# ក្រមបរិស្ថាននៃព្រះរាជាណាចក្រកម្ពុជា

**សេចក្តីព្រាងលើកទី២១ - ថ្ងៃទី០១ ខែឧសភា ឆ្នាំ២៨ ខែមីនា មីនា ២០១៦**

## គន្ថីទី ១ – បទប្បញ្ញត្តិទូទៅ

### ជំពូកទី ១ – គោលបំណង

#### មាត្រា ១៖ គោលដៅ

ក្រមបរិស្ថាននេះមានគោលដៅ ក្នុងការលើកកម្ពស់ការអភិវឌ្ឍន៍ប្រកបដោយចីរភាព នៃព្រះរាជាណាចក្រកម្ពុជា តាមរយៈការការពារបរិស្ថាន និងការប្រើប្រាស់ប្រកបដោយចីរភាពនៃធនធានធម្មជាតិ ។

#### មាត្រា ២៖ គោលបំណង

ក្រមបរិស្ថានមានគោលបំណង ដូចខាងក្រោម ៖

(ក) អភិរក្សជីវៈចម្រុះ ប្រព័ន្ធអេកូឡូស៊ី និងសេវាប្រព័ន្ធអេកូឡូស៊ី នៃព្រះរាជាណាចក្រកម្ពុជា ។

Commented [M1]: យោបល់របស់ karina watkins

(ខ) ការពារបរិស្ថានពីភាពអន្តរាយ និងការខូចខាត និងគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព ស្របតាមមាត្រា ៥៩ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

(គ) ថែរក្សា និងលើកកម្ពស់វប្បធម៌ជាតិ ថែរក្សាប្រាសាទបុរាណ និងវត្ថុសិល្បៈបុរាណ និងស្តារឡើងវិញនូវមនីយដ្ឋានប្រវត្តិសាស្ត្រ ស្របតាមមាត្រា ៦៩ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

(ឃ) ធានាសុខភាពរបស់ប្រជាពលរដ្ឋស្របតាមមាត្រា ៧២ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

(ង) ការពារសិទ្ធិបុគ្គល និងសិទ្ធិសមូហភាព នៃជនជាតិដើមភាគតិច ដូចមានកំណត់នៅក្នុងអនុក្រឹត្យលេខ ៨៣ អនក.បក និង ស.ជ.ណ លេខ ស.រ ៦៥៣ ។

Commented [M2]: យោបល់របស់ Sao Sotheary, CI

(ចឃ) ធានាថា គោលបំណងនានានៃកិច្ចការពារបរិស្ថាន និងការអភិវឌ្ឍន៍ប្រកបដោយចីរភាព ត្រូវបានដាក់បញ្ចូលយ៉ាងពេញលេញទៅក្នុងផែនការសេដ្ឋកិច្ចថ្នាក់ជាតិ និងថ្នាក់តំបន់ និងទៅក្នុងផែនការ និងការគ្រប់គ្រងធនធានធម្មជាតិ ។

(ឆង) អនុវត្តផែនការសកម្មភាព និងយុទ្ធសាស្ត្របរិស្ថានជាតិ ។

(ជច) លើកកម្ពស់វិធីសាស្ត្រសហប្រតិបត្តិការ ចំពោះកិច្ចការពារ និងការគ្រប់គ្រងបរិស្ថាន ដែលមានការចូលរួមពីសំណាក់រដ្ឋាភិបាល សហគមន៍ អ្នកកាន់កាប់ដី ជនជាតិដើមភាគតិច និងធុរៈកិច្ច ។

(ឈឆ) ជួយដល់ការអនុវត្តនូវការទទួលខុសត្រូវផ្នែកបរិស្ថានជាលក្ខណៈអន្តរជាតិរបស់ព្រះរាជាណាចក្រកម្ពុជា ។

(ញជ) អនុវត្តគោលការណ៍សំខាន់ៗនៃច្បាប់ និងគោលនយោបាយបរិស្ថាន ដូចមានចែងនៅក្នុងជំពូកទី២ ។

## មាត្រា ៣៖ វិសាលភាព

ក្រមនេះបញ្ញត្តិអំពី សកម្មភាពការពារបរិស្ថាន គោលនយោបាយ វិធានការ និងធនធាន សម្រាប់កិច្ចការពារបរិស្ថាន ព្រមទាំងសិទ្ធិ និងកាតព្វកិច្ចរបស់អង្គការ សហគមន៍ ក្រុមគ្រួសារ និងបុគ្គលទាំងឡាយដែលទាក់ទងនឹងកិច្ចការពារបរិស្ថាន ។

### ស្ថាប័នដែលត្រូវអនុវត្ត

ក្រមបរិស្ថាននេះអនុវត្តចំពោះ ស្ថាប័នរដ្ឋ អង្គការ ក្រុមគ្រួសារ និងបុគ្គលគ្រប់រូប និងពលរដ្ឋកម្ពុជាដែលរស់នៅបរទេស និងអង្គការបរទេស និងបុគ្គលនានា ដែលមានប្រតិបត្តិការនៅក្នុងដែនដីនៃព្រះរាជា

ណាចក្រកម្ពុជា ។ នៅក្នុងករណីដែលសន្ធិសញ្ញាអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋសមាជិក មានចែងអំពីបទប្បញ្ញត្តិដែលខុសពីបទប្បញ្ញត្តិដែលមាននៅក្នុងក្រម បទប្បញ្ញត្តិដែលមានចែងនៅក្នុងសន្ធិសញ្ញាអន្តរជាតិនោះ ត្រូវមានឧត្តមានុភាពជាង ។

### **មាត្រា ៤៖ និយមន័យ/សន្ទានុក្រម**

វាក្យស័ព្ទ ដែលប្រើប្រាស់នៅក្នុងក្រមបរិស្ថានេះ មានដូចខាងក្រោម៖

*(មាត្រានេះត្រូវមាននិយមន័យនៃវាក្យស័ព្ទសំខាន់ៗ ដែលប្រើនៅក្នុងក្រមនេះ ដូចជា "ការអភិវឌ្ឍន៍ប្រកបដោយចីរភាព" "ស្តង់ដារបរិស្ថាន" "ការអនុវត្តល្អបំផុត" ជាដើម)*

*(និយមន័យទាំងអស់នឹងត្រូវផ្អែកលើនិយមន័យដែលមានស្រាប់នៅក្នុងអត្ថបទច្បាប់នៃកម្ពុជា ក្នុងករណីដែលអាចប្រើប្រាស់បាន ព្រមទាំងការប្រើប្រាស់វាក្យស័ព្ទសំខាន់ៗ ពាក់ព័ន្ធជាអន្តរជាតិ)*

និយមន័យនៃវាក្យស័ព្ទបច្ចេកទេស ត្រូវកំណត់នៅក្នុងផ្នែកសន្ទានុក្រមនៃក្រមនេះ ។

## **ជំពូកទី ២ – គោលការណ៍**

ក្រមបរិស្ថាននេះ ពឹងផ្អែកទៅលើ និងគួរតែត្រូវបានអនុវត្ត និងបកស្រាយ ឱ្យស្របទៅតាមគោលការណ៍ជាមូលដ្ឋានគ្រឹះនៃច្បាប់ និងគោលនយោបាយបរិស្ថាន ដូចខាងក្រោម ៖

### **មាត្រា ៥៖ គោលការណ៍នៃការចូលរួមជាសាធារណៈ**

គោលការណ៍នៃការចូលរួមជាសាធារណៈ ពោលគឺ បុគ្គលទាំងឡាយណា ដែលអាចទទួលរងនូវផលប៉ះពាល់ដោយសារការសម្រេចចិត្តណាមួយ ត្រូវមានសិទ្ធិផ្តល់នូវ ការចូលរួមមតិយោបល់ដ៏មានអត្ថន័យ ទាន់ពេលវេលា  និងប្រកបដោយការយល់ដឹងបន្ទាប់ពីទទួលបានព័ត៌មាន  មុនពេលដែលការសម្រេចចិត្តនោះត្រូវបានធ្វើឡើង ។ ពួកគេក៏អាចមានឥទ្ធិពលក្នុងដំណើរការនៃការសម្រេចចិត្តនោះ នៅក្នុងលក្ខណៈប្រកបដោយការចូលរួម តម្លាភាព និងគណនេយ្យភាពផងដែរ ។ ការធ្វើការសម្រេចចិត្តប្រកបដោយការចូលរួមលើកកម្ពស់សម្ថភាពរបស់រាជរដ្ឋាភិបាលក្នុងការឆ្លើយតបចំពោះក្តីបារម្ភ និងតម្រូវការរបស់សាធារណៈជន ដើម្បីពង្រឹងនូវការមូលមតិគ្នា និងធ្វើឱ្យប្រសើរឡើងចំពោះការទទួលយកនូវ និងការគោរពតាម សេចក្តីសម្រេចផ្នែកបរិស្ថាន ដោយសារប្រជាពលរដ្ឋយល់ថាខ្លួនមានភាពជាម្ចាស់លើការសម្រេចចិត្តទាំងនេះ ។

**មាត្រា ៦៖** គោលការណ៍នៃការទទួលបានព័ត៌មាន

គោលការណ៍នៃការទទួលបានព័ត៌មាន ពោលគឺ រូបវន្តបុគ្គល នីតិបុគ្គល និងសង្គមស៊ីវិល ត្រូវមានសិទ្ធិសមរម្យក្នុងការទទួលបានព័ត៌មានទាក់ទងនឹងបរិស្ថាន និងការអភិវឌ្ឍ ដែលព័ត៌មានទាំងនោះត្រូវបានគ្រប់គ្រងដោយអាជ្ញាធរសាធារណៈ ជាអាទិ៍ ព័ត៌មានអំពីសម្ភារៈ និងសកម្មភាពគ្រោះថ្នាក់នៅក្នុងសហគមន៍របស់ពួកគេ ។ រាល់ព័ត៌មានស្តីពីការគ្រប់គ្រងធនធានធម្មជាតិ ត្រូវធ្វើឲ្យមានការដឹងឮ និងប្រើប្រាស់បានយ៉ាងទូលំទូលាយទៅដល់សាធារណៈជន នៅក្នុងលក្ខណៈមួយដែលបង្កើតឱកាសជាអតិបរមា សម្រាប់ការចូលរួមជាសាធារណៈ នៅក្នុងការសម្រេចចិត្ត ដែលប៉ះពាល់ដល់សង្គម និងបរិស្ថាន ។

**មាត្រា ៧៖** គោលការណ៍នៃការទទួលបានដំណោះស្រាយប្រកបដោយប្រសិទ្ធភាព

គោលការណ៍នៃការទទួលបានដំណោះស្រាយប្រកបដោយប្រសិទ្ធភាព ពោលគឺ ប្រជាពលរដ្ឋ អង្គការ និងអង្គភាពស្របច្បាប់ ត្រូវមានសិទ្ធិទទួលបាននូវមធ្យោបាយសមរម្យ ទោះបី ផ្នែករដ្ឋបាលក្តី ឬផ្នែកតុលាការក្តី និងទទួលបាននូវដំណោះស្រាយដែលសមរម្យ និងប្រកបដោយប្រសិទ្ធភាព ដើម្បីសម្រេចបាននូវការដោះស្រាយវិវាទបរិស្ថាន ។ នីតិវិធី និងដំណោះស្រាយ ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល គួរតែមានអត្ថិភាព ដើម្បីពង្រឹងសិទ្ធិនានាទាក់ទងនឹងនីតិវិធី និងដើម្បីដាក់ទណ្ឌកម្មដល់ជនទាំងឡាយណាដែលត្រូវទទួលខុសត្រូវចំពោះការបង្កឱ្យមានការខូចខាតដល់បរិស្ថាន ។

**មាត្រា ៨៖** គោលការណ៍អ្នកបំពុលត្រូវទទួលខុសត្រូវលើតម្លៃនៃការបំពុល

គោលការណ៍អ្នកបំពុលត្រូវទទួលខុសត្រូវលើតម្លៃនៃការបំពុល ពោលគឺ បុគ្គលទាំងអស់ ដែលរួមមាន នីតិបុគ្គលឯកជន និងនីតិបុគ្គលសាធារណៈ ដែលបានបង្កឱ្យមាន គ្រោះថ្នាក់ ឬការបំពុលបរិស្ថាន ជាអាទិ៍ ការបំពុលដោយសំឡេង រំញ័រ ក្លិន ផ្សែង ការបង្ហូរសំណល់រាវ ឬការបញ្ចេញចោលនូវសំណល់គ្រប់ប្រភេទ ឬការបង្កឱ្យមានការខូចខាតដល់បរិស្ថាន ត្រូវទទួលបន្ទុកក្នុងការបង់ថ្លៃចំណាយទៅលើការជួសជុលការខូចខាត ព្រមទាំង ការទប់ស្កាត់ ការបញ្ចៀស និងការកាត់បន្ថយនូវការខូចខាតនោះ ។

**មាត្រា ៩៖** គោលការណ៍ប្រុងប្រយ័ត្នជាមុន

គោលការណ៍ប្រុងប្រយ័ត្នជាមុន ពោលគឺ ក្នុងស្ថានភាពដែលបរិស្ថានអាចប្រឈមនឹងការគម្រាមកំហែងនៃការខូចខាតយ៉ាងធ្ងន់ធ្ងរ ដែលមិនអាចជួសជុលឱ្យដូចដើមវិញបាន នោះ ~~ភាពស្រពិចស្រពិល និង~~កង្វះខាតនូវភាពប្រាកដប្រជាពេញលេញផ្នែកវិទ្យាសាស្ត្រ មិនត្រូវយកមកប្រើប្រាស់ជាមូលហេតុ ក្នុង ~~ការបដិសេធនូវអត្ថិភាពនៃហានិភ័យចំពោះ~~ការពន្យាការចាត់វិធានការដែលមានប្រសិទ្ធិភាព ដើម្បីទប់ស្កាត់នូវការធ្វើឱ្យខូចខាតដល់~~គុណភាព~~បរិស្ថាន ~~និងធនធានជីវៈចម្រុះ~~ បានឡើយ ។

**មាត្រា ១០៖** គោលការណ៍នៃការទប់ស្កាត់

Commented [M3]: ត្រូវបានផ្លាស់ប្តូរដើម្បីកែតម្រូវនិយមន័យនៃ គោលការណ៍ប្រុងប្រយ័ត្នជាមុន

គោលការណ៍នៃការទប់ស្កាត់ ពោលគឺ ផលប៉ះពាល់អវិជ្ជមានដល់បរិស្ថាន គួរតែត្រូវបានបញ្ឈប់មុនពេលដែលវាកើតមានឡើង ។ ក្នុងការអនុវត្តគោលការណ៍នេះ គេគួរតែចាត់វិធានការតាំងពីដំណាក់កាលដំបូង ដើម្បីកាត់បន្ថយ ឬទប់ស្កាត់ ការខូចខាតដល់បរិស្ថាន ជាជាងរង់ចាំឱ្យមានផលប៉ះពាល់ដែលមិនអាចជួសជុលបានកើតឡើង ។ គោលការណ៍នៃការទប់ស្កាត់ គឺផ្អែកលើគំនិតដែលថា "ការទប់ស្កាត់នូវការខូចខាត គឺប្រសើរជាជាង ការចាត់វិធានការក្នុងការស្តារបរិស្ថានឡើងវិញ បន្ទាប់ពីការខូចខាតបានកើតឡើងហើយ" ។

## មាត្រា ១១៖ គោលការណ៍សមធម៌រវាងជំនាន់បច្ចុប្បន្ន និងអនាគត

គោលការណ៍សមធម៌រវាងជំនាន់បច្ចុប្បន្ន និងអនាគត ពោលគឺ សិទ្ធិក្នុងការធ្វើការអភិវឌ្ឍ រួមបញ្ចូល ការសម្រេចចិត្តនានា ដែលប៉ះពាល់ដល់ធនធានធម្មជាតិ និងសេវាកម្មប្រព័ន្ធអេកូឡូស៊ី ត្រូវតែអនុវត្តឱ្យបាន ដើម្បីបំពេញតម្រូវការនៃការអភិវឌ្ឍ ក៏ដូចជាតម្រូវការសង្គម និងបរិស្ថាន របស់មនុស្ស ទាំងក្នុងជំនាន់បច្ចុប្បន្ន និងអនាគត ប្រកបដោយលក្ខណៈសមធម៌ ។

## មាត្រា ១២៖ គោលការណ៍នៃការទទួលខុសត្រូវផ្នែកបរិស្ថាន

ការទទួលខុសត្រូវក្នុងការសងសំណង ចំពោះការធ្វើឱ្យខូចខាតដល់បរិស្ថាន អនុវត្តចំពោះការខូចខាតបរិស្ថាន និងការគម្រាមកំហែងនៃការខូចខាតដែលអាចកើតឡើង ដែលបណ្តាលមកពីសកម្មភាពអភិវឌ្ឍន៍ នៅក្នុងករណីដែលគេអាចបង្កើតបាននូវទំនាក់ទំនងរវាងការខូចខាត និងសកម្មភាពនោះ ។ ការទទួលខុសត្រូវ គួរតែរួមបញ្ចូលនូវ តម្លៃនៃការស្តារឡើងវិញនូវប្រព័ន្ធអេកូឡូស៊ី ឬធនធាន ឬនៃការដាក់ជំនួសមកវិញនូវធនធានដែលរងការខូចខាត តម្លៃនៃការវាយតម្លៃការខូចខាត និងការបាត់បង់បឋមដែលរង់ចាំនូវការស្តារឡើងវិញ ឬការដាក់ជំនួសវិញ ។ ការទទួលខុសត្រូវ អាចជាការទទួលខុសត្រូវលក្ខណៈតឹងរ៉ឹង ដោយមិនចាំបាច់ត្រូវការនូវភស្តុតាងនៃកំហុស ហើយវាអាចជាការទទួលខុសត្រូវច្រើនជង ឬមានលក្ខណៈរួមគ្នា ។

## មាត្រា ១៣៖ គោលការណ៍នៃការធ្វើការសម្រេចចិត្តដោយផ្អែកលើភស្តុតាង

ការធ្វើការសម្រេចចិត្តលើគោលការណ៍បរិស្ថាន និងធនធានធម្មជាតិ គួរតែមានភាពបើកចំហ និងយកភស្តុតាងជាមូលដ្ឋាន ដោយប្រើប្រាស់ព័ត៌មានដ៏ប្រសើរបំផុតដែលអាចស្វែងរកបាន ។ ព័ត៌មានទាំងនោះអាចមានលក្ខណៈវិទ្យាសាស្ត្រ ឬបច្ចេកទេស និងអាចជាទិន្នន័យដែលប្រមូលបានមកពីសហគមន៍ និងចំណេះដឹងរបស់ជនជាតិដើមម្ចាស់ស្រុកផងដែរ ។

XXX

Commented [M4]: សូមកត់សម្គាល់មតិយោបល់របស់លោក Raphaele Deau ក្នុងការបញ្ចូល គោលការណ៍ អ្នកប្រើប្រាស់ត្រូវបង់ថ្លៃចំណាយ និងគោលការណ៍ FPIC

**មាត្រា ១៤៖ គោលការណ៍ "សមភាពយេនឌ័រសម្រាប់ការសម្រេចចិត្តផ្នែកធនធានធម្មជាតិ"**

គោលការណ៍នេះលើកកម្ពស់ការចូលរួមរបស់ស្ត្រីនៅក្នុងការធ្វើការសម្រេចចិត្តអំពីបរិស្ថាន នៅគ្រប់កម្រិតទាំងអស់ ។ ការវាយតម្លៃអំពីផលប៉ះពាល់សម្រាប់គម្រោងអភិវឌ្ឍន៍ និងគោលនយោបាយបរិ-ស្ថានពាក់ព័ន្ធ ត្រូវរួមបញ្ចូលនូវយន្តការនានា ដើម្បីវាយតម្លៃប្រកបដោយប្រសិទ្ធភាពនូវផលប៉ះពាល់លើស្ត្រី ។ ក្តីបារម្ភ និងទស្សនៈស្តីពីយេនឌ័រ នឹងត្រូវដាក់បញ្ចូលទៅក្នុងគោលនយោបាយ និងកម្មវិធីសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងទៅក្នុងការអនុវត្តនៃក្រមនេះ ។

## ជំពូកទី ៣ – ភារកិច្ចទូទៅក្នុងការបញ្ចៀសនូវការខូចខាតបរិស្ថាន

**មាត្រា #:**

បុគ្គលគ្រប់រូបមិនត្រូវអនុវត្តសកម្មភាពណាមួយដែលបង្ក ឬដែលអាចបង្កនូវ ការខូចខាតបរិស្ថានបានឡើយ ~~លើកលែងតែបុគ្គលនោះចាត់វិធានការទាំងអស់ដែលសមហេតុផល និងដែលអាចអនុវត្តបានដើម្បីទប់ស្កាត់ ឬកាត់បន្ថយជាអប្បបរមានូវការខូចខាតនោះ-~~ (កាតព្វកិច្ចទូទៅផ្នែកបរិស្ថាន) ។

## ជំពូកទី ៤ – កិច្ចព្រមព្រៀងអន្តរជាតិស្តីពីបរិស្ថាន

- *ជំពូកនេះនឹងពន្យល់អំពីរបៀបដែលក្រមបរិស្ថានត្រូវអនុវត្ត ហើយដែលត្រូវផ្អែកទៅលើកិច្ចព្រមព្រៀងអន្តរជាតិ និងកិច្ចព្រមព្រៀងតំបន់ ដែលមានស្រាប់ ។*

- *ជំពូកនេះនឹងដោះស្រាយផងដែរ អំពីកិច្ចព្រមព្រៀង និងសន្ធិសញ្ញា ក្នុងពេលអនាគត ព្រមទាំងរបៀបដែលកិច្ចព្រមព្រៀងទាំងនេះត្រូវដាក់បញ្ចូលទៅក្នុងការទទួលខុសត្រូវផ្នែកបរិស្ថាននៃក្រសួងពាក់ព័ន្ធ ។*

# គន្ថីទី ២ – ការរៀបចំនូវស្ថាបនមានសមត្ថកិច្ច/បញ្ហាសមត្ថកិច្ច

- *គន្ថីនេះនឹងបង្កើតនូវគោលបំណងនៃកិច្ចសហការអន្តរក្រសួង និងតម្រូវការសម្រាប់ការពិគ្រោះយោបល់ និងការពិភាក្សា រវាងក្រសួងពាក់ព័ន្ធ ដើម្បីឈានទៅសម្រេចបាននូវគោលបំណងទាំងឡាយនៃក្រមនេះ ។ ការរៀបចំសមត្ថកិច្ច នឹងត្រួតពិនិត្យអំពី តួនាទី ភារកិច្ច និងមធ្យោបាយនៃកិច្ចសហប្រតិបត្តិការ នៃ~~ក្រសួង~~ស្ថាប័នមួយចំនួន ដូចខាងក្រោម ៖*

- *ក្រសួងបរិស្ថាន*
- *ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ*
- *ក្រសួងរ៉ែ និងថាមពល*
- *ក្រសួងធនធានទឹក និងឧតុនិយម*
- *ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់*
- *ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *ក្រសួងវប្បធម៌*
- *ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*

## ជំពូកទី # – ទំនាក់ទំនងដែលពាក់ព័ន្ធផ្នែកបរិស្ថានរវាងក្រសួងបរិស្ថាន និង ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ

## ជំពូកទី # – ទំនាក់ទំនងដែលពាក់ព័ន្ធផ្នែកបរិស្ថានរវាងក្រសួងបរិស្ថាន និង ក្រសួងរ៉ែ និងថាមពល

## ជំពូកទី # – ទំនាក់ទំនងដែលពាក់ព័ន្ធផ្នែកបរិស្ថានរវាងក្រសួងបរិស្ថាន និង ក្រសួងធនធានទឹក និងឧតុនិយម

## ជំពូកទី # – ទំនាក់ទំនងដែលពាក់ព័ន្ធផ្នែកបរិស្ថានរវាងក្រសួងបរិស្ថាន និង ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## ជំពូកទី # – ការបញ្ជាក់អំពីតួនាទី និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាជាតិអភិវឌ្ឍដោយចីរភាព

## ជំពូកទី # – ការបញ្ជាក់អំពីតួនាទី និងការទទួលខុសត្រូវរបស់កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

## ជំពូកទី # – តួនាទីរបស់អាជ្ញាធរនានា ជាអាទិ៍ អាជ្ញាធរអប្សរា អាជ្ញាព្រះវិហារ អាជ្ញាធរបឹងទន្លេសាប និងគណៈកម្មាជាតិទន្លេមេគង្គ

## ជំពូកទី # – បង្កើតយន្តការក្នុងការលើកកម្ពស់គណៈកម្មការអន្តរនាយកដ្ឋាន

## ជំពូកទី # – បង្កើតនូវគណៈកម្មការធ្វើផែនទី និងផែនការជាតិស្តីពីប្រព័ន្ធអេកូឡូស៊ី

# គន្ថីទី ៣ – ការចូលរួមជាសាធារណៈ និងការទទួលបានព័ត៌មានបរិស្ថាន

- *គន្ថីនេះនឹងបញ្ជាក់ និងចែងលម្អិតអំពីលក្ខខណ្ឌតម្រូវនានាសម្រាប់ការចូលរួមជាសាធារណៈ និងការទទួលបានព័ត៌មានបរិស្ថាន ។ គោលបំណងនៃគន្ថីនេះ គឺផ្តល់នូវវិធីសាស្ត្រដែលមានលក្ខណៈស៊ីសង្វាក់គ្នា ក្នុងចំណោមបណ្តាក្រសួងទាំងអស់ ហើយដែលទាក់ទងទៅនឹងសេចក្តីសម្រេចផ្សេងៗ ដែលត្រូវបានធ្វើឡើងនៅក្រោមក្រមបរិស្ថាន ។*

Commented [M5]: សូមពិចារណាអំពីគន្ថីពីរផ្សេងគ្នា ។ គន្ថី១ ស្តីពី ការចូលរួមជាសាធារណៈ មួយទៀតស្តីពី ការទទួលបានព័ត៌មាន យោងតាមយោបល់ក្រុម ៧ (សិក្ខាសាលាថ្ងៃទី៦ ខែមេសា)

## ជំពូកទី # – ការពិគ្រោះយោបល់ជាសាធារណៈ ជាលក្ខខណ្ឌតម្រូវជាមូលដ្ឋានសម្រាប់ការសម្រេចចិត្តផ្នែកបរិស្ថាន

### មាត្រា #

Commented [M6]: មាត្រាខាងក្រោមនេះ យកមកពីសេចក្តីព្រាងច្បាប់ស្តីពី EIA ហើយនឹងត្រូវកែសម្រួល ដើម្បីពង្រីកវិសាលភាពឱ្យលើសពី EIA គឺពីស្ថានភាពគម្រោងជាក់លាក់ ទៅគ្រប់ស្ថានភាពទាំងអស់ ដែលការចូលរួមជាសាធារណៈ និងការទទួលបានព័ត៌មាន មានភាពពាក់ព័ន្ធគ្នា មានភាពស៊ីសង្វាក់គ្នាជាមួយក្របខណ្ឌទូទៅនៃក្រមនេះ ។

គោលបំណងចម្បងនៃការចូលរួមជាសាធារណៈ គឺដើម្បីធានាថា អ្នកដែលទទួលរងផលប៉ះពាល់ និងភាគីពាក់ព័ន្ធ ៖

-បានទទួលដំណឹងគ្រប់ជ្រុងជ្រោយអំពីគម្រោង

-មានឱកាសចូលរួមក្នុងកិច្ចពិភាក្សា និងកិច្ចដំណើរការនៃការធ្វើសេចក្តីសម្រេចពាក់ព័ន្ធនឹងគម្រោង និង

-មានឱកាសចូលរួមក្នុងការអង្កេតតាមដានគម្រោង

ម្ចាស់គម្រោងដែលត្រូវធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវដាក់បញ្ចូលការចូលរួម និងការពិគ្រោះយោបល់ជាសាធារណៈ ពីរដ្ឋបាលមូលដ្ឋាន សង្គមស៊ីវិល តំណាងសហគមន៍ ប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ដោយសារគម្រោង និងអ្នកពាក់ព័ន្ធដទៃទៀត ទៅក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នៅដំណាក់កាលរៀបចំផែនការគម្រោង ដើម្បី៖

-កំណត់ផ្នែកដែលមានសារៈសំខាន់ផ្នែកបរិស្ថាន សេដ្ឋកិច្ច សង្គម និងវប្បធម៌

-ប្រមូលមតិយោបល់ពីភាគីពាក់ព័ន្ធ និងដាក់បញ្ចូលមតិយោបល់ទាំងនោះ ទៅក្នុងកិច្ចដំណើរការនៃការធ្វើសេចក្ដីសម្រេច ។

-ពិនិត្យគម្រោងស្នើសុំ និងពន្យល់ពីផលប៉ះពាល់បរិស្ថាន សេដ្ឋកិច្ច សង្គម និងវប្បធម៌

-ពិចារណាជម្រើសដទៃទៀត និងវិធានការកាត់បន្ថយផលប៉ះពាល់នានា ។

នីតិវិធីនៃការចូលរួមជាសាធារណៈ នៅក្នុងដំណាក់កាលសិក្សាពិគ្រោះយោបល់ ការពិនិត្យរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងការអង្កេតតាមដានគម្រោង ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

**មាត្រា #**

របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញត្រូវ៖

-កត់ត្រាទុកនូវយោបល់របស់សាធារណជនដែលបានចូលរួម នៅក្នុងដំណាក់កាលរៀបចំផែនការ និងដំណាក់កាលអនុវត្តលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

-ផ្តោតលើបញ្ហានានា ដែលលើកឡើងដោយស្ត្រី និងបណ្តាជនដែលអាចទទួលរងគ្រោះខ្លាំងបំផុត ពីផលប៉ះពាល់ដែលអាចកើតមានពីគម្រោងដែលបានស្នើឡើង ។

-ដាក់បញ្ចូលនូវសេចក្តីលំអិត អំពីផលប៉ះពាល់របស់គម្រោងដល់សាធារណជន និងការទទួលយក ឬបដិសេធសំណើរបស់សាធារណជន ។

-ផ្តល់ហេតុផលនៃការបដិសេធឲ្យបានច្បាស់លាស់ នៅក្នុងករណីដែលម្ចាស់គម្រោងបដិសេធសំណើរបស់សាធារណជន ។

**មាត្រា #**

ក្រសួងបរិស្ថានត្រូវធានាថា របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ និងឯកសារពាក់ព័ន្ធរួមមាន លិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផែនការគ្រប់គ្រងបរិស្ថាន ត្រូវបានផ្សព្វផ្សាយជាសាធារណៈ ហើយភាគីពាក់ព័ន្ធ និងសហគមន៍ដែលទទួលរងផលប៉ះពាល់ដោយសារគម្រោង អាចទទួលបានព័ត៌មានគ្រប់គ្រាន់ និងច្បាស់លាស់ ។

ម្ចាស់គម្រោងត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ តាមរយៈគេហទំព័ររបស់ខ្លួន យ៉ាងហោចណាស់ នូវឯកសារថតចម្លងនៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ផែនការគ្រប់គ្រងបរិស្ថាននៃគម្រោង ផែនទី និងផែនការនៃគម្រោង ព្រមទាំងបណ្តាវិធានការកាត់បន្ថយផលប៉ះពាល់នៃគម្រោងដែលត្រូវបានស្នើឡើង ។

នីតិវិធីសម្រាប់ការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មាន ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

## ជំពូកទី # – ភារៈកិច្ចក្នុងការពិគ្រោះយោបល់ជាមួយអ្នកដែលអាចទទួលរងនូវផលប៉ះពាល់

## ជំពូកទី # – ភារៈកិច្ចក្នុងការពិចារណាអំពីក្ដីកង្វល់ដែលលើកឡើងដោយ សហគមន៍

## ជំពូកទី # – ការកំណត់អត្តសញ្ញាណអ្នកទទួលផលប៉ះពាល់ពីគម្រោង និងអ្នកពាក់ព័ន្ធផ្សេងទៀត

## ជំពូកទី # – អំឡុងពេលអប្បបរមាដែលអនុញ្ញាតសម្រាប់ការពិគ្រោះយោបល់ជាសាធារណៈនៅក្នុងបញ្ហាធនធានធម្មជាតិ

## ជំពូកទី # – អំឡុងពេលអប្បបរមាដែលអនុញ្ញាតសម្រាប់ការពិគ្រោះយោបល់ជាសាធារណៈនៅក្នុងការវាយតម្លៃប៉ះហេតុពាល់បរិស្ថាន

## ជំពូកទី # – អំឡុងពេលអប្បបរមាដែលអនុញ្ញាតសម្រាប់ជនជាតិដើមភាគតិចក្នុងការផ្ដល់មតិយោបល់

## ជំពូកទី # – ការយល់ព្រមជាមុន ដោយសេរី បន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ សម្រាប់ជនជាតិដើមភាគតិច ចំពោះបញ្ហាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងធនធានធម្មជាតិ

Commented [M7]: សហគមន៍??? យោបល់របស់ Raphaele Deau

### មាត្រា #

កិច្ចដំណើរការចូលរួមសាធារណៈត្រូវធានាថា មានការយល់ព្រមពីសហគមន៍ដែលទទួលរងផលប៉ះពាល់ដោយសារគម្រោង ចំពោះវិធានការកាត់បន្ថយផលប៉ះពាល់ដែលបានស្នើឡើង ដោយផ្អែកលើគោលការណ៍យល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីជ្រាបព័ត៌មានគ្រប់ជ្រុងជ្រោយ ។

ក្នុងវិធានការកាត់បន្ថយផលប៉ះពាល់បរិស្ថាននេះ ម្ចាស់គម្រោងត្រូវ ៖

-កំណត់វិធានការនានា ក្នុងការលើកកម្ពស់ជីវភាព និងជួយដល់អ្នកដែលទទួលរងផលប៉ះពាល់ដោយសារគម្រោង ។

-ធានាថា អ្នកដែលទទួលរងផលប៉ះពាល់ បានចូលរួមក្នុងការរៀបចំការផ្លាស់ទីលំនៅថ្មី ដើម្បីកាត់បន្ថយផលប៉ះពាល់នៃការផ្លាស់ទីលំនៅថ្មីឲ្យបានកម្រិតអប្បបរមា ក្នុងការធានាថា សំណងលើការបាត់បង់ទ្រព្យសម្បត្តិ ត្រូវបានដោះស្រាយដោយយុត្តិធម៌សមស្របជាមុនសិន និងដែលទទួលយកបានតាមតម្លៃទីផ្សារ ហើយវិធានការកាត់បន្ថយផលប៉ះពាល់បរិស្ថានមានលក្ខណៈត្រឹមត្រូវ ។

ក្នុងករណីដែលសហគមន៍ដែលរងផលប៉ះពាល់ មិនយល់ស្របចំពោះវិធានការកាត់បន្ថយនានាដែលម្ចាស់គម្រោងបានស្នើខាងលើ គម្រោងអភិវឌ្ឍន៍នៅតែបន្តដដែល ប៉ុន្តែម្ចាស់គម្រោងត្រូវកំណត់ រកវិធានការកាត់បន្ថយផលប៉ះពាល់ផ្សេងទៀត ឬដោះស្រាយរាល់ផលប៉ះពាល់នោះដល់សហគមន៍ ។

នីតិវិធីនៃការដោះស្រាយសំណងដល់សហគមន៍ដែលទទួលរងផលប៉ះពាល់ និងនីតិវិធីនៃការផ្លាស់ប្តូលំនៅថ្មី ត្រូវកំណត់ដោយអនុក្រឹត្យ ។

បែបបទ និងនីតិវិធីនៃការទូទាត់សំណងការខូចខាត ដល់សហគមន៍ទទួលរងផលប៉ះពាល់ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង រវាងក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី # – ការឆ្លើយតបចំពោះការដាក់ពាក្យរបស់សាធាណៈជន

## ជំពូកទី # – ការពិចារណាអំពីការដាក់ពាក្យរបស់សាធារណៈជន

## ជំពូកទី # – ការផ្សព្វផ្សាយនូវការដាក់ពាក្យស្នើសុំអំពីបញ្ហាធនធានធម្មជាតិ

## ជំពូកទី # – គណៈកម្មការស៊ើបអង្កេតអំពីការសម្រេចចិត្តលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬធនធានធម្មជាតិ

## ជំពូកទី # – បទប្បញ្ញត្តិពិសេសសម្រាប់គម្រោង និងសកម្មភាព ដែលមានផលប៉ះពាល់គួរឱ្យកត់សម្គាល់ ឬគម្រោង ឬសកម្មភាពដែលមានភាពចម្រូងចម្រាស់

## ជំពូកទី # – ការទទួលបានព័ត៌មានមុនពេលដែលការសម្រេចត្រូវបានធ្វើឡើង

## ជំពូកទី # – ពេលវេលាសមរម្យសម្រាប់ការទទួលបានព័ត៌មាន

## ជំពូកទី # – ព័ត៌មានដែលអាចស្វែងរកបាន

## ជំពូកទី # – ការការពារចំពោះអ្នករាយការណ៍អំពីបញ្ហាមិនប្រក្រតី

## ជំពូកទី # – ការការពារចំពោះសារព័ត៌មានដែលបោះពុម្ពផ្សាយព័ត៌មាន

## ជំពូកទី # – ការអង្កេតតាមដានបរិស្ថាន

## ជំពូកទី # – ប្រព័ន្ធអង្កេតតាមដានបរិស្ថាន

## ជំពូកទី # – ការធ្វើផែនការអំពីប្រព័ន្ធអង្កេតតាមដានបរិស្ថាន

## ជំពូកទី # – កម្មវិធីអង្កេតតាមដានបរិស្ថាន

## ជំពូកទី # – សូចនាករបរិស្ថាន

## ជំពូកទី # – របាយការណ៍ស្ថានភាពបរិស្ថានកម្រិតខេត្ត

### ជំពូកទី # – របាយការណ៍ហេតុប៉ះពាល់បរិស្ថាន ដោយឧស្សាហកម្ម និងតាមវិស័យ

### ជំពូកទី # – ការទទួលបានរបាយការណ៍បរិស្ថានជាសាធារណៈ

### ជំពូកទី # – របាយការណ៍ជាតិស្តីពីបរិស្ថាន

### ជំពូកទី # – ស្ថិតិបរិស្ថាន និងការសម្រេចបានទិន្នន័យ និងព័ត៌មានបរិស្ថាន

### ជំពូកទី # – ការបោះពុម្ពផ្សាយ និងការផ្តត់ផ្គង់ព័ត៌មានស្តីពីបរិស្ថាន

### ជំពូកទី # – ការបោះពុម្ពផ្សាយព័ត៌មាន និងទិន្នន័យស្តីពីបរិស្ថាន

### ជំពូកទី # – ការអនុវត្តនូវសិទ្ធិជាមូលដ្ឋានអំពីការការពារបរិស្ថាន

## គន្លឹះទី ៤ – ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

- *គន្លឹះនេះនឹងកំណត់អំពីដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅក្នុងប្រទេសកម្ពុជា ដែលនឹងជំនួសឱ្យអនុក្រឹត្យស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន លេខ ៧២ អនក.បក ឆ្នាំ១៩៩៩ ។ ហើយវានឹងដាក់បញ្ចូលនូវព័ត៌មានលម្អិត និងបទប្បញ្ញត្តិនៃសេចក្តីព្រាងច្បាប់ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។*
- *គន្លឹះនេះនឹងបែងផងដែរ ទាក់ទងនឹងគម្រោងថ្មីៗ រួមជាមួយនឹងគម្រោងដែលមានស្រាប់ ព្រមទាំងកំណត់ឱ្យមានការវាយតម្លៃចំនួន ៣ កម្រិត ៖*

  - *ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ*
  - *ការវាយតម្លៃបរិស្ថានបឋម និង*
  - *លិខិតអនុញ្ញាតផ្នែកបរិស្ថាន*

- *គោលបំណងនៃគន្លឹះនេះស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន គឺដើម្បីតម្រូវឱ្យគម្រោង និងសកម្មភាពអភិវឌ្ឍន៍ទាំងអស់ ដែលនឹងបង្កឱ្យមានផលប៉ះពាល់ដល់បរិស្ថាន ឬសង្គម ធ្វើការវាយតម្លៃបរិស្ថាន ។ កម្រិតនៃការវាយតម្លៃនឹងត្រូវកំណត់ ទៅតាមផលប៉ះពាល់ដែលអាចកើតឡើងចំពោះបរិស្ថាន ឬសង្គម ។*

- *វិញ្ញាបនបត្រឯកភាពលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននឹងត្រូវចេញ ហើយលិខិតអនុញ្ញាតដទៃទៀតនឹងត្រូវចេញ ដោយយោងទៅតាមវិញ្ញាបនបត្រឯកភាពលើការវាយតម្លៃផលប៉ះពាល់បរិស្ថាននោះ ។*
- *ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នឹងត្រូវតែតម្រូវសម្រាប់គម្រោង ឬសកម្មភាពទាំងអស់ ដែលទំនងជានឹងមានផលប៉ះពាល់គួរឱ្យកត់សម្គាល់លើបរិស្ថាន ឬសង្គម ។*
- *ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង នឹងត្រូវតែតម្រូវសម្រាប់គម្រោង ឬសកម្មភាពទាំងឡាយឡាយ ដែលអាចបង្កឱ្យមានផលប៉ះពាល់កម្រិតស្រាលទៅលើបរិស្ថាន និងសង្គម ។*
- *លិខិតអនុញ្ញាតផ្នែកបរិស្ថាននឹងត្រូវតែតម្រូវសម្រាប់គម្រោង ឬសកម្មភាពទាំងឡាយណា ដែលមិនតម្រូវឱ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬការវាយតម្លៃបរិស្ថានដំបូង ។ ការទាំងនឹងតម្រូវឱ្យមានការអនុញ្ញាត ដើម្បីធ្វើឱ្យប្រាកដថា គម្រោងនានាទំនងជានឹងមិនបង្កឱ្យមានភាពអន្តរាយ ឬការខូចខាតចំពោះ បរិស្ថាន ឬសង្គមនោះទេ ។*

## ជំពូកទី # – គោលដៅនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

## ជំពូកទី # – វិសាលភាពនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅកម្ពុជា

## ជំពូកទី # – គោលបំណងនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅកម្ពុជា

## ជំពូកទី # – ការអនុវត្តចំពោះគម្រោងអភិវឌ្ឍសាធារណៈ និងឯកជន

## ជំពូកទី # – ការអនុវត្តច្បាប់ចំពោះគម្រោងដែលមានស្រាប់

## ជំពូកទី # – ការចូលរួមជាសាធារណៈនៅក្នុងការវាយតម្លៃហេតុប៉ះពាល់បរិ-ស្ថាន

**Commented [M8]:** លក្ខណៈពិសេសនៃគម្រោងទាញយកពីបាតសមុទ្រ ( offshore projects ) គួរត្រូវពិចារណាដោយប្រុងប្រយ័ត្ន និងដាក់បញ្ចូលទៅក្នុងគន្លឹះស្តីពី ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន បើយោងតាមមតិយោបល់របស់ក្រុមហ៊ុន Kris Energy

**Commented [M9]:** ត្រូវពិចារណាអំឡុងពេលនៃសុពលភាពនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដោយធៀបនឹងអំឡុងពេលនៃគម្រោង បើយោងតាមមតិយោបល់របស់ក្រុមហ៊ុន Kris Energy

# ជំពូកទី # – ការទទួលខុសត្រូវរបស់ក្រសួងបរិស្ថាននៅក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

## មាត្រា #

មន្ត្រីអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃក្រសួងបរិស្ថាន មានសិទ្ធិ អំណាចដូចខាងក្រោម៖

១- ធ្វើអធិការកិច្ចតាមដាន និងត្រួតពិនិត្យការគោរពច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ ជាធរមាន គោលការណ៍ណែនាំនានា កិច្ចសន្យាការពារបរិស្ថាន ស្តង់ដារផែនការគ្រប់គ្រងបរិស្ថាន និងល័ក្ខខ័ណ្ឌតម្រូវផ្នែកបរិស្ថានដែលពាក់ព័ន្ធផ្សេងៗទៀត។ ក្នុងករណីចាំបាច់ មន្ត្រីអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន អាចបង្គាប់ឱ្យម្ចាស់គម្រោងផ្អាកសកម្មភាពមួយផ្នែក ឬទាំងស្រុងជាបណ្ដោះអាសន្ន ឬបិទទីតាំងជាបណ្តោះអាសន្ន ។

២- ពិនិត្យកំណត់ត្រា ឯកសារ ទិន្នន័យអេឡិចត្រូនិក ស្តីពីការគ្រប់គ្រងបរិស្ថាន និង កំណត់ត្រា ដទៃទៀត ស្តីពីគម្រោងអភិវឌ្ឍន៍ និងការប្រតិបត្តិគម្រោង ។

៣- ស្តាប់ និងធ្វើកំណត់ហេតុស្តាប់ចម្លើយរបស់កម្មករ និយោជិត តំណាងម្ចាស់គម្រោង ក៏ដូចជា បុគ្គលពាក់ព័ន្ធនានា ។

៤- បង្គាប់ឲ្យកម្មករ និយោជិត អភិបាល អ្នកតំណាងស្របច្បាប់ និងភ្នាក់ងារនៃគម្រោងអភិវឌ្ឍន៍ ផ្តល់នូវរាល់ព័ត៌មាន ឯកសារជាលាយលក្ខណ៍អក្សរ ផែនការក៏ដូចជាកំណត់ត្រា គ្រប់ប្រភេទដែលពាក់ព័ន្ធនឹងកិច្ចការគ្រប់គ្រងបរិស្ថានរបស់ម្ចាស់គម្រោង ។

៥- មានសិទ្ធិចុះឆែកឆេរទីតាំងគម្រោង និងចាប់យកវត្ថុតាង ក្នុងករណីដែលសង្ស័យថាមានអំពើល្មើសនឹងច្បាប់ ឬបទប្បញ្ញត្តិនានាស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬផែនការគ្រប់គ្រងបរិស្ថាន ។

៦- ជួបប្រជុំជាមួយប្រធានក្រុមប្រឹក្សាភិបាល តំណាងស្របច្បាប់ និងកម្មករនិយោជិតនៃគម្រោងយ៉ាងតិច ១ (មួយ) ឆ្នាំ ម្តង ដើម្បីធ្វើការវាយតម្លៃការអនុវត្តច្បាប់នេះ និងបទប្បញ្ញត្តិ ពាក់ព័ន្ធដទៃទៀត ។

៧- ធ្វើកំណត់ហេតុឆែកឆេរ និងចាប់យកវត្ថុតាងនានា ដើម្បីកសាងសំណុំរឿងនៃការប្រព្រឹត្តល្មើសនឹងច្បាប់នេះ ដើម្បីចាត់ការតាមនីតិវិធីជាធរមាន ។

## មាត្រា #

មន្ទីរបរិស្ថានរាជធានី ខេត្ត ចូលរួមអនុវត្តច្បាប់នេះ អនុលោមតាមច្បាប់ និងបទដ្ឋានគតិយុត្តិ ជាធរមាន ព្រមទាំងការចាត់តាំងរបស់ក្រសួងបរិស្ថាន ។

## ជំពូកទី # – ការចុះបញ្ជីអ្នកជំនាញការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

Commented [M10]: មានការផ្តល់យោបល់មួយចំនួនដែលលើកឡើងជាការស្នើឱ្យអ្នកជំនាញការអន្តរជាតិ មានសិទ្ធិរៀបចំរបាយការណ៍ EIA/IEE នៅក្នុងប្រទេសកម្ពុជា

**មាត្រា ២១.**

ទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានដែលជារូបវន្តបុគ្គល ឬនីតិបុគ្គល ត្រូវស្ថិតនៅក្រោម ការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន ។

ក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវមានសញ្ជាតិខ្មែរ និងមានប្រធានក្រុមការងារជាទីប្រឹក្សាដែលទទួលបាននីតិសម្បទាពីក្រសួងបរិស្ថាន ។

បុគ្គលជាទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានគ្រប់រូប ត្រូវចុះបញ្ជីនៅក្រសួងបរិស្ថានជាមុនសិន មុននឹងប្រកបវិជ្ជាជីវៈរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ជាមួយក្រុមហ៊ុនទីប្រឹក្សា។

វិញ្ញាបនបត្រនៃការចុះបញ្ជី ផ្តល់នីតិសម្បទាជាទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវមាន រយៈពេលសុពលភាពអតិបរិមា ៥ (ប្រាំ) ឆ្នាំ ហើយអាចបន្តសាជាថ្មីបាន ។

## ជំពូកទី # – កម្រិតនៃការវាយតម្លៃត្រូវរួមបញ្ចូលនូវការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬដំបូង ឬកិច្ចសន្យាការពារបរិស្ថាន

**មាត្រា #**

រាល់គម្រោងអភិវឌ្ឍន៍ ត្រូវធ្វើការវាយតម្លៃហេតុប៉ះពាល់ទៅលើបរិស្ថាន សេដ្ឋកិច្ច សង្គម សុខភាព និងវប្បធម៌ ដោយមានការឯកភាពពីក្រសួងបរិស្ថានជាមុនសិន មុននឹងបញ្ជូនទៅរាជរដ្ឋាភិបាលសម្រេច ។

រាល់ការចេញអាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតលើគម្រោងអភិវឌ្ឍន៍នានាដោយក្រសួង-ស្ថាប័នអនុម័តគម្រោងត្រូវធ្វើឡើងអនុលោមតាមលក្ខខណ្ឌដែលកំណត់នៅក្នុងលិខិត និងវិញ្ញាបនបត្រវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត ឬសេចក្តីសម្រេចនានាដែលផ្ទុយនឹងស្មារតីនៃបទប្បញ្ញត្តិនេះត្រូវទុកជាមោឃៈ ។

**មាត្រា #.**

ច្បាប់នេះមិនអនុវត្តចំពោះគម្រោងអភិវឌ្ឍន៍ ឬសកម្មភាពរបស់រដ្ឋ ដែលបានអនុម័តដោយរាជរដ្ឋាភិបាល ឬរដ្ឋសភា ហើយដែលចាត់ទុកជាគម្រោងចាំបាច់ និងបន្ទាន់ទាក់ទងនឹងសន្តិសុខជាតិ បូរណភាពទឹកដី អធិបតេយ្យជាតិ ឬការគ្រប់គ្រងគ្រោះមហន្តរាយ ។

**មាត្រា #.**

ក្រសួងបរិស្ថានត្រូវកំណត់ចំណាត់ថ្នាក់លើគម្រោងអភិវឌ្ឍន៍ ដើម្បីតម្រូវឱ្យម្ចាស់គម្រោងរៀបចំនូវឯកសារ ដូចខាងក្រោម ៖

១.របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ភ្ជាប់ជាមួយកិច្ចសន្យាការពារបរិស្ថាន ។

២.របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ភ្ជាប់ជាមួយកិច្ចសន្យាការពារបរិស្ថាន

៣.កិច្ចសន្យាការពារបរិស្ថាន ។

ប្រភេទគម្រោង ដែលតម្រូវឱ្យរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬកិច្ចសន្យាការពារបរិស្ថាន ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា #**

ក្រសួងបរិស្ថាន អាចកំណត់ចំណាត់ថ្នាក់គម្រោងបន្ថែមទៀត ដោយផ្អែកលើទំហំនៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ដែលត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

**មាត្រា #**

ក្នុងករណីដែលមានការផ្ទេរ ឬផ្លាស់ប្តូរម្ចាស់គម្រោង ដោយហេតុណាមួយ នោះលិខិតឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និង/ឬ ពេញលេញ ព្រមទាំងកិច្ចសន្យា និងល័ក្ខខ័ណ្ឌទាំងអស់ដែលចែងក្នុងវាក្យខណ្ឌនេះ ត្រូវផ្ទេរទៅម្ចាស់ថ្មី ដោយស្វ័យប្រវត្តិ ។ កិច្ចសន្យាផ្ទេរ ឬការផ្លាស់ប្តូរម្ចាស់គម្រោងមានសុពលភាពអនុវត្ត លុះត្រាតែការផ្ទេរ ឬការផ្លាស់ប្តូរនោះ ធ្វើឡើងបន្ទាប់ពីក្រសួងបរិស្ថាន ទទួលបានការជូនដំណឹងអំពីការផ្លាស់ប្តូរនោះ ។

**មាត្រា ១៦.**

របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ត្រូវធ្វើឡើងសម្រាប់៖

១.គម្រោងនានាដែលមានរៀបរាប់ក្នុងអនុក្រឹត្យ ឬ

២.គម្រោងនានា ដែលបានរៀបចំជាកិច្ចសន្យាការពារបរិស្ថាន ហើយក្រសួងបរិស្ថាន តម្រូវឲ្យធ្វើរបាការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ។

នៅពេលដែលគម្រោងស្នើឡើង ត្រូវធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង នោះម្ចាស់គម្រោងត្រូវសហការជាមួយក្រុមហ៊ុនទីប្រឹក្សា ដើម្បីរៀបចំសេចក្តីព្រាងល័ក្ខខ័ណ្ឌការងារដោយអនុលោមតាមបទប្បញ្ញត្តិ និងគោលការណ៍ណែនាំនានារបស់ក្រសួងបរិស្ថាន រួចដាក់សុំការអនុម័ត ជាស្ថាពរពីអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

ម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សា ត្រូវរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ផ្អែកលើល័ក្ខខ័ណ្ឌការងារដែលទទួលបានការឯកភាព ។

**មាត្រា #**

របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញត្រូវធ្វើឡើងសម្រាប់៖

១-គម្រោងដែលកំណត់ដោយអនុក្រឹត្យ ឬ

២-គម្រោងដែលទទួលបានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ហើយលទ្ធផលនៃការសិក្សានេះពិនិត្យឃើញថាមានការប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថាន និងសង្គម ហើយក្រសួង បរិស្ថានតម្រូវឱ្យមានការសិក្សារបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ។

នៅពេលដែលគម្រោងស្នើសុំ តម្រូវឲ្យធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ម្ចាស់គម្រោងត្រូវសហការជាមួយក្រុមហ៊ុនទីប្រឹក្សា ដើម្បីរៀបចំសេចក្តីព្រាងល័ក្ខខ័ណ្ឌការងារ ដោយអនុលោមតាមបទប្បញ្ញត្តិ និងគោលការណ៍ណែនាំនានារបស់ក្រសួងបរិស្ថាន រួចដាក់សុំការអនុម័តជាស្ថាពរពីអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

ម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សាត្រូវ រៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ផ្អែកលើល័ក្ខខ័ណ្ឌការងារដែលទទួលបានការឯកភាព ។

**មាត្រា #.**

កិច្ចសន្យាការពារបរិស្ថាន ត្រូវធ្វើឡើងសម្រាប់គម្រោងនានាដែលមានរៀបរាប់ក្នុងអនុក្រឹត្យ ឬគម្រោងដែលមានទំហំហេតុប៉ះពាល់អវិជ្ជមានដល់បរិស្ថាន និងសង្គមតិចតួច ។

នៅពេលដែលគម្រោងស្នើឡើងត្រូវធ្វើត្រឹមកិច្ចសន្យាការពារបរិស្ថាន នោះម្ចាស់គម្រោង ត្រូវចុះកិច្ចសន្យាការពារបរិស្ថាន ដោយត្រូវភ្ជាប់ជាមួយគោលការណ៍បច្ចេកទេស ជាអាទិ៍ ផែនការគាំពារបរិស្ថាន និងឯកសារពាក់ព័ន្ធ រួចដាក់សុំការអនុម័តជាស្ថាពរពីអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

គំរូកិច្ចសន្យាការពារបរិស្ថាន និងផែនការគាំពារបរិស្ថាន ត្រូវកំណត់ដោយក្រសួងបរិស្ថាន ។

## ជំពូកទី # – ការបង្កើតគណៈកម្មការត្រួតពិនិត្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

**មាត្រា #.**

រាល់គម្រោងអភិវឌ្ឍន៍នានា ដែលតម្រូវឲ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ចាំបាច់ត្រូវមានមតិបច្ចេកទេសរបស់គណៈកម្មការជំនាញត្រួតពិនិត្យ ។

គណៈកម្មការជំនាញ ត្រួតពិនិត្យនេះរួមមានសមាសភាពនៃមន្ត្រីមកពីក្រសួងបរិស្ថាន ក្រសួងស្ថាប័នពាក់ព័ន្ធ និងអ្នកជំនាញឯករាជ្យ ដែលមានគុណសម្បត្តិ និងបទពិសោធន៍សមស្រប ក្នុងការពិនិត្យរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ។ សមាជិកនៃគណកម្មការជំនាញត្រួតពិនិត្យនេះ អាចមានការប្រែប្រួលពីគម្រោងមួយទៅគម្រោងមួយតាមការជ្រើសរើសរបស់ក្រសួងបរិស្ថាន អាស្រ័យទៅតាមទិដ្ឋភាពបច្ចេកទេសនៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃការបង្កើតគណៈកម្មការជំនាញត្រួតពិនិត្យនេះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

សមាជិកនៃគណៈកម្មការជំនាញត្រួតពិនិត្យ ត្រូវបានទូទាត់ប្រាក់កម្រៃសម្រាប់ការបម្រើការងាររបស់ខ្លួន ដោយផ្អែកលើការព្រមព្រៀង រវាងក្រសួងបរិស្ថាន សមាជិកម្នាក់ៗ និងម្ចាស់គម្រោង ។

## ជំពូកទី # – តួនាទីរបស់គណៈកម្មការត្រួតពិនិត្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

## ជំពូកទី # – រយៈពេលសម្រាប់នីតិវិធីនៃការធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ និងដំបូង

**មាត្រា #**

ក្រសួងបរិស្ថានអាចធ្វើការកំណត់ ស្របតាមនីតិវិធីនេះ តែនៅក្រោយពេល ការវាយតម្លៃហេតុប៉ះពាល់ដំបូង ឬពេញលេញ ត្រូវបានដាក់បង្ហាញជាសាធារណៈ យ៉ាងហោចណាស់សម្រាប់អំឡុងពេល ដែលត្រូវបានកំណត់នៅក្នុងក្រមបរិស្ថាននេះ ។

សម្រាប់កិច្ចសន្យាការពារបរិស្ថាន អំឡុងពេលអប្បបរមាសម្រាប់ការដាក់បង្ហាញជាសាធារណៈ និងការផ្តល់មតិយោបល់គឺរយៈពេល ៣ សប្តាហ៍ ។

សម្រាប់របាយការណ៍វាយតម្លៃហេតុប៉ះពាល់ដំបូង អំឡុងពេលអប្បបរមា សម្រាប់ការដាក់បង្ហាញជាសាធារណៈ និងការផ្តល់មតិយោបល់គឺរយៈពេល ៦ សប្តាហ៍ ។

សម្រាប់របាយការណ៍វាយតម្លៃហេតុប៉ះពាល់ពេញលេញ អំឡុងពេលអប្បបរមាសម្រាប់ការដាក់បង្ហាញជាសាធារណៈ និងការផ្តល់មតិយោបល់គឺរយៈពេល ៨ សប្តាហ៍ ។

**មាត្រា #**

ក្រសួងបរិស្ថានមានរយៈពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ ដើម្បីពិនិត្យ ផ្តល់យោបល់ ឯកភាព បដិសេធ ឬតម្រូវឱ្យកែសម្រួល ឬកែតម្រូវ លើកិច្ចសន្យាការពារបរិស្ថាន និងផែនការគាំពារបរិស្ថាន។ រយៈពេលនេះគិតចាប់ពីកាលបរិច្ឆេទដែលខ្លួនទទួលបានពាក្យសុំពិនិត្យលើកិច្ចសន្យាការពារបរិស្ថាន ផែនការគាំពារបរិស្ថាន និងឯកសារពាក់ព័ន្ធ ។

**មាត្រា #**

ក្រសួងបរិស្ថានត្រូវពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូងក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទដែលខ្លួនទទួលបានរបាយការណ៍នោះ ។ រយៈពេល ៦០ (ហុកសិប) ថ្ងៃនេះ ត្រូវអស់សុពលភាព នៅពេលដែលក្រសួងបរិស្ថានបានផ្តល់យោបល់របស់ខ្លួន ទោះបីជាជាយោបល់នោះជាយោបល់បដិសេធ យោបល់ឯកភាព ឬជាយោបល់បង្គាប់ឱ្យមានការកែប្រែ ឬកែលម្អ របាយការណ៍ដែលខ្លួនពិនិត្យក៏ដោយ ។

រយៈពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ សម្រាប់ពិនិត្យ និងផ្តល់យោបល់ខាងលើ ជានិច្ចកាល ត្រូវចាប់ផ្តើមរាប់សារជាថ្មី នៅពេលដែលក្រសួងទទួលបានពាក្យស្នើសុំឱ្យពិនិត្យព្រមទាំងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ដែលម្ចាស់គម្រោងបានធ្វើការកែតម្រូវរួចជាស្ថាពរ ស្របតាមសេចក្តីបង្គាប់ ឬសេចក្តីណែនាំ ដែលក្រសួងបរិស្ថានបានផ្តល់ជូននាគ្រាមុនៗ ។

ម្ចាស់គម្រោង ត្រូវទទួលខុសត្រូវ ចំពោះព្យសនកម្មនានា ដែលបង្កឡើងដោយកំហុសរបស់ខ្លួនដែលបណ្តាលមកពីការយឺតយ៉ាវ ឬការខកខានមិនបានធ្វើការកែសម្រួលឱ្យត្រូវតាមសេចក្តីបង្គាប់ ឬសេចក្តីណែនាំខាងលើ ។

**មាត្រា ២៤**

ក្រសួងបរិស្ថានត្រូវពិនិត្យ និងផ្តល់យោបល់ លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ក្នុងរយៈពេល ៩០ (កៅសិប) ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទដែល

ខ្លួនទទួលបានរបាយការណ៍នោះ។ រយៈពេល៩០(កៅសិប)ថ្ងៃនេះ ត្រូវអស់សុពលភាព នៅពេលដែលក្រសួងបរិស្ថានបានផ្តល់យោបល់របស់ខ្លួន ទោះបីជាជាយោបល់នោះជាយោបល់បដិសេធ យោបល់ឯកភាព ឬ ជាយោបល់បង្គាប់ឱ្យមានការកែប្រែ ឬកែលម្អ របាយការណ៍ដែលខ្លួនពិនិត្យក៏ដោយ ។

រយៈពេល ៩០ (កៅសិប) ថ្ងៃ នៃថ្ងៃធ្វើការ សម្រាប់ពិនិត្យ និងផ្តល់យោបល់ខាងលើ ជានិច្ចកាលត្រូវចាប់ផ្តើមរាប់សារជាថ្មី នៅពេលដែលក្រសួងទទួលបានពាក្យស្នើសុំឱ្យពិនិត្យ ព្រមទាំងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលម្ចាស់គម្រោងបានធ្វើការកែតម្រូវរួចជាស្ថាពរ ស្របតាមសេចក្តីបង្គាប់ ឬណែនាំដែលក្រសួងបរិស្ថានបានផ្តល់ជូននាគ្រាមុនៗ ។

ម្ចាស់គម្រោង ត្រូវទទួលខុសត្រូវ ចំពោះព្យសនកម្មនានាដែលបង្កឡើងដោយកំហុសរបស់ខ្លួនដែលបណ្តាលមកពីការយឺតយ៉ាវ ឬការខកខានមិនបានធ្វើការកែសម្រួលឱ្យត្រូវតាមសេចក្តីបង្គាប់ ឬសេចក្តីណែនាំខាងលើ ។

## ជំពូកទី # – ការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន

## ជំពូកទី # – ការរៀបចំផែនការគ្រប់គ្រងបរិស្ថាន

### មាត្រា #

ផែនការគ្រប់គ្រងបរិស្ថានត្រូវរៀបចំដោយម្ចាស់គម្រោង ។

ផែនការគ្រប់គ្រងបរិស្ថាន ត្រូវដាក់បញ្ចូលល័ក្ខខ័ណ្ឌតម្រូវនៃការការពារ ការកាត់បន្ថយ ការអង្កេតតាមដាន និងការគ្រប់គ្រង ដែលបានកំណត់នៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ ។

ផែនការគ្រប់គ្រងបរិស្ថាន ត្រូវធ្វើបច្ចុប្បន្នភាពជាប្រចាំ ដោយអនុលោមតាមការវិវឌ្ឍន៍ជាក់ស្តែងនៃស្តង់ដារបរិស្ថាន ឬការអនុវត្តជាក់ស្តែងដែលទទួលស្គាល់ជាទូទៅក្នុងវិស័យនីមួយៗ ឬការប្រែប្រួលស្ថានភាពផ្សេងៗនៃគម្រោង ។

### មាត្រា #

រាល់គម្រោងអភិវឌ្ឍន៍ និងអ្នកប្រតិបត្តិការគម្រោង ត្រូវបង្កើត និងរក្សាប្រព័ន្ធគ្រប់គ្រងបរិស្ថាន ផ្ទៃក្នុងដែលត្រូវធានាឲ្យមាននូវនីតិវិធី និងវិធីសាស្ត្រអង្កេតតាមដានដោយខ្លួនឯង ដូចមានចែងក្នុងផែនការគ្រប់គ្រងបរិស្ថានរបស់ខ្លួន ។

ក្នុងករណីផលប៉ះពាល់បរិស្ថាន មានទំហំធំជាងផលប៉ះពាល់ដែលត្រូវបានប៉ាន់ប្រមាណនៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬផែនការគ្រប់គ្រងបរិស្ថាន

ក្រសួងបរិស្ថានតម្រូវឲ្យចាត់វិធានការកែតម្រូវផលប៉ះពាល់ភ្លាមៗ ឬកែតម្រូវផែនការគ្រប់គ្រងបរិស្ថាន ។

ផែនការគ្រប់គ្រងបរិស្ថានដែលបានកែតម្រូវរួច និងកម្មវិធីអង្កេតតាមដាន ត្រូវទទួលបានការឯកភាពពីក្រសួងបរិស្ថាន ។ រយៈពេលកំណត់ ដើម្បីធ្វើការកែតម្រូវ ឬកែលម្អជាថ្មីឡើងវិញ ត្រូវមានការព្រមព្រៀងជាលាយលក្ខណ៍អក្សរដោយភាគីពាក់ព័ន្ធ ។

ម្ចាស់គម្រោង ត្រូវរៀបចំរបាយការណ៍អង្កេតតាមដានបរិស្ថាន រៀងរាល់០៣ខែម្តង ហើយបញ្ជូនមកអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដើម្បីពិនិត្យ និងវាយតម្លៃ ។ អង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន មានសិទ្ធិចុះត្រួតពិនិត្យដល់កន្លែង និងផ្ទៀងផ្ទាត់លទ្ធផល នៃការអង្កេតតាមដានរបស់ម្ចាស់គម្រោង ។

**មាត្រា #**

អ្នកដែលទទួលរងផលប៉ះពាល់ដោយសារគម្រោង និងអ្នកពាក់ព័ន្ធនានា ត្រូវមានសិទ្ធិរាយការណ៍ពីបញ្ហា និងក្តីកង្វល់បរិស្ថាន និងសង្គម ជូនដល់ម្ចាស់គម្រោង និងដាក់បណ្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច ហើយបញ្ហាទាំងនោះត្រូវដោះស្រាយដោយអនុគណៈកម្មការថ្នាក់ក្រោមជាតិ និងអាចបន្តមកគណៈកម្មការអន្តរក្រសួង ដែលបង្កើតឡើងជាផ្នែកមួយនៃផែនការគ្រប់គ្រងបរិស្ថាន ។

អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវឆ្លើយតបចំពោះបណ្តឹង ឬញត្តិ ហើយដោះស្រាយបញ្ហា បរិស្ថាន និងសង្គម ដែលពាក់ព័ន្ធ តាមពេលវេលាកំណត់សមស្រប និងផ្តល់ព័ត៌មានដល់អ្នកពាក់ព័ន្ធតាមស្ថានភាពជាក់ស្តែង ។

បែបបទ និងនីតិវិធីនៃការដោះស្រាយបណ្តឹង ឬញត្តិនេះត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

## ជំពូកទី # – ការដាក់របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន

## ជំពូកទី # – ការពិចារណា និងការវាយតម្លៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន

**មាត្រា ២៥.**

ក្នុងអំឡុងពេលនៃការពិនិត្យ និងផ្តល់យោបល់ ក្រសួងបរិស្ថានត្រូវពិនិត្យ និងផ្តល់យោបល់របស់ខ្លួន ចំពោះរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញបន្ទាប់ពី៖

-ស្តាប់និងពិចារណាលើបទបង្ហាញ និងការការពារជាផ្លូវការរបស់ម្ចាស់គម្រោង និង ក្រុមហ៊ុនទីប្រឹក្សា

-ពិចារណាលើមតិយោបល់ របស់អ្នកដែលទទួលរងផលប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោល មតិសាធារណជនពាក់ព័ន្ធ និងសង្គមស៊ីវិល

-ពិចារណាមតិយោបល់របស់ក្រសួង ឬស្ថាប័នពាក់ព័ន្ធ និង

-ពិចារណាមតិរបស់គណៈកម្មការជំនាញត្រួតពិនិត្យដែលបានស្នើឡើង ។

ក្រសួងបរិស្ថានទទួលខុសត្រូវ ក្នុងការរៀបចំឱ្យមានដំណើរការចូលរួមជាសាធារណៈប្រកបដោយសមធម៌ ដោយអញ្ជើញតំណាងក្រសួង ឬស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី សង្គមស៊ីវិល និង អ្នកដែលទទួលរងការប៉ះពាល់ ឲ្យចូលរួមផ្តល់មតិយោបល់ចំពោះគម្រោងដែលបានស្នើឡើងនោះ ។

## ជំពូកទី # – ការកែលម្អរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន

**មាត្រា #**

ការផ្តល់យោបល់ឯកភាព ឬបដិសេធ ឬបង្គាប់ឱ្យមានការកែប្រែ ឬកែតម្រូវផ្សេងៗទៅលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ត្រូវធ្វើឡើងដោយពិចារណាលើ គុណសម្បត្តិ និងគុណវិបត្តិខាងផ្នែកបរិស្ថាន សេដ្ឋកិច្ច សង្គម និងវប្បធម៌ តាមរយៈការពិនិត្យជាអាទិ៍៖ វិសាលភាពនៃគម្រោង ទីតាំងភូមិសាស្រ្ត សក្តានុពលនៃហេតុប៉ះពាល់ លក្ខណៈពិសេសដទៃទៀតរបស់គម្រោងនីមួយៗ និងប្រសិទ្ធភាពនៃការអនុវត្តវិធានការគ្រប់គ្រង និង/ឬការពារគុណភាពបរិស្ថាន និងកាត់បន្ថយហេតុប៉ះពាល់ចំពោះសង្គម អនុលោមតាមកម្រិតវិវឌ្ឍន៍ នៃបច្ចេកវិជ្ជា និងវិទ្យាសាស្រ្ត ។

ក្នុងករណីក្រសួងបរិស្ថាន ផ្តល់យោបល់ឯកភាព លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ក្រសួងបរិស្ថានត្រូវចេញលិខិតនិងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃគម្រោងនោះដោយភ្ជាប់ជាមួយកិច្ចសន្យាការពារបរិស្ថាន។

ក្នុងករណី ក្រសួងបរិស្ថានបដិសេធលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ក្រសួងបរិស្ថានត្រូវបញ្ជាក់ពីហេតុផលនៃសេចក្តីសម្រេចរបស់ខ្លួន ។

ក្នុងករណីក្រសួងបរិស្ថាន ផ្តល់យោបល់បង្គាប់ឱ្យធ្វើការកែប្រែ ឬកែតម្រូវលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ នោះក្រសួងបរិស្ថានត្រូវភ្ជាប់ហេតុផល និងចង្អុលបង្ហាញដោយច្បាស់ៗ នូវចំណុចត្រូវកែប្រែ ឬកែតម្រូវ ។

**មាត្រា #**

មុនសម្រេចផ្តល់នូវលិខិត និងវិញ្ញាបនបត្រឯកភាព លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានលើគម្រោងអភិវឌ្ឍន៍ ដែលមានទីតាំងស្ថិតនៅតំបន់ ដែលមានជនជាតិដើមភាគតិចរស់នៅ ក្រសួងបរិស្ថាន សមាជិកនៃគណៈកម្មការជំនាញត្រួតពិនិត្យ ឬអ្នកពាក់ព័ន្ធក្នុងការចូលរួមក្នុងការសម្រេច ត្រូវធ្វើការយកចិត្តទុកដាក់ និងពិចារណាខ្ពស់ចំពោះគម្រោងនោះដើម្បីបញ្ចៀសផលប៉ះពាល់អវិជ្ជមាន ជាអាទិ៍ វប្បធម៌ ទំនៀមទំលាប់ ប្រពៃណី ការប្រកបរបរចិញ្ចឹមជីវិត ទ្រព្យសម្បត្តិ ដល់សហគមន៍ជនជាតិដើមភាគតិច ។

## ជំពូកទី # – ការឯកភាព ឬបដិសេធរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន

### មាត្រា #

ក្រសួងបរិស្ថាន ត្រូវធ្វើសេចក្តីសម្រេចបដិសេធ ឬសេចក្តីបង្គាប់ឱ្យមានការកែប្រែ ឬកែតម្រូវ ជាលាយលក្ខណ៍អក្សររបស់ខ្លួន រួមទាំងហេតុផល ឬល័ក្ខខ័ណ្ឌ និង/ឬ ចំណុចនានាដែលត្រូវកែប្រែ ឬកែតម្រូវ ជូនទៅម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សាសម្រាប់រៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

ក្រសួងបរិស្ថានត្រូវធ្វើលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន រួមទាំងកិច្ចសន្យាការពារបរិស្ថាន ជូនដល់ម្ចាស់គម្រោង និងក្រសួង ឬស្ថាប័នមានសមត្ថកិច្ច ពាក់ព័ន្ធជាអាទិ៍៖ ក្រសួង ឬស្ថាប័នអនុម័តគម្រោង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មន្ទីរបរិស្ថានរាជធានី ខេត្ត និងក្រុមប្រឹក្សាឃុំ-សង្កាត់ពាក់ព័ន្ធ។

## ជំពូកទី # – ការផ្តល់លិខិតឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន

## ជំពូកទី # – ការហាមឃាត់សកម្មភាពគម្រោងដែលគ្មានលិខិតឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន

### មាត្រា #

ម្ចាស់គម្រោងមិនត្រូវចាប់ផ្តើមសកម្មភាពសាងសង់ ឬប្រតិបត្តិការគម្រោង មុនពេលទទួលបានលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានឡើយ ។ ក្នុងករណីដែលគម្រោងអភិវឌ្ឍន៍គ្មានលិខិត និងវិញ្ញាបនបត្រ ឯកភាពលើរបាយ

ការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ក្រសួងបរិស្ថានមានសិទ្ធិសម្រេចផ្អាកសកម្មភាពសាងសង់ ឬប្រតិបត្តិការគម្រោងទាំងស្រុង ។

រាល់កិច្ចព្រមព្រៀងសម្បទាន ដែលផ្តល់ជូនដោយរាជរដ្ឋាភិបាលកម្ពុជាទាំងថ្នាក់ជាតិ និងថ្នាក់រាជធានី ខេត្ត ត្រូវមានលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានជាផ្លូវការដោយភ្ជាប់ជាមួយកិច្ចសន្យាការពារបរិស្ថាន ។

**មាត្រា #**

លិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន មានសុពលភាព សម្រាប់រយៈពេលវដ្តនៃគម្រោង ។ ក្នុងករណីក្រសួងបរិស្ថានពិនិត្យឃើញថាមានការផ្លាស់ប្តូរផែនការមេ ឬ/និង របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ លែងមានលក្ខណៈសមស្រប ឬមិនមានប្រសិទ្ធិភាពក្នុងការអនុវត្តវិធានការកាត់បន្ថយផលប៉ះពាល់ ក្រសួងបរិស្ថានមានសិទ្ធិតម្រូវឱ្យម្ចាស់គម្រោង រៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានឡើងវិញ ឬ/និង ធ្វើបច្ចុប្បន្នភាព របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដើម្បីទទួលបានជាថ្មីនូវលិខិត និងវិញ្ញាបនបត្រឯកភាពលើ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន តាមលក្ខខណ្ឌកំណត់ដោយក្រសួងបរិស្ថាន ។

## ជំពូកទី # – គម្រោងដែលមានស្រាប់

**មាត្រា ៣១ #**

ក្រសួងបរិស្ថានត្រូវពិគ្រោះយោបល់ជាមួយក្រសួង ឬស្ថាប័នពាក់ព័ន្ធ ត្រូវរៀបចំគោលការណ៍ណែនាំផ្អែកលើការចាត់ថ្នាក់គម្រោងសម្រាប់ប្រភេទគម្រោង ដែលមិនបានអនុវត្តការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដើម្បីតម្រូវឲ្យម្ចាស់គម្រោងទាំងនោះ រៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ចំពោះគម្រោងដែលមានស្រាប់ និងកំពុងដំណើរការ។

គោលការណ៍ណែនាំត្រូវបោះពុម្ពផ្សព្វផ្សាយក្នុងរយៈពេល ៣ (បី) ខែ គិតចាប់ពីពេលក្រសួងបរិស្ថានសម្រេចលើគោលការណ៍ណែនាំទាំងនេះ ។

ម្ចាស់គម្រោងត្រូវសហការជាមួយក្រុមហ៊ុនទីប្រឹក្សា រៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឲ្យបានចប់ ហើយត្រូវដាក់ ឯកសារទាំងនេះ ទៅក្រសួងបរិស្ថានដើម្បីពិនិត្យ ផ្តល់យោបល់ ក្នុងរយៈពេលកំណត់ដោយក្រសួងបរិស្ថាន ។

ក្រសួងបរិស្ថានត្រូវពិនិត្យ ផ្តល់យោបល់ និងសម្រេចលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ដោយយោងទៅតាមបទប្បញ្ញត្តិនៃក្រមនេះ ។

**Commented [M11]:** ការបញ្ជាក់ដែលអាចធ្វើឡើង សម្រាប់គម្រោងដែលមានស្រាប់ ជាមួយនឹង EIA ដែលមានស្រាប់ និងអាជ្ញាប័ណ្ណសម្រាប់ប្រតិបត្តិការ យោងតាមយោបល់របស់ Kris Energy

**Commented [M12]:** គម្រោងដែលត្រូវបានគ្រោង ឬដែលមានស្រាប់ ដែលបានបំពេញ ដំណើរការ EIA និងដំណើរការឯកភាពរបស់រដ្ឋាភិបាល មិនតម្រូវឱ្យមានការវាយតម្លៃបន្ថែមទៀតទេ ។ គម្រោងដែលមានស្រាប់ទាំងអស់ នឹងត្រូវតម្រូវឱ្យអនុលោមតាមក្រមបរិស្ថាន និងត្រូវទទួលរងការទណ្ឌកម្មសមរម្យ ប្រសិនបើគម្រោងបង្កការខូចខាតដល់បរិស្ថាន ឬ សង្គម ។

## ជំពូកទី # – បញ្ហាដែលត្រូវធ្វើការពិចារណា

### មាត្រា #

## ជំពូកទី # – ការវាយតម្លៃបណ្តុំនៃហេតុប៉ះពាល់

### មាត្រា #

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ត្រូវវិភាគនិងវាយតម្លៃពីបណ្តុំនៃផលប៉ះពាល់ ដែលបង្កឡើងដោយគម្រោងដែលមានស្រាប់ និងគម្រោងក្នុងពេលអនាគត នៅជុំវិញនៃទីតាំងគម្រោងទាំងនោះ ដែលអាចបង្កើតឲ្យមានផលប៉ះពាល់គួរឱ្យកត់សម្គាល់ ដល់បរិស្ថាន ឬសង្គម ។

នៅក្នុងរបាយការណ៍វាយតម្លៃបណ្តុំនៃផលប៉ះពាល់ ម្ចាស់គម្រោងត្រូវវាយតម្លៃសមត្ថភាពនៃធនធានរូបសាស្ត្រ ធនធានជីវសាស្ត្រ និងធនធានសេដ្ឋកិច្ចសង្គម ដើម្បីគិតគូរអំពីផលប៉ះពាល់បន្ថែម ផ្អែកលើកត្តាពេលវេលា ស្ថានភាពភូមិសាស្ត្រ និងសកម្មភាពរបស់គម្រោងនានាដែលនៅជុំវិញទីតាំងគម្រោង ។

ម្ចាស់គម្រោងត្រូវពិចារណាអំពី ជម្រើសនៃវិធានការកាត់បន្ថយបណ្តុំនៃផលប៉ះពាល់ផ្សេងៗ ដើម្បីកាត់បន្ថយ ឬបញ្ចៀស បណ្តុំនៃផលប៉ះពាល់ដែលគួរឱ្យកត់សម្គាល់ទាំងនោះ ។

## ជំពូកទី # – ការវាយតម្លៃហេតុប៉ះពាល់សុខភាព

### មាត្រា #

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ ត្រូវរាប់បញ្ចូលនូវការវាយតម្លៃហេតុប៉ះពាល់សុខភាព ដែលមានជាអាទិ៍៖

-ទិន្នន័យមូលដ្ឋាន ស្តីពីសុខភាពនៅក្នុងតំបន់គម្រោង និងរបស់ប្រជាជនដែលរងផលប៉ះពាល់

-ការពិពណ៌នា អំពីផលប៉ះពាល់នៃគម្រោងដែលអាចមាន ដោយសារការសាងសង់ លំហូរប្រជាជន និងការផ្លាស់ប្តូរចំពោះបរិស្ថាន

-វិធានការកាត់បន្ថយផលប៉ះពាល់ ដើម្បីកាត់បន្ថយ ឬលុបបំបាត់ផលប៉ះពាល់អវិជ្ជមាននៃគម្រោង និងវិធានការដែលត្រូវដាក់ឲ្យអនុវត្តដោយម្ចាស់គម្រោង ដើម្បីកែលម្អសុខភាពរបស់សហគមន៍មូលដ្ឋាន

-បញ្ហានានាទាក់ទងនឹងការអង្កេតតាមដានសុខភាព និងការគ្រប់គ្រងផលប៉ះពាល់ដែលនៅសល់ក្នុងរយៈពេលខ្លី និងវែង សម្រាប់គម្រោង ។

**មាត្រា #**

ក្នុងការវាយតម្លៃហេតុប៉ះពាល់សុខភាព ម្ចាស់គម្រោងត្រូវ៖

-លើកផែនការគ្រប់គ្រងសុវត្ថិភាព និងសុខភាព ជាផ្នែកមួយនៃការវាយតម្លៃហេតុប៉ះពាល់សុខភាព សម្រាប់បរិស្ថានការងារ ដោយវិភាគពីហានិភ័យដែលពាក់ព័ន្ធ និងប្រភេទនៃកត្តាគ្រោះថ្នាក់ក្នុងទីតាំងគម្រោង ជាអាទិ៍ កត្តាគ្រោះថ្នាក់ផ្នែករូបសាស្ត្រ-គីមីសាស្ត្រ ជីវសាស្ត្រ និងវិទ្យុសកម្ម ។

-កំណត់ និងវាយតម្លៃពីគ្រោះហានិភ័យ និងសក្ដានុពលនៃផលប៉ះពាល់ទៅលើសុវត្ថិភាព និងសុខភាព របស់សហគមន៍ក្នុងដំណាក់កាលរចនាគម្រោង សាងសង់គម្រោងប្រតិបត្តិគម្រោង និងបញ្ចប់គម្រោង ព្រមទាំងលើកវិធានការការពារ និងផែនការគ្រប់គ្រងផលប៉ះពាល់នៅក្នុងដំណាក់កាលទាំងនេះ ។

## ជំពូកទី # – ការគ្រប់គ្រង និងការអង្កេតតាមដានបរិស្ថាន

**មាត្រា #**

អង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងមន្ទីរបរិស្ថានរាជធានី ខេត្ត ជាអាជ្ញាធរត្រួតពិនិត្យលើផែនការគ្រប់គ្រងបរិស្ថាន និងអង្កេតតាមដានសកម្មភាពអនុវត្តផែនការគ្រប់គ្រងបរិស្ថានរបស់ម្ចាស់គម្រោង ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី និងអ្នកពាក់ព័ន្ធ ។

## ជំពូកទី # – ការផ្តល់ព័ត៌មាន

## ជំពូកទី # – លក្ខខណ្ឌតម្រូវនានានៃរបាយការណ៍

**មាត្រា #**

គម្រោងអភិវឌ្ឍន៍នីមួយៗត្រូវរៀបចំរបាយការណ៍អង្កេតតាមដានបរិស្ថាននៃគម្រោងដូចតទៅ៖

-របាយការណ៍រៀងរាល់ ០៣ (បី) ខែ ដែលរាយកាណ៍ពីលទ្ធផលទាំងអស់នៃការអង្កេតតាមដាន និងការគ្រប់គ្រងបរិស្ថាន ដែលត្រូវបញ្ជូនទៅអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

-ក្នុងរយ:ពេល ០៣ (បី) ខែ បន្ទាប់ពីបញ្ចប់ឆ្នាំហិរញ្ញវត្ថុនីមួយៗ ម្ចាស់គម្រោងត្រូវរៀបចំ និងបញ្ជូនរបាយការណ៍ប្រចាំឆ្នាំ ដែលដាក់បញ្ចូលមតិយោបល់របស់សវនករស្តីពីបរិស្ថាន

-ផ្តល់សំណៅរបាយការណ៍បរិស្ថានប្រចាំឆ្នាំ នៃគម្រោងដល់សាធារណជនតាមការ ស្នើសុំដោយឥតគិតថ្លៃ

-ផ្តល់សំណៅអេឡិចត្រូនិក ដែលត្រូវបង្ហោះលើគេហទំព័រជាសាធារណ: របស់ក្រសួង បរិស្ថាន និងដោយម្ចាស់គម្រោង នៅលើគេហទំព័រសាធារណ:មួយ ។

**មាត្រា #**

គម្រោងអភិវឌ្ឍន៍ ដែលមានលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវបញ្ជូនរបាយការណ៍ប្រចាំត្រីមាស និងប្រចាំឆមាស ទៅអង្គភាពវាយតម្លៃហេតុប៉ះពាល់ បរិស្ថានទាក់ទងនឹងការអង្កេតតាមដាន និងការគ្រប់គ្រងបរិស្ថានរបស់ខ្លួន ។

ម្ចាស់គម្រោងមានកាតព្វកិច្ចត្រូវរាយការណ៍ភ្លាមៗ អំពីបញ្ហាបរិស្ថានសំខាន់ដល់អាជ្ញាធរដែលពាក់ព័ន្ធ និងអាជ្ញាធរមានសមត្ថកិច្ច និងដល់សាធារណជន ដើម្បីជៀសវាងផលប៉ះពាល់អវិជ្ជមានមកលើបរិស្ថាន ឬសង្គម ។

ម្ចាស់គម្រោង ត្រូវផ្តល់ព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រងបរិស្ថាននៃគម្រោង ដល់ក្រសួងបរិស្ថាន តាមការស្នើសុំរបស់ក្រសួងបរិស្ថាន ។

## ជំពូកទី # – ថ្លៃសេវា និងបន្ទុកផ្សេងៗ

**មាត្រា #**

ម្ចាស់គម្រោង ត្រូវទទួលរ៉ាប់រងបង់រាល់ការចំណាយទាំងអស់ ក្នុងការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ សេវាសម្រាប់ចាត់ថ្នាក់គម្រោង សេវាសម្រាប់កំណត់លើវិសាលភាពនៃការសិក្សា និងក្នុងការចំណាយលើកិច្ចដំណើរការចូលរួមជាសាធារណ: សេវាសម្រាប់ការពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍របស់ក្រសួងបរិស្ថាន សេវាពិនិត្យរបាយការណ៍អង្កេតតាមដានបរិស្ថាន រួមទាំងគណ:កម្មការជំនាញត្រួតពិនិត្យ ។

**មាត្រា #**

ម្ចាស់គម្រោងត្រូវទទួលរ៉ាប់រង ក្នុងការបង់ថ្លៃចំណាយលើការរៀបចំ និងការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន និងផែនការអង្កេតតាមដានបរិស្ថាន និងថ្លៃចំណាយលើការអនុវត្ត និងការអង្កេតតាមដានវិធានការកាត់បន្ថយផលប៉ះពាល់បរិស្ថាននិងសង្គម ដូចមានចែងក្នុងផែនការគ្រប់គ្រងបរិស្ថាន និងផែនការអភិវឌ្ឍន៍សង្គម ។

ម្ចាស់គម្រោង ត្រូវមានថវិកាតម្កល់ ឬថវិកាធានារ៉ាប់រង សម្រាប់គ្រប់គ្រងគ្រោះហានិភ័យនានា ផ្នែកបរិស្ថាន និងសង្គម ដែលត្រូវកំណត់ដោយក្រសួងបរិស្ថាន ។

**មាត្រា #**

ថវិកាលំអិតអំពីការប៉ាន់ស្មាននៃការចំណាយ លើវិធានការកាត់បន្ថយផលប៉ះពាល់បរិស្ថានដែលត្រូវដាក់បញ្ចូលទៅក្នុងផែនការគ្រប់គ្រងបរិស្ថាន ត្រូវទទួលរ៉ាប់រងដោយម្ចាស់គម្រោង ។

ថ្លៃចំណាយលើការផ្សព្វផ្សាយឯកសារជាសាធារណៈ រាប់ទាំងគេហទំព័រ ដូចមានចែងក្នុងមាត្រា ៩០ នៃច្បាប់នេះ ត្រូវទទួលរ៉ាប់រងដោយម្ចាស់គម្រោង ។

ថ្លៃចំណាយទាំងអស់ក្នុងការកែតម្រូវ ឬកែលម្អវិធានការកាត់បន្ថយផលប៉ះពាល់ និងកម្មវិធីអង្កេតតាមដានគម្រោង ដូចមានចែងក្នុងមាត្រា ៩៣ នៃច្បាប់នេះ ត្រូវទទួលរ៉ាប់រងដោយម្ចាស់គម្រោង ។

ថ្លៃចំណាយទាំងអស់ ក្នុងការដោះស្រាយវិវាទពាក់ព័ន្ធនឹង ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ទាំងតាមប្រព័ន្ធតុលាការ និងក្រៅប្រព័ន្ធតុលាការ ដូចមានចែងក្នុងមាត្រា ៦៥ នៃច្បាប់នេះ ជាបន្ទុករបស់ម្ចាស់គម្រោង ។

ថ្លៃសេវា និងបន្ទុកផ្សេងៗ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា #**

នៅពេលម្ចាស់គម្រោងដាក់ពាក្យសុំពិនិត្យ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ក្រសួងបរិស្ថានមានភារកិច្ចប្រមូលថ្លៃ និងបន្ទុកសេវា ដូចមានចែងនៅក្នុងប្រកាសអន្តរក្រសួងរវាងក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ដីពីការបង់ថ្លៃសេវាការងារសម្រាប់ការពិនិត្យរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

**មាត្រា #**

ម្ចាស់គម្រោងត្រូវបង់សេវាពិនិត្យលើ របាយការណ៍អង្កេតតាមដានបរិស្ថានទៅឱ្យក្រសួងបរិស្ថាន ដើម្បីផ្តល់លទ្ធភាពដល់ក្រសួងបរិស្ថានក្នុងការអនុវត្តតួនាទីរបស់ខ្លួន ក្នុងការត្រួតពិនិត្យរបាយការណ៍តាមដានត្រួតពិនិត្យ ក៏ដូចជាឆ្លើយតបចំពោះ សំណើឱ្យមានការស៊ើបអង្កេតលើបណ្តឹងបរិស្ថាន និងក្នុងការអនុវត្តការតាមដានត្រួតពិនិត្យ លើការអនុលោមតាមច្បាប់ជាប្រចាំ ទាំងនៅក្នុងអំឡុងពេលនៃដំណាក់សាងសង់ និងដំណាក់កាលប្រតិបត្តិការគម្រោង។

**មាត្រា #**

មូលនិធិបរិស្ថាន និងសង្គមត្រូវបានបង្កើតឡើងដោយក្រសួងបរិស្ថាន ដើម្បីផ្តល់ហិរញ្ញប្បទានដល់ការស្តារបរិស្ថាន អភិរក្សជីវៈចម្រុះ និងការអភិវឌ្ឍន៍សង្គមនៅក្នុង និងជុំវិញតំបន់ដែលគម្រោងតាំងនៅ ។

**មាត្រា #**

ម្ចាស់គម្រោងត្រូវបង់មូលនិធិទាយជ្ជទានបរិស្ថាន តាមការព្រមព្រៀងគ្នារវាងក្រសួងបរិស្ថាន និងម្ចាស់គម្រោង ជារៀងរាល់ឆ្នាំរហូតដល់បញ្ចប់អាជីវកម្ម ដោយផ្អែកលើប្រភេទ និងទំហំនៃគម្រោងអភិវឌ្ឍន៍។

## គន្ថីទី ៥ – ការបង្កើតផែនការបរិស្ថាន និងធនធានធម្មជាតិថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងថ្នាក់មូលដ្ឋាន

Commented [RH13]: ដោយ តេង រិទ្ធីនី

- *គន្ថីនេះនឹងកំណត់អំពីនីតិវិធីសម្រាប់ការអនុម័តទទួលយកនូវផែនការបរិស្ថាន និងធនធានធម្មជាតិថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងថ្នាក់មូលដ្ឋាន ។ ផែនការទាំងនេះនឹងត្រូវរៀបចំសម្រាប់ការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ ដែលរួមបញ្ចូលបញ្ហាសន្តិសុខអាហារនិងទឹក និងការផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មរ៉ែជាតុដែលទាក់ទិន*
- *គន្ថីនេះនឹងបង្កើតឱ្យមានដំណើរការផែនទីមួយ (One Map Process) ដើម្បីតម្រូវឱ្យមានទិន្នន័យជាតាបេស (database) នៃព័ត៌មានភូមិសាស្ត្របរិស្ថានថ្នាក់ជាតិរួមតែមួយ ដោយមានការបើកចំហរ និងនិងកាតព្វកិច្ចនៃការចែករំលែកទិន្នន័យរវាងក្រសួង និងសាធារណៈជនទូទៅ ។ ដំណើរការនេះនឹងត្រូវប្រើប្រាស់ក្នុងការបង្កើតផែនការជាតិស្តីពីបរិស្ថាន និងធនធានធម្មជាតិ ។*

Commented [RH14]: ដោយ Andeol Cadin ផ្តល់យោបល់

- *គន្លឹះនេះនឹងចែងលម្អិតអំពីនីតិវិធីសម្រាប់ការបង្កើតនូវផែនការជាតិស្តីពីដីធ្លី និងធនធានធម្មជាតិ ដែលក្នុងនោះ ផែនការតំបន់ និងមូលដ្ឋាន នឹងត្រូវធ្វើឡើង និងយោងទៅលើគន្លឹះទី ៣ ស្តីពីការចូលរួមជាសាធារណៈ និងការទទួលបានព័ត៌មានបរិស្ថាន។ ផែនការជាតិនឹងចែងយ៉ាងច្បាស់លាស់អំពីទិសដៅជាយុទ្ធសាស្ត្រ និងគោលនយោបាយ ។ ផែនការថ្នាក់ក្រោមជាតិនឹងចែងអំពីវិធានការដាក់លាក់ ក្នុងការអនុវត្តគោលបំណងថ្នាក់ជាតិទាំងនេះ ។*

- *ជម្រើស១ គឺត្រូវព្យាយាមអនុម័តយកនូវវិធីសាស្ត្រតែមួយ សម្រាប់ការធ្វើ និងការឯកភាពលើផែនការគ្រប់គ្រង សម្រាប់កិច្ចការពារ និងការគ្រប់គ្រង (រួមបញ្ចូល ការធ្វើអាជីវកម្ម) ក្នុងតំបន់បេតិកភ័ណ្ឌ តំបន់ការពារដែនសមុទ្រ និងដែនដីគោក និងផែនគ្រប់គ្រងសម្រាប់ប្រភេទ (សត្វ ឬរុក្ខជាតិ) ដែលទទួលរងការគម្រាមកំហែង និងជិតផុតពូជ ។*

## ជំពូកទី # – ការបង្កើតដំណើរការផែនទីមួយថ្នាក់ជាតិ ធាតុផ្សំនៃផែនទីមួយ តួនាទីនានារបស់រដ្ឋាភិបាលនិងសង្គមស៊ីវិលក្នុងដំណើរការផែនទីមួយ

## ជំពូកទី # – ការបង្កើតផែនការជាតិគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ

## ជំពូកទី # – ការតែងតាំងគណៈកម្មការដើម្បីរៀបចំផែនការជាតិគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ

## ជំពូកទី # – សេចក្តីព្រាងផែនការជាតិគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ ដែលត្រូវរៀបចំ ដោយមានការចូលរួមជាសាធារណៈ

## ជំពូកទី # – ការរៀបចំ និងការឯកភាពលើផែនការជាតិគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ ថ្នាក់ក្រោមជាតិ និងថ្នាក់មូលដ្ឋាន

## ជំពូកទី # – ការបង្កើតនូវទិន្នន័យជាតាបេសថ្នាក់ជាតិស្តីពីព័ត៌មានភូមិ-សាស្ត្រដីធ្លី និងធនធាននានា

## ជំពូកទី # – ទិន្នន័យជាតាបេសដែលត្រូវដាក់បង្ហាញជាសាធារណៈ

# ជំពូកទី # – ទិន្នន័យជាតាបេសដែលត្រូវប្រើប្រាស់ដើម្បីរៀបចំផែនការថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងថ្នាក់មូលដ្ឋាន

## គន្លឹទី ៦– ការគ្រប់គ្រង និងការរៀបចំផែនការប្រើប្រាស់ដីទីក្រុង

Commented [RH15]: បញ្ចូលគ្នាជាមួយគន្លឹ ១១ ដោយក្រុម១ ក្នុងសិក្ខាសាលាថ្ងៃទី៦ ខែមេសា

- *គន្លឹនេះនឹងពិនិត្យទៅលើការរៀបចំផែនការប្រើប្រាស់ដីសម្រាប់តំបន់ទីប្រជុំជន។ វានឹងចែងអំពីការបង្កើតផែនការបែងចែកតំបន់ និងការធ្វើចំណាត់ថ្នាក់ដីសម្រាប់តំបន់ទីក្រុងឬទីប្រជុំជន។ វានឹងចែងផងដែរអំពីដំណើរការនៃឯកភាពលើការអភិវឌ្ឍន៍ក្នុងតំបន់ទីក្រុងឬទីប្រជុំជន ដោយស្របទៅតាមបំណែងចែកតំបន់សមរម្យ ។ ការនេះអាចតម្រូវឱ្យមានការពិនិត្យសារឡើងវិញនូវច្បាប់ស្តីពីការគ្រប់គ្រងដែនដី នគរូបនីយកម្ម និងសំណង់ ឆ្នាំ១៩៩៤ ។*

- *តំបន់ទីក្រុងឬទីប្រជុំជន និងការអភិវឌ្ឍន៍ទីប្រជុំជនឬទីក្រុងនានា បង្កើតនូវបន្ទុកជាច្រើនគួរឱ្យកត់សម្គាល់មួយទៅលើបរិស្ថាន និងសហគមន៍ ។ មានការស្នើឱ្យមានចែងអំពីចំណុចនេះនៅក្នុងគន្លឹដាច់ដោយឡែកពីគ្នា ក្នុងគោលបំណងផ្តោតទៅលើការលើកកម្ពស់នូវការអភិវឌ្ឍន៍ទីក្រុងឬទីប្រជុំជនប្រកបដោយចីរភាព។*

- *គន្លឹនេះនឹងបង្កើតនូវនីតិវិធីសម្រាប់ការធ្វើចំណាត់ថ្នាក់ដីថាជាដីទីក្រុងឬទីប្រជុំជន និងការកំណត់តំបន់ដីទីក្រុងឬទីប្រជុំជន ថាជាតំបន់សម្រាប់សាងសង់លំនៅដ្ឋាន តំបន់ពាណិជ្ជកម្ម និងតំបន់ពាក់ព័ន្ធដទៃទៀត។ វានឹងចែងអំពីការណែនាំសម្រាប់ការអភិវឌ្ឍន៍ទីក្រុងប្រកបដោយចីរភាព ស្របទៅតាមគោលការណ៍នៃការរៀបចំផែនការនៃការអនុវត្តល្អបំផុត ។ ការនេះនឹងប្រើប្រាស់ដំណើរការផែនទី១ដែលមានចែងនៅក្នុងគន្លឹទី៥ ។*

- *គន្លឹនេះនឹងចែងផងដែរនូវលក្ខខណ្ឌតម្រូវជាអប្បបរិមាសម្រាប់ការគ្រប់គ្រងដីទីក្រុងឬទីប្រជុំជន រួមបញ្ចូលបទប្បញ្ញត្តិអំពីផែនការដែលទាក់ទងនឹង ទឹក ថាមពល ការគ្រប់គ្រងទឹកជន់ដែលបណ្តាលមកពីភ្លៀង ព្រមទាំង ចរាចរ សំឡេងរំខាន និងការសាងសង់។*

- *តួនាទីរបស់អាជ្ញាធរផ្សេងៗ ក្នុងការរៀបចំផែនការ និងការគ្រប់គ្រងការប្រើប្រាស់ដី នឹងមានចែងនៅក្នុងច្បាប់នេះ ដោយយោងទៅកាន់ គន្លឹទី ២ ។*

- *គន្លឹនេះនឹងមានចែងអំពីលក្ខខណ្ឌតម្រូវជាក់លាក់ សម្រាប់ការចូលរួមជាសាធារណៈ ដោយយោងទៅកាន់គន្លឹទី៣ ។*

- *គន្លឹនេះនឹងលើកឡើងពីលំនៅដ្ឋានសង្គម*

ជំពូកទី # – ការបង្កើតនូវដំណើរការនៃការកំណត់តំបន់ដោយមានតម្លាភាពនៅកម្រិតក្រុង និងកម្រិតមូលដ្ឋាន រួមបញ្ចូល ការកំណត់ពេលវេលា វិសាលភាព និងអ្នកពាក់ព័ន្ធ ដែលត្រូវចូលរួម និងវិធីសាស្រ្ត

ជំពូកទី # – ការធ្វើចំណាត់ថ្នាក់ដីក្នុងតំបន់ទីក្រុង ឬទីប្រជុំជន

ជំពូកទី # – ស្តង់ដារអប្បបរមានៃផែនការកំណត់តំបន់ក្នុងទីក្រុង ឬទីប្រជុំជន រួមបញ្ចូលនូវលក្ខខណ្ឌសម្រាប់ ការរៀបចំ និងសហអត្ថិភាពតំបន់ឧស្សាហកម្ម ពាណិជ្ជកម្ម និងរស់នៅ

ជំពូកទី # –តំបន់ទ្រនាប់ និងការទប់ស្កាត់ការឈ្លានពានការប្រើប្រាស់ដែលមិនស្របគ្នា

ជំពូកទី # – លក្ខខណ្ឌតម្រូវនៃហេដ្ឋារចនាសម្ព័ន្ធនៃទីក្រុង ឬទីប្រជុំជន

ជំពូកទី # – ការដឹកជញ្ជូនសាធារណៈ ផ្លូវសម្រាប់ជិះកង់ ការកែច្នៃ ការប្រើប្រាស់ឡើងវិញ ការគ្រប់គ្រងសំណល់ ការថែទាំលំហបៃតងនៃទីក្រុង ឬទីប្រជុំជនដោយរួមបញ្ចូលនូវភាពច្បាស់លាស់ស្តីពីតួនាទី និងទំនួលខុសត្រូវនៃលំដាប់ថ្នាក់ផ្សេងៗនៃអាជ្ញាធរ

ជំពូកទី # – លក្ខខណ្ឌតម្រូវពិសេសសម្រាប់ការសាងសង់ (ឧទាហរណ៏៖ ការរៀបចំទុកឱ្យមានទីលំហ លក្ខខណ្ឌតម្រូវសម្រាប់ទីចំណតយានយន្ត ស្តង់ដារប្រសិទ្ធផលនៃថាមពល)ដោយធ្វើការដោះស្រាយទៅលើការកំណត់ទីចំណតជាអប្បបរមា  ទីលំហរត្រៀមសម្រាប់ជាតម្រូវការក្នុងការអភិវឌ្ឍន៍ទីក្រុង បញ្ហាក្នុងការគ្រប់គ្រងលំហូរចរាចរ  ការដឹកជញ្ជូនសាធារណៈ...។ល។

ជំពូកទី # – បទប្បញ្ញត្តិផ្សេងទៀតដែលទាក់ទងនឹងវិស័យឯកជន

ជំពូកទី # – ស្តង់ដារ នៃការបំភាយឧស្ម័ន(អ៊ីមីស្យុង)នៃយានយន្ត

ជំពូកទី # – ប្រព័ន្ធថ្មីនៃសិទ្ធិកម្មសិទ្ធិដីធ្លី សម្រាប់គម្រោងលំនៅឋានសង្គម

Commented [RH16]: យោបល់ពី M. Ramasamy

Commented [RH17]: យោបល់ពី R. Deau

Commented [RH18]: យោបល់ពី Raphaele Deau

# គន្ថីទី ៧– ការរៀបចំផែនការ និងការគ្រប់គ្រងធនធានធម្មជាតិ

- *គន្ថីនេះនឹងចែងអំពីក្របខណ្ឌនៃការរៀបចំផែនការមួយ ដើម្បីរៀបចំនូវដែនកំណត់សម្រាប់ការប្រើប្រាស់ដោយចីរភាព និងកិច្ចការពារសម្រាប់ធនធានធម្មជាតិ ដែលមានលក្ខណៈពាណិជ្ជកម្ម និងមិនមានលក្ខណៈពាណិជ្ជកម្មនៃប្រទេសកម្ពុជា ។*

- *គន្ថីនេះក៏នឹងទាក់ទងផងដែរទៅនឹងគន្ថីទី ៩ ស្តីពីការវាយតម្លៃហេតុប៉ះពាល់ជាយុទ្ធសាស្ត្រ ដែលអាចតម្រូវឱ្យធ្វើឡើងមុនពេលអនុម័តនូវផែនការ និងគោលនយោបាយនានា ។*

- *គន្ថីនេះនឹងពិនិត្យលើតួនាទី និងមុខងារនៃដីសម្បទានសេដ្ឋកិច្ច និងការអនុវត្តគម្រោង ដោយប្រើប្រាស់ដីសម្បទានសេដ្ឋកិច្ច ។*

- *វានឹងរួមបញ្ចូលនូវបទប្បញ្ញត្តិ ដើម្បីតម្រូវឱ្យមានការពិចារណាអំពីកិច្ចការពារបរិស្ថាន នៅក្នុងការធ្វើអាជីវកម្មលើធនធានធម្មជាតិជាលក្ខណៈពាណិជ្ជកម្ម និងលក្ខណៈជីវព្រឹត្តិ ក៏ដូចជា នៅក្នុងសកម្មភាពទាំងឡាយណា ដែលអាចប៉ះពាល់ដល់ធនធានធម្មជាតិ ។ ការនេះនឹងរួមបញ្ចូលការត្រួតពិនិត្យផ្នែកបរិស្ថានលើការអនុវត្តក្នុងវិស័យកសិកម្ម រួមមាន ការប្រើប្រាស់ជី ថ្នាំសម្លាប់សត្វល្អិត និងថ្នាំសម្លាប់ស្មៅ ។*

## ជំពូកទី # – ការរៀបចំផែនការគ្រប់គ្រងស្របតាមផែនការគ្រប់គ្រងបរិស្ថានថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់មូលដ្ឋាន

## ការដាក់បញ្ចូលគួរអោយកត់សំគាល់ – មាតិការពេញលេញនៃគន្ថីទី ១៣ ការបង្កើតប្រភេទការបៀងអភិរក្សជាតិ????

## ជំពូកទី # – ការបង្កើតដែនបម្រុងសមុទ្រ

## ជំពូកទី # – ការបង្កើតដែនបម្រុងជលផលទឹកសាប

## ជំពូកទី # – ការបង្កើតតំបន់ផលិតកម្មទឹកសាប

## ជំពូកទី # – ការអភិរក្ស និងការប្រើប្រាស់ដោយសមស្របនៃធនធានធម្មជាតិ

## ជំពូកទី # – នីតិវិធីសម្រាប់ការផ្តល់ ការអនុវត្តតាមដាន និងការបញ្ចប់ដីសម្បទានសេដ្ឋកិច្ច

## ជំពូកទី # – ការគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច រួមបញ្ចូល ផែនការគ្រប់គ្រងតម្លាភាព និងភាពទាក់ទងនឹងផលិតកម្មឈើដោយចីរភាព និងស្តារជីវៈចម្រុះឡើងវិញ

# គន្ថីទី ៨ – ការអភិរក្ស និងការគ្រប់គ្រងជីវៈចម្រុះ

- *គន្ថីនេះនឹងពិនិត្យពិច័យទៅលើការការពារ ការអភិរក្ស និងការគ្រប់គ្រងជីវៈចម្រុះ និងនឹងរួមបញ្ចូលនូវជំពូកស្តីពី ព្រៃឈើ ដីសើម ប្រព័ន្ធអេកូឡូស៊ីសមុទ្រ ប្រភេទ (សត្វ និងរុក្ខជាតិ) ជិតផុតពូជប្រភេទ (សត្វ និងរុក្ខជាតិ) ឈ្លានពាន និងការគ្រប់គ្រងតំបន់ការពារ ។*
- *ជំពូកជាក់លាក់មួយចំនួន អាចចែងអំពី តំបន់ជាអាទិភាពនានា ដែលរួមបញ្ចូល បឹងទន្លេសាប និងទន្លេមេគង្គ។*
- *មតិយោបល់ត្រូវបានទទួលពីអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន ស្តីពី គោលនយោបាយសត្វព្រៃ (រឺ កសិដ្ឋានសត្វព្រៃ)ក្នុងប្រទេសកម្ពុជា។ អត្ថបទពិភាក្សាលើកឡើងពីបញ្ហាសំខាន់ៗមួយចំនួន និងក្តីបារម្ភអំពីលទ្ធភាពក្នុងការណែនាំថ្មីនូវកសិដ្ឋានសត្វព្រៃមកក្នុងប្រទេសកម្ពុជា។ការពិចារណាកំពុងត្រូវគូសបញ្ជាក់ទៅលើបញ្ហាដែលលើកឡើងតាមរយៈមតិយោបល់នោះ*

## ជំពូកទី # – ការការពារប្រភេទ សត្វ និងរុក្ខជាតិកំពុងរងគ្រោះថ្នាក់

## ជំពូកទី # – ការការពារសត្វព្រៃ

Commented [RH19]: ទំនាក់ទំនងរវាង ជំពូកទាំងពីរនេះ នឹងត្រូវបញ្ជាក់ច្បាស់ រឺក៏ជំពូកអាចបញ្ចូលគ្នា

## ជំពូកទី # – ការការពាររុក្ខជាតិ និងសហគមន៍រុក្ខជាតិ

## ជំពូកទី # – ការការពាររុក្ខជាតិដែលមានដើមកំណើតក្នុងស្រុក និងជម្រកសត្វព្រៃ និងសហគមន៍ធម្មជាតិ (សហគមន៍អេកូឡូស៊ី) សំខាន់ៗ រួមបញ្ចូលជម្រកសត្វសំខាន់ៗ សម្រាប់សត្វ និងរុក្ខជាតិដែលកំពុងរងគ្រោះថ្នាក់

## ជំពូកទី # – ការរៀបចំផែនការជីវៈតំបន់សម្រាប់ការអភិរក្សជីវៈចម្រុះ

## ជំពូកទី # – ការហាមឃាត់នូវការនាំចេញ ឬនាំចូលនូវរុក្ខជាតិ និងសត្វដែលត្រូវកំណត់ជាក់លាក់ និងផលិតផលដែលផលិតចេញពីរុក្ខជាតិ និងសត្វព្រៃ

## ជំពូកទី # – ការហាមឃាត់នូវការធ្វើពាណិជកម្ម ការកាន់កាប់ ឬការលក់ដូរនូវប្រភេទសត្វ និងរុក្ខជាតិ ដែលកំពុងរងគ្រោះថ្នាក់

## ជំពូកទី # – ការពង្រឹងការអនុវត្តអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់ និងភាពត្វកិច្ចនៃកិច្ចព្រមព្រៀងអន្តរជាតិផ្សេងទៀត

## ជំពូកទី # – ការប្រើប្រាស់លក្ខណៈវិទ្យាសាស្ត្រ និងលក្ខណៈអប់រំ

## ជំពូកទី # – ការបង្កើត/ការធ្វើចំណាត់ថ្នាក់តំបន់ការពារសម្រាប់ការអភិរក្សជីវៈចម្រុះ

## ជំពូកទី # – ការស្តារឡើងវិញនូវប្រព័ន្ធអេកូឡូស៊ីដែលរងការខូចខាត

## ជំពូកទី # – ផែនការគ្រប់គ្រង និងការពារប្រភេទសត្វ និងរុក្ខជាតិដែលកំពុងរងការគម្រាមកំហែង (រួមបញ្ចូល ការកំណត់ដំណើរការគម្រាមកំហែងចម្បងៗ និងការបង្កើតផែនការកាត់បន្ថយការគម្រាមកំហែង និងផែនការស្តារឱ្យដូចដើមវិញ)

## ជំពូកទី # – ការហាមឃាត់លើការធ្វើឱ្យខូចខាត ឬការបំផ្លិចបំផ្លាញរុក្ខជាតិដែលមានដើមកំណើតក្នុងស្រុក និងតំបន់ការពារព្រៃឈើ

## ជំពូកទី # – ការហាមឃាត់នូវការប្រម៉ាញ់នៅក្នុងតំបន់មួយចំនួន

## ជំពូកទី # – ការហាមឃាត់សកម្មភាពនៅក្នុងតំបន់ការពារ

## ជំពូកទី # – ការគ្រប់គ្រងនូវប្រភេទសត្វ និងរុក្ខជាតិ ដែលឈ្លានពាន (រាតត្បាត)

## ជំពូកទី # – និយមន័យនៃសារពាង្គកាយកែច្នៃហ្សែន

## ជំពូកទី # – ការហាមឃាត់នូវការប្រើប្រាស់សារពាង្គកាយកែច្នៃហ្សែន រួមបញ្ចូលគ្រាប់ពូជ

## ជំពូកទី # – ការគ្រប់គ្រង និងការឯកភាពលើការប្រើប្រាស់សារពាង្គកាយកែច្នៃហ្សែន

# គន្ថីទី ៩ – ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ

ស្នើរអោយសៀវភៅនេះយកលំនាំតាមគន្ថីស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

- *គន្ថីនេះនឹងគូសបញ្ជាក់ពីការប្រើប្រាស់នូវការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ សម្រាប់ការវាយតម្លៃ និងការអភិវឌ្ឍន៍ផែនការ និងគោលនយោបាយនានានៅក្នុងប្រទេសកម្ពុជា ។ ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រអាចប្រើប្រាស់ទៅលើគោលនយោបាយ និងផែនកាគ្រប់ប្រភេទ រួមបញ្ចូល ការសម្រេចចិត្តដែលអាចមានផលប៉ះពាល់ទៅលើការគ្រប់គ្រងធនធានធម្មជាតិ។*
- *គន្ថីនេះក៏ចែងផងដែរនូវទំនាក់ទំនងរវាងផែនការបរិស្ថាន និងធនធានធម្មជាតិ ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោងជាក់លាក់នានា។*

## ជំពូកទី # – ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រសម្រាប់គោលនយោបាយ និងផែនការ

**មាត្រា#**

ក្រសួងបរិស្ថានទទួលខុសត្រូវទៅលើការត្រួតពិនិត្យសារជាថ្មី និងការវាយតម្លៃទៅលើការវាយតម្លៃបរិស្ថានជាយុត្តិសាស្ត្រ នៃគោលនយោបាយ គម្រោងយុត្តិសាស្ត្រ របស់រាជរដ្ឋាភិបាល ហើយក៏ដូចជាការត្រួតពិនិត្យសារជាថ្មីទៅលើយោបល់ដែលទទួលបានពីភ្នាក់ងារ និងសាធារណជនដែលទាក់ទិន។

## ជំពូកទី # – ប្រព័ន្ធនៃការបែងចែកតំបន់

## ជំពូកទី # – ការរៀបចំរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ

## ជំពូកទី # – ខ្លឹមសារនៃរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ

## ជំពូកទី # – ការវាយតម្លៃលើរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ

**Commented [RH20]:** ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ គឺមានមុខការលើសពីការវាយតម្លៃ គោលនយោបាយ ផែនការ និង កម្មវិធី ប្រសិនបើយើងប្រៀបធៀបជាមួយការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលជាការវាយតម្លៃគម្រោង។ បើទោះជាវាមានការទាក់ទងគ្នា មានឧបករណ៍ដាច់ដោយឡែកសម្រាប់ការធ្វើផែនការ និងការវាយតម្លៃ។ ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រគួរចេញមុនការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដូចជាលិខិតុបករណ៍ក្នុងការធ្វើផែនការ

**Commented [RH21]:** យោបល់ពី R. Deau

# គន្ថីទី ១០ – ស្តង់ដាគុណភាពបរិស្ថាន និងគោលការណ៍ណែនាំស្តីពីការការពារបរិស្ថាន

- *គន្ថីនេះនឹងចែងអំពីនីតិវិធីសម្រាប់រៀបចំបង្កើតស្តង់ដារគុណភាពបរិស្ថានថ្នាក់ជាតិ និងថ្នាក់មូល-ដ្ឋាន និងគោលការណ៍ណែនាំ ។ វានឹងចែងអំពីព័ត៌មានលម្អិតស្តីពីប្រភេទ និងបរិមាណនៃការបំភាយ (អ៊ីមីស្យុង)។ គន្ថីនេះក៏នឹងទទួលយកនូវ កម្រិត និងស្តង់ដារ ដែលមានស្រាប់ផងដែរ រហូតដល់ពេលដែលអាចកែសម្រួល ឬធ្វើវិសោធនកម្មទៅលើគោលការណ៍ណែនាំ និងស្តង់ដារបរិស្ថានទាំងនេះ ។*

- *គន្ថីនេះនឹងតម្រូវឱ្យក្រសួងពាក់ព័ន្ធទាំងអស់ គោរពតាមស្តង់ដារគុណភាពបរិស្ថាន និងគោលការណ៍ណែនាំទាំងនេះ ។*

- *ស្តង់ដារគុណភាពបរិស្ថាន និងគោលការណ៍ណែនាំនៅក្នុងគន្ថីនេះ នឹងលាតសន្ធឹងទៅដល់គោលការណ៍ និងគោលបំណង នៃសុវត្ថិភាពស្បៀងអាហារ ។*

Commented [RH22]: ស្តង់ដាមាននៅក្នុងប្រទេសកម្ពុជា។ គន្ថីនេះនឹងធ្វើបច្ចុប្បន្នភាពទៅលើស្តង់ដាគុណភាពបរិស្ថាន និងនឹងចែងពីគោលការណ៍ណែនាំការការពារបរិស្ថាន។ ការបង្កើត និងការរៀបចំស្តង់ដាគុណភាពបរិស្ថាន និងគោលការណ៍ណែនាំការការពារដាក់លាក់គួរចែកអោយដាច់ពីគន្ថីដោយលើកឡើងពីការអនុវត្តស្តង់ដាគុណភាពបរិស្ថាន។ស្តង់ដាគុណភាពបរិស្ថាននឹងត្រូវបានអនុវត្តនៅក្នុងគន្ថីស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានផងដែរ

Commented [RH23]: យោបល់របស់ក្រុម២ នៅក្នុងសិក្ខាសាលាលើកឡើងថាស្តង់ដាគុណភាពបរិស្ថានគួរតែមានកិច្ចជួយពីអ្នកជំនាញការអន្តរជាតិក្នុងការកំណត់អោយច្បាស់ពីស្តង់ដាគុណភាពបរិស្ថានដែលអាចអនុវត្តបានក្នុងប្រទេសកម្ពុជា។

## ជំពូកទី # – ការកំណត់អំពីស្តង់ដារគុណភាពបរិស្ថាន

## ជំពូកទី # – ការកំណត់អំពីស្តង់ដារ និងស្តង់ដារបរិស្ថានជុំវិញ

## ជំពូកទី # – ការកំណត់អំពីស្តង់ដារនៃការបញ្ចេញចោល

## ជំពូកទី # – ការកែលម្អ (កែសម្រួលឡើងវិញ)នូវ ស្តង់ដារគុណភាពបរិស្ថាន

## ជំពូកទី # – ការអនុវត្តស្តង់ដារគុណភាពបរិស្ថាននៅក្នុងប្រទេសកម្ពុជា

## ជំពូកទី # – ការអនុម័តទទួលយកជាបណ្តោះអាសន្ននូវស្តង់ដារអន្តរជាតិ

## ជំពូកទី # – និយមន័យនៃបច្ចេកវិជ្ជាដ៏ល្អបំផុតដែលអាចស្វែងរកបាន

## ជំពូកទី # – និយមន័យនៃការអនុវត្តល្អៗ

# គន្ថីទី ១១ – ទីក្រុងប្រកបដោយចីរភាព

- *គន្ថីនេះនឹងតម្រូវថា ផែនការ និងការគ្រប់គ្រងលើការប្រើប្រាស់ដី សម្រាប់តំបន់ទីក្រុង ឬទីប្រជុំជន ត្រូវធ្វើឡើងដើម្បីលើកកម្ពស់ទីក្រុងប្រកបដោយចីរភាព និងដែលមានភាពធុនស៊ាំ ។*
- *វានឹងធានាថា ការរៀបចំផែនការត្រូវពិចារណាអំពីផលប៉ះពាល់រយៈពេលវែងទៅលើតំបន់ទីក្រុង ឬទីប្រជុំជន រួមបញ្ចូល ការប្រែប្រួលអាកាសធាតុ ថាមពល ទឹក ចំនួនប្រជាជន និងការអភិវឌ្ឍសេដ្ឋកិច្ច ។*
- *គន្ថីនេះនឹងពិនិត្យទៅលើការគ្រប់គ្រងដើមឈើ ដែលស្ថិតនៅតាមបណ្តោយផ្លូវសាធារណៈនិង ការអភិវឌ្ឍន៍មនុស្ស និងទីក្រុងដែលមានមេត្រីភាពជាមួយធម្មជាតិ រួមបញ្ចូល ការលើកកម្ពស់ថាមពលដែលកកើតឡើងវិញ នៅក្នុងតំបន់ទីក្រុង និងទីប្រជុំជន ។*
- *ការបង្កើតស្ថាប័នពិសេសក្នុងការលើកកម្ពស់ការកសាងសមត្ថភាព និងការអប់រំបច្ចេកទេសស្តីពីទីក្រុងប្រកបដោយចីរភាព*

## ជំពូកទី # – ការអភិវឌ្ឍន្ទមជ្ឈមណ្ឌលចីរភាពទីក្រុង ឬទីប្រជុំជន

## ជំពូកទី # – ការរៀបចំផែនការនៃទីក្រុងប្រកបដោយចីរភាព

## ជំពូកទី # – ការបង្កើតនូវផែនការកែច្នៃឡើងវិញសម្រាប់តំបន់ទីក្រុង ឬទីប្រជុំជន

## ជំពូកទី # – ការលើកកម្ពស់ប្រសិទ្ធផលនៃថាមពល

## ជំពូកទី # – ការកំណត់អំពីស្តង់ដារប្រសិទ្ធផលនៃថាមពល

## ជំពូកទី # – ការកំណត់ស្តង់ដារសម្រាប់អគារបៃតង

Commented [RH24]: បញ្ចូលជាមួយគន្ថី៦ តាមរយៈយោបល់ក្រុម១ ក្នុងសិក្ខាសាលាខែមេសា

Commented [RH25]: យោបល់ពី Andeol Cadin

## ជំពូកទី # – ការអនុម័តជាមថមនៃស្តង់ដារអន្តរជាតិ

## ជំពូកទី # – ការបង្កើតលំនៅដ្ឋានប្រកបដោយចីរភាព និងប្រសើរជាងមុន

# គន្ថីទី ១២ – ការរៀបចំផែនការនិងការគ្រប់គ្រងតំបន់ឆ្នេរ

- *គន្ថីនេះនឹងចែងអំពីក្របខណ្ឌនៃការរៀបចំផែនការមួយ សម្រាប់ការប្រើប្រាស់ និងការគ្រប់គ្រងតំបន់ឆ្នេរ ។*
- *គន្ថីនេះនឹងចែងនូវសេចក្តីលម្អិត សម្រាប់ការគ្រប់គ្រងលើការអភិវឌ្ឍន៍សេដ្ឋកិច្ច និងទេសចរណ៍ក្នុងតំបន់ឆ្នេរ។ គន្ថីនេះនឹងទទួលយកនូវការការពារ និងការត្រួតពិនិត្យយ៉ាងដិតដល់ ដើម្បីការពារតំបន់ឆ្នេរ ឱ្យចៀសផុតពីការអភិវឌ្ឍន៍ដែលមិនល្អ ។*
- *គន្ថីនេះនឹងបញ្ចូលតំបន់ដែលមានស្រាប់នានា ដែលទទួលបាននូវការយកចិត្តទុកដាក់ជាពិសេស និងប្រព័ន្ធមួយសម្រាប់រៀបចំតំបន់ថ្មីៗដែលត្រូវអភិវឌ្ឍន៍ រួមបញ្ចូល ការគ្រប់គ្រងស្ថាប័នថ្មីដែលបានស្នើឡើង និងដែលមានស្រាប់ ។*

## ជំពូកទី # – ការបង្កើតសេចក្តីព្រាងផែនការគ្រប់គ្រងតំបន់ឆ្នេរ

## ជំពូកទី # – គោលបំណងទូទៅនៃការអភិរក្សនិងការគ្រប់គ្រង តំបន់ឆ្នេរ

## ជំពូកទី # – បទប្បញ្ញត្តិពិសេសសម្រាប់ការអភិរក្សព្រៃកោងកាង

## ជំពូកទី # – ខ្លឹមសារនៃផែនការគ្រប់គ្រងតំបន់ឆ្នេរ

## ជំពូកទី # – ការអនុម័តផែនការគ្រប់គ្រងតំបន់ឆ្នេរ

## ជំពូកទី # – ការអនុវត្តផែនការគ្រប់គ្រងតំបន់ឆ្នេរ

## ជំពូកទី # – ការធ្វើផែនទីតំបន់ឆ្នេរ រួមបញ្ចូលការធ្វើផែនទីផ្កាថ្ម

**Commented [RH26]:** ស្នើរអោយសៀវភៅនេះគួរបញ្ចូលតំបន់ឆ្នេ និងសមុទ្រ។ បញ្ហានេះស្ថិតនៅក្នុងការពិចារណា

**Commented [RH27]:** យោបល់ពី R. Deau

## ជំពូកទី # – ការធ្វើវិសោធនកម្មផែនការគ្រប់គ្រងតំបន់ឆ្នេរ

## ជំពូកទី # – តួនាទី និងការទទួលខុសត្រូវរបស់ក្រសួង

## ជំពូកទី # – តួនាទី និងការទទួលខុសត្រូវរបស់សហគមន៍

## ជំពូកទី # – លក្ខខណ្ឌតម្រូវនានាសម្រាប់ការចូលរួមជាសាធារណៈ

## ជំពូកទី # – ការលើកកម្ពស់ការអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងតំបន់ឆ្នេរ

## ជំពូកទី # – ការហាមឃាត់សកម្មភាពនានានៅក្នុងតំបន់ឆ្នេរ ដែលមិនស្របតាមផែនការគ្រប់គ្រងតំបន់ឆ្នេរ

# គន្ថីទី ១៣– ការបង្កើតប្រព័ន្ធតំបន់ការពារធម្មជាតិ

- *គន្ថីនេះនឹងបង្កើតនូវប្រព័ន្ធមួយនៃប្រកបរបៀងអភិរក្សជាតិ។ ប្រកបរបៀងទាំងនេះនឹងត្រូវជាតំបន់ដែលមានស្ថានភាពផ្លូវច្បាប់ និងការការពារបរិស្ថានជាក់លាក់ ដែលរួមបញ្ចូលៈ*

  - *ឧទ្យានជាតិ*
  - *ឧទ្យានទីក្រុង ឬទីប្រជុំជន និងប្រកបរបៀងដើមឈើ*
  - *ដីឯកជនភ្ជាប់ជាមួយនឹងកិច្ចព្រមព្រៀងអភិរក្ស ដោយរួមបញ្ចូលទាំង រមណីយដ្ឋានធម្មជាតិ កសិកម្មសរីរាង្គ*

Commented [RH28]: ដោយ Andeol Cabin

## ជំពូកទី # – ការបង្កើតនូវប្រកបរបៀងអភិរក្សជាតិ រួមបញ្ចូល ការដាក់ឈ្មោះ ទីតាំង និង ឯកសារយោងព្រំប្រទល់/ផែនទី

## ជំពូកទី # – ការធ្វើចំណាត់ថ្នាក់តំបន់ដែលស្ថិតនៅក្នុងប្រកបរបៀងអភិរក្សជាតិ

## ជំពូកទី # – សកម្មភាពដែលត្រូវបានហាមឃាត់នៅក្នុងប្រករបៀងអតិរេក្សជាតិ

## ជំពូកទី # – ការរៀបចំ និងការឯកភាពលើផែនការគ្រប់គ្រងសម្រាប់ប្រករបៀងអតិរេក្សជាតិ

## ជំពូកទី # – ការស្តារឡើងវិញនូវទីជម្រក ឬប្រព័ន្ធអេកូឡូស៊ីដែលរងការខូចខាត នៅក្នុងប្រករបៀងអតិរេក្សជាតិ

## ជំពូកទី # – នីតិវិធីសម្រាប់ការកែសម្រួលចំពោះព្រំប្រទល់នៃប្រករបៀងអតិរេក្សជាតិ

# គន្ថីទី ១៤– ការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព

- ក្នុងលក្ខណៈជាផ្នែកសំខាន់នៃក្របខណ្ឌនៃការរៀបចំផែនការ គន្ថីនេះនឹងបង្កលក្ខណៈឱ្យមានការរៀបចំតំបន់នានា ដែលមានការការពារ និងស្ថានភាពផ្លូវច្បាប់ជាក់លាក់ ដើម្បីបង្កលក្ខណៈឱ្យមានការគ្រប់គ្រងឈើប្រកបដោយចីរភាព ។

## ជំពូកទី # – ការបង្កើតនូវវិស័យព្រៃឈើប្រកបដោយចីរភាព គោលបំណង និង ដែនកំណត់នៃការគ្រប់គ្រងឈើប្រកបដោយចីរភាព

## ជំពូកទី # – ការហាមឃាត់នូវការកាប់ ការដកចេញ ការនាំចេញ និងការប្រើប្រាស់ឈើ ដោយគ្មានលិខិតអនុញ្ញាត ស្របតាមក្រមនេះ

## ជំពូកទី # – ការវាយតម្លៃសំណើសុំប្រមូលផលឈើ ឬការនាំចេញឈើ

## ជំពូកទី # – ការហាមឃាត់ចំពោះការយកឈើចេញពីដីសម្បទានសេដ្ឋកិច្ច ដោយគ្មានលិខិតអនុញ្ញាត

**Commented [RH29]:** ដូរពី Timber ទៅForestry តាមអ្វីដែលបានណែនាំក្នុងសិក្ខាសាលាក្នុងខែមេសា

### ជំពូកទី # – លិខិតអនុញ្ញាតក្នុងការកាប់ ឬយកឈើចេញ ដែលត្រូវផ្តល់ឱ្យចំពោះតែក្នុងករណីមានការវាយតម្លៃបរិស្ថានលើសកម្មភាពនោះប៉ុណ្ណោះ

### ជំពូកទី # – ការប្រមូលផលប្រកបដោយចីរភាព នូវផលឈើ អុសដុត និងអនុផលព្រៃឈើនៅក្នុងតំបន់ផលិតកម្មព្រៃឈើ ដោយរួមបញ្ចូលទាំងយន្តការផ្តល់លិខិតអនុញ្ញាតិអន្តរជាតិ

### ជំពូកទី# –ការប្រមូលផលប្រកបដោយចីរភាព នូវផលឈើ អុសដុត និងអនុផលព្រៃឈើពីព្រៃសហគមន៍ តំបន់សហគមន៍ និង ដីកម្មសិទ្ធសហគមន៍ ជនជាតិដើមភាគតិច

### ជំពូកទី # – តួនាទីរបស់រដ្ឋាភិបាល និងប្រជាពលរដ្ឋ ក្នុងការអង្កេតតាមដាន និងត្រួតពិនិត្យប្រតិបត្តិការគ្រប់គ្រងឈើដោយចីរភាព

### ជំពូកទី # – ការស្តារឡើងវិញនូវទីជម្រក ឬប្រព័ន្ធអេកូឡូស៊ីដែលរងការខូចខាត

## គន្លីទី ១៥– ការគ្រប់គ្រងជលផលប្រកបដោយចីរភាព

- *ក្នុងលក្ខណៈជាផ្នែកសំខាន់នៃក្របខណ្ឌនៃការរៀបចំផែនការ គន្លីនេះនឹងបង្កលក្ខណៈឱ្យមានការរៀបចំតំបន់នានា ដែលមានការការពារ និងស្ថានភាពច្បាប់ជាក់លាក់ ដើម្បីបង្កលក្ខណៈឱ្យមានការគ្រប់គ្រងជលផលប្រកបដោយចីរភាព ។*
- *ពិចារណាទៅលើប្រព័ន្ធការផ្តល់លិខិតអនុញ្ញាតដែលទាក់ទិន*

### ជំពូកទី # – ការបង្កើតនូវឧស្សាហកម្មជលផលប្រកបដោយចីរភាព

### ជំពូកទី # – បទប្បញ្ញត្តិសម្រាប់ផលនេសាទធម្មជាតិ និងវារីវប្បកម្ម និងតំបន់ការពារជលផល

### ជំពូកទី # – ការការពារជលផល និងប្រព័ន្ធអេកូឡូស៊ីក្នុងទឹក

Commented [RH30]: ដោយ Andeol Cadin

Commented [RH31]: ដោយAndeol Cadin

## ជំពូកទី # – សិទ្ធិកាន់កាប់ជលផល និងប្រតិបត្តិការវារីវប្បកម្ម

## ជំពូកទី # – ការធ្វើអត្តសញ្ញាណកម្មសារពាង្គកាយក្នុងទឹក

## ជំពូកទី # – ការហាមឃាត់លើការនេសាទលក្ខណៈពាណិជ្ជកម្មដែលគ្មានលក្ខណៈចីរភាព

## ជំពូកទី # – ការវាយតម្លៃលើពាក្យស្នើសុំការនេសាទលក្ខណៈពាណិជ្ជកម្ម

## ជំពូកទី # – សហគមន៍នេសាទ

## ជំពូកទី # – ការហាមឃាត់ការនាំចេញត្រី ឬសារពាង្គកាយក្នុងទឹក ដោយគ្មានលិខិតអនុញ្ញាត

## ជំពូកទី # – លិខិតអនុញ្ញាតក្នុងការនាំចេញត្រី ឬសារពាង្គកាយក្នុងទឹក ដែលត្រូវផ្តល់ឱ្យក្នុងករណីមានលក្ខណៈចីរភាព

## ជំពូកទី # – ការគ្រប់គ្រងប្រកបដោយចីរភាពនូវជលផល និងតំបន់បន្តពូជត្រី

## ជំពូកទី # – តួនាទីរបស់រដ្ឋាភិបាល និងប្រជាពលរដ្ឋ ក្នុងការអង្កេតតាមដាន និងត្រួតពិនិត្យប្រតិបត្តិការគ្រប់គ្រងជលផលប្រកបដោយចីរភាព

## ជំពូកទី # – ការស្តារឡើងវិញនូវជម្រកជលផល ឬប្រព័ន្ធអេកូឡូស៊ីក្នុងទឹកដែលរងការខូចខាត

## ជំពូកទី # – ការគ្រប់គ្រងសកម្មភាពនានាដែលមានផលប៉ះពាល់លើជលផល និងប្រព័ន្ធអេកូឡូស៊ីក្នុងទឹក

# គន្ថីទី ១៦– ការគ្រប់គ្រងសហគមន៍

- *គន្ថីនេះពិនិត្យទៅលើជម្រើសរបស់សហគមន៍ ក្នុងការប្រើប្រាស់ធនធានធម្មជាតិ ការប្រមាញ់ ការនេសាទត្រីរបស់សហគមន៍ និងការប្រើប្រាស់ដីសម្រាប់តម្រូវការសហគមន៍ប្រកបដោយចីរភាព ។*

- *បញ្ចូលនូវការកែលម្អទៅលើនិតិវិធីសហគមន៍ព្រៃឈើនិងតំនប់ការពារសហគមន៍ក្នុងពេលបច្ចុប្បន្ន*

## ជំពូកទី # – ការលើកកម្ពស់សហគមន៍ព្រៃឈើ និងសហគមន៍តំបន់ការពារ នៅក្រោមក្របខណ្ឌនៃការគ្រប់គ្រងរួបរួមគ្នា

## ជំពូកទី # – ការបង្កើតនូវការគ្រប់គ្រងរួម ក្នុងនាមជាឧបករណ៍អភិរក្ស លក្ខណ:ពហុភាគីពាក់ព័ន្ធ

## ជំពូកទី # – យន្តការ និងធាតុផ្សំនៃការគ្រប់គ្រងរួម

## ជំពូកទី # – នីតិវិធីក្នុងការបង្កើតនូវតំបន់គ្រប់គ្រងរួម

# គន្ថីទី ១៧– ការគ្រប់គ្រងសំណល់ និងការត្រួតពិនិត្យការបំពុល

- *គន្ថីនេះនឹងពិនិត្យពិច័យសារជាថ្មីទៅលើបទប្បញ្ញត្តិនៃអនុក្រឹត្យស្តីពី ការគ្រប់គ្រងសំណល់រឹង លេខ ៣៦ អនក្រ.បក ១៩៩៩ ។ គន្ថីនេះនឹងធ្វើបច្ចុប្បន្នភាពទៅលើបទប្បញ្ញត្តិពាក់ព័ន្ធ អំពីការគ្រប់គ្រងសំណល់រឹង និងសំណល់ប្រកបដោយគ្រោះថ្នាក់ ។ គន្ថីនេះនឹងធ្វើបច្ចុប្បន្នភាព និងដាក់បញ្ចូលផងដែរនូវបទប្បញ្ញត្តិដែលទាក់ទងនឹងអនុក្រឹត្យស្តីពីការបំពុលទឹក លេខ២៧ អនក្រ.បក ១៩៩៩ និងការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេងរំខាន លេខ ៤២ អនក្រ ២០០០។*

- *ថ្លៃសេវា និងបន្ទុកផ្សេងៗ នឹងមានចែងស្របតាមគន្ថីទី ២៦ ។*

- *លក្ខខណ្ឌតម្រូវនានាសម្រាប់ការធ្វើរបាយការណ៍ និងការអង្កេតតាមដាន រួមបញ្ចូល ការលាតត្រដាងជាសាធារណ: នឹងមានចែងនៅក្នុងគន្ថីទី ២៩ ។*

- *នីតិវិធីសម្រាប់ការស៊ើបអង្កេតលើការរំលោភបំពាន និងបទល្មើស នឹងមានចែងនៅក្នុងគន្ថីទី ៣០ ។ គោលបំណងគឺថា ការស៊ើបអង្កេត និងដំណើរការនីតិវិធីសម្រាប់បទល្មើសទាក់ទងនឹងការគ្រប់គ្រង*

**Commented [RH32]:** ណែនាំអោយចែកគន្ថី១៧ជា២គន្ថី។ គន្ថីដំបូង លើកពី ការគ្រប់គ្រងសំណល់និងសារធាតុប្រកបដោយគ្រោះថ្នាក់ ចំណែកគន្ថីបន្ទាប់លើកពីការគ្រប់គ្រងការបំពុលបរិស្ថាន។ នៅពេលដែលក្រមត្រូវបានរៀបលំដាប់លំដោយឡើងវិញរួច បញ្ហាខាងលើនឹងត្រូវបានអនុម័ត

*សំណល់ និងការបំពុល នឹងមានលក្ខណៈដូចគ្នានឹង នីតិវិធីសម្រាប់បទល្មើស និងការរំលោភបំពានផ្សេងទៀតនៃក្រមបរិស្ថាន ។*

## ជំពូកទី # – ការលើកកម្ពស់ ការបញ្ចៀស និងការកាត់បន្ថយសំណល់

## ជំពូកទី # – ការលើកទឹកចិត្ត និងការសម្របសម្រួលការកែច្នៃឡើងវិញ (រួមបញ្ចូលការធ្វើនិយតកម្មចំពោះធុរៈកិច្ចកែច្នៃសំណល់)

## ជំពូកទី # –តួនាទី និងទំនួលខុសត្រូវរបស់រដ្ឋាភិបាល វិស័យឯកជន និងប្រជាជនក្នុងការកែច្នៃឡើងវិញ កាកាត់បន្ថយសំណល់ និងការគ្រប់គ្រងសំណល់

Commented [RH33]: យោបល់ពី R. Deau

## ជំពូកទី # – ការធ្វើស្លាកសញ្ញាសម្រាប់សំណល់

## ជំពូកទី # – ការធ្វើអត្តសញ្ញាណកម្ម ការគ្រប់គ្រង និងការសម្អាតដីដែលមានជាតិពុល

## ជំពូកទី # – បទប្បញ្ញត្តិស្តីពីបរិក្ខាគ្រប់គ្រងសំណល់ រួមបញ្ចូល ទីលានចាក់សម្រាម

## ជំពូកទី # – ស្តង់ដារសម្រាប់ការធ្វើចំណាត់ថ្នាក់សំណល់

## ជំពូកទី # – ការគ្រប់គ្រងឡដុតកម្ទេចសំណល់

## ជំពូកទី # – ការគ្រប់គ្រង និងការកម្ចាត់ចោលសំណល់រឹង

## ជំពូកទី # – ការគ្រប់គ្រងសំណល់ដែលគ្រោះថ្នាក់

## ជំពូកទី # – ការដឹកជញ្ជូនសំណល់

## ជំពូកទី # – ប្រព័ន្ធរំដោះទឹកសាធារណៈ ការបង្ហូររំដោះទឹកភ្លៀង

## ជំពូកទី # – ប្រព័ន្ធប្រព្រឹត្តកម្មទឹកល្អ

## ជំពូកទី # – ការនាំចូល និងការនាំចេញសំណល់

## ជំពូកទី # – ការអនុវត្តអនុសញ្ញាអន្តរជាតិស្តីពីសំណល់

## ជំពូកទី # – បញ្ហានៃការគ្រប់គ្រងការបំពុល រួមបញ្ចូល ខ្យល់ ទឹក សំឡេង ក្លិន ផ្សែង អ័ព្ទ រំញ័រ ពន្លឺ អូហ្សូន វិទ្យុសកម្ម និងដីដែលមានជាតិពុល

## ជំពូកទី # – ការបំភាយឧស្ម័ន( អ៊ីមីស្យុង )នៃយានយន្ត/យាន្តយន្ត

## ជំពូកទី # – ការបំពុលឆ្លងដែន

## ជំពូកទី # – ការបំពុលដោយផ្សែងអ័ព្ទ

## ជំពូកទី # – ការគ្រប់គ្រងសារធាតុគីមី

## បទបញ្ញត្តិទូទៅ

### មាត្រា ១

*ច្បាប់នេះមានគោលដៅដើម្បី :*

១. លើកស្ទួយការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងការប្រើប្រាស់ប្រកបដោយសុវត្ថិភាព នូវរាល់សារធាតុគីមី និងផលិតផលគីមី នៅព្រះរាជាណាចក្រកម្ពុជា ។

២. ធានាការចុះបញ្ជី ការធ្វើចំណាត់ថ្នាក់ និងការដាក់ស្លាកសញ្ញាលើសារធាតុគីមី និង ផលិតផលគីមីគ្រោះថ្នាក់ ដើម្បីជៀសវាងការប្រើប្រាស់មិនត្រឹមត្រូវ និងលើកកំពស់សុវត្ថិភាព ក្នុងការប្រើប្រាស់សារធាតុគីមីគ្រោះថ្នាក់នៅគ្រប់ទីកន្លែង ។

**Commented [RH34]:** ជំពូកថ្មី បានដាក់បញ្ចូលពីសេចក្តីព្រាង

**Commented [RH35]:** អត្ថបទខាងក្រោម មាត្រា១ដល់មាត្រា៣៦ គឺយកចេញពីពង្រាងច្បាប់ស្តីពីការគ្រប់គ្រងសារធាតុគីមី។ អត្ថបទនេះនឹងត្រូវបានពិនិត្យសារឡើងវិញយ៉ាងប្រុងប្រយត្ន័ក្រែងមានការកែប្រែ និងភាពស៊ីគ្នាជារួមក្នុងក្របខណ្ឌទូទៅនៃក្រម។

**Commented [RH36]:** ត្រូវដោះស្រាយទៅលើការពិនិត្យតាមកាលកំណត់នៃស្តង់ដារការបំភាយ M. Ramasamy

៣. លើកកំពស់ការយល់ដឹងជាសាធារណៈ និងទទួលបានរាល់ព័ត៌មានអំពីសុវត្ថិភាព និងកាត់បន្ថយហានិភ័យនៅគ្រប់ដំណាក់កាល នៃវដ្តសារធាតុគីមី រួមបញ្ចូលទាំងការផលិត ការទុកដាក់ ការដឹកជញ្ជូន ការប្រើប្រាស់ និងការបោះបង់ចោល ។

៤. បង្កើតយន្តការសម្របសម្រួលរបស់ស្ថាប័នរដ្ឋ និងប្រព័ន្ធព័ត៌មានសម្រាប់ធានា ប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងការត្រួតពិនិត្យសារធាតុគីមី និងផលិតផលគីមីនៅគ្រប់ដំណាក់ កាលនៃវដ្តរបស់វា ។

៥. ធានាឲ្យមានប្រព័ន្ធគ្រប់គ្រងថ្នាក់ជាតិ ដោយបញ្ចូលផលិតកម្មស្អាតទៅក្នុងខ្សែចង្វាក់ ផលិតកម្ម សេវាកម្ម ក៏ដូចជាការទុកដាក់ និងការបោះបង់ចោលសារធាតុគីមីទៅក្នុងបរិស្ថាន ។

## មាត្រា ២

ច្បាប់នេះមានគោលបំណងដើម្បី ការពារហេដ្ឋារចនា សម្ព័ន្ធសង្គម ជីវិតមនុស្សសត្វ និងបរិស្ថានដែលអាចទទួលរងផលប៉ះពាល់បណ្តាលមកពី សារធាតុគីមី និងរាល់ហានិភ័យនៃគ្រោះថ្នាក់បង្កឡើងដោយការប្រើប្រាស់សារធាតុគីមី និងផលិតផលគីមីមិនត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសនៅគ្រប់ដំណាក់កាលនៃវដ្តរបស់វា ។

## មាត្រា ៣

ច្បាប់នេះមានវិសាលភាពគ្របដណ្តប់លើសារធាតុគីមី ឬផលិតផលគីមីទាំងអស់ និង អនុវត្តចំពោះរាល់នីតិបុគ្គល ឬរូបវន្តបុគ្គល ដែលផលិត ដឹកជញ្ជូន ទិញ-លក់ ប្រើប្រាស់ ទុកដាក់ បញ្ចេញ ឬបោះចោលសារធាតុគីមី និងគ្រឿងផ្សំនៅគ្រប់ដំណាក់កាលនៃវដ្តរបស់វា ។

ច្បាប់នេះមិនអនុវត្តចំពោះសារធាតុវិទ្យុសកម្ម ឱសថ សារធាតុសំអាងកាយ គ្រឿងផ្សំ សម្រាប់ផលិតម្ហូបអាហារ ឬឧបករណ៍ប្រើប្រាស់ និងសម្ភារៈក្មេងលេង ដែលស្ថិតនៅក្រោម ច្បាប់ និងបទប្បញ្ញត្តិផ្សេង ។

## មាត្រា ៤

និយមន័យនៃវាក្យស័ព្ទសំខាន់ៗពាក់ព័ន្ធនឹងសារធាតុគីមីគ្រោះថ្នាក់ ដែលបានប្រើប្រាស់ ក្នុងច្បាប់នេះ មានពន្យល់នៅក្នុងឧបសម្ព័ន្ធ១ ។

## ជំពូក ២
## ស្ថាប័នទទួលខុសត្រូវ

### មាត្រា ៥

ក្រសួងបរិស្ថានជាស្ថាប័នទទួលខុសត្រូវលើការគ្រប់គ្រង និងការអនុវត្តច្បាប់នេះ ដោយ សហការជាមួយក្រសួង/ស្ថាប័នពាក់ព័ន្ធ និងអនុវត្តដោយមានសុខដុមនីយកម្ម ជាមួយច្បាប់ និងបទប្បញ្ញត្តិនានាដែលស្ថិតនៅជាធរមាន ពាក់ព័ន្ធការគ្រប់គ្រងសារធាតុគីមី និងសំណល់គីមីនៅព្រះរាជាណាចក្រកម្ពុជា។

### មាត្រា ៦

រាជរដ្ឋាភិបាលកម្ពុជាត្រូវចាត់តាំងបង្កើតយន្តការសមស្របសម្រាប់គ្រប់គ្រង និងត្រួត ពិនិត្យសារធាតុគីមីនៅរាល់ដំណាក់កាលនៃវដ្តរបស់វា ជាពិសេសសម្រាប់ធ្វើការផ្លាស់ប្តូរ ព័ត៌មាន អភិបាលកិច្ច ចំណាត់ថ្នាក់ និងការផ្តល់ព័ត៌មានអំពីភាពគ្រោះថ្នាក់ និងការវាយ តម្លៃហានិភ័យ នៃសារធាតុគីមីដែលបានចុះបញ្ជី និងពុំទាន់បានចុះបញ្ជីដែលកំពុងធ្វើចរាចរណ៍ នៅព្រះរាជាណាចក្រកម្ពុជា ។

### មាត្រា ៧

ក្រសួងបរិស្ថានត្រូវសម្របសម្រួលដល់ការអនុវត្តរាល់កិច្ចព្រមព្រៀង និងអនុសញ្ញាអន្តរ -ជាតិផ្សេងៗពាក់ព័ន្ធនឹងសារធាតុគីមី។

### មាត្រា ៨

ច្បាប់នេះមិនអនុញ្ញាតឲ្យនីតិបុគ្គល ឬរូបវន្តបុគ្គលធ្វើសកម្មភាពពាក់ព័ន្ធនឹងសារធាតុ គីមីដូចខាងក្រោម ៖

១. ណែនាំឲ្យស្គាល់ ឬផ្គត់ផ្គង់សារធាតុគីមីដែលមានឈ្មោះ និងស្លាកសញ្ញាផលិតកម្មពុំ ត្រឹមត្រូវ ឬសារធាតុគីមីដែលហាមឃាត់។

២. ការកែប្រែ ការបំផ្លាញ ឬការលុបចេញនូវចំណែកណាមួយ ឬទាំងស្រុងរាល់ស្លាកសញ្ញានៃសារធាតុគីមីក្នុងពេលដឹកជញ្ជូន ទោះបីស្ថិតក្នុងកាលៈទេសៈណាក៏ដោយ ។

៣. ទទួលយកសារធាតុគីមី ដែលមានឈ្មោះ និងស្លាកសញ្ញាផលិតកម្មពុំត្រឹមត្រូវ ឬសារធាតុគីមីគ្រោះថ្នាក់ដែលហាមឃាត់ និងហាមដឹកជញ្ជូនទៅកាន់គោលដៅណាមួយសម្រាប់ ការធ្វើអាជីវកម្ម ឬដើម្បីគោលបំណងផ្សេងទៀត ។

## មាត្រា ៩

នីតិបុគ្គល ឬរូបវន្តបុគ្គលគ្មានសិទ្ធិផលិត ប្រើប្រាស់ និងចែកចាយសារធាតុគីមីមិន ងាយបំបែកធាតុដែលហាមឃាត់ដោយអនុសញ្ញាស្តុកខូមដូចមានរាយឈ្មោះនៅក្នុងឧបសម្ព័ន្ធ២នៃច្បាប់នេះ ។ បញ្ជីឈ្មោះសារធាតុគីមីហាមឃាត់ទាំងនោះ អាចនឹងបច្ចុប្បន្នកម្មឡើងវិញ ដោយផ្អែកលើការធ្វើសេចក្តីសម្រេចជាថ្មី របស់សន្និសីទបណ្តាប្រទេសហត្ថលេខីជាសមាជិក អនុសញ្ញាស្តុកខូម ដែលក្នុងនោះមានប្រទេសកម្ពុជាផងដែរ ។

## មាត្រា ១០

រាល់សារធាតុគីមី ឬសារធាតុគីមីដែលមានឈ្មោះផលិតកម្មមិនត្រឹមត្រូវ ដែលបាននាំចូល មកព្រះរាជាណាចក្រកម្ពុជា ត្រូវប្រឈមនឹងការរឹបអូស និងការប្រមូលទុក ឬការប្តឹងចោទ ប្រកាន់តាមនីតិវិធីច្បាប់ ។ ប៉ុន្តែករណីនេះ មិនអនុវត្តចំពោះសារធាតុគីមីដែលដឹកជញ្ជូនឆ្លងកាត់ ប្រទេសកម្ពុជា ដើម្បីនាំចេញទៅប្រទេសផ្សេងទៀតដោយមានច្បាប់អនុញ្ញាតត្រឹមត្រូវឡើយ ។

## មាត្រា ១១

នីតិបុគ្គល ឬរូបវន្តបុគ្គលទាំងឡាយពុំមានសិទ្ធិផលិត រក្សាទុក ដឹកជញ្ជូន នាំចូល ចែកចាយ ឬប្រើប្រាស់សារធាតុគីមី ដែលពុំបានចុះបញ្ជីដោយត្រូវអនុលោមតាមអនុក្រឹត្យ លេខ១៨០ ចុះថ្ងៃ ទី២០ ខែតុលា ឆ្នាំ២០០៩ ស្តីពី " ការគ្រប់គ្រងលើការចាត់ថ្នាក់ និងការដាក់ស្លាកសញ្ញាសារធាតុ គីមី " ។

### មាត្រា ១២

នីតិបុគ្គល ឬរូបវន្តបុគ្គលពុំមានសិទ្ធិរក្សាទុក នាំចូល នាំចេញ ឬចែកចាយសារធាតុគីមី ដែលពុំបានធ្វើការវេចខ្ចប់ត្រឹមត្រូវ ដោយអនុលោមតាមបទប្បញ្ញត្តិជាលក្ខខណ្ឌនៃការចុះបញ្ជី ។

### មាត្រា ១៣

នីតិបុគ្គល ឬរូបវន្តបុគ្គលពុំមានសិទ្ធិវេចខ្ចប់ ឬផ្សព្វផ្សាយរាល់សារធាតុគីមីក្នុងគោល បំណងបោកប្រាស់ ដែលនាំទៅរកការយល់ខុសអំពីលក្ខណៈ គុណភាព តម្លៃ សមាសធាតុ សុវត្ថិភាព និងការចុះបញ្ជីត្រឹមត្រូវឡើយ ។

### មាត្រា ១៤

រាល់សារធាតុគីមីប្រកបដោយគ្រោះថ្នាក់ អាស៊ីត ប្រេងឥន្ធនៈ និងសារធាតុគីមីពុល ត្រូវប្រើប្រាស់អនុលោមតាមគោលការណ៍ណែនាំអំពីរបៀបប្រើប្រាស់សុវត្ថិភាពអន្តរជាតិ ហើយប្រសិនមានករណីធ្វើឲ្យពេល វលោក អុកស៊ីដកម្ម របួស និងបំផ្លាញសុខភាពមនុស្ស ឬបរិស្ថាន នីតិបុគ្គល ឬរូបវន្តបុគ្គលត្រូវទទួលខុសត្រូវចំពោះការផាកពិន័យ និងសំណង។

## ជំពូក ៤
## ការចុះបញ្ជី និងការបង្ហាញព័ត៌មាន

### មាត្រា ១៥

នីតិបុគ្គល ឬរូបវន្តបុគ្គលដែលធ្វើសកម្មភាពពាក់ព័ន្ធនឹងការធ្វើអាជីវកម្មសារធាតុគីមី និងផលិតផលគីមី ត្រូវមានកាតព្វកិច្ចដាក់ពាក្យសុំចុះបញ្ជីជាផ្លូវការរាល់សារធាតុគីមី និងផលិត ផលគីមី ដែលមានគោលបំណងផ្សព្វផ្សាយ ចែកចាយ/លក់ ប្រើប្រាស់ និងបំផ្លាញនៅព្រះរាជា ណាចក្រកម្ពុជា ។

### មាត្រា ១៦

ពាក្យសុំចុះបញ្ជីសារធាតុគីមី ត្រូវដាក់ជូនទៅក្រសួងពាក់ព័ន្ធ ដោយភ្ជាប់រាល់ព័ត៌មានចាំបាច់បញ្ជាក់អំពីឈ្មោះនីតិបុគ្គល ឬរូបវន្តបុគ្គលធ្វើអាជីវកម្ម ឈ្មោះសារធាតុគីមី ចំណាត់ថ្នាក់គ្រោះថ្នាក់ ដំណើរការផលិតកម្ម បរិមាណ គោលបំណងនាំចូល ឬការប្រើប្រាស់ ព័ត៌មានអំពីសុវត្ថិភាព ការពណ៌នាអំពីគ្រោះថ្នាក់ ភាពហានិភ័យចំពោះជីវិតមនុស្ស បរិស្ថាននិងអាស័យដ្ឋានធ្វើអាជីវកម្មនៅព្រះរាជាណាចក្រកម្ពុជាឲ្យបានច្បាស់លាស់ ។

## មាត្រា ១៧

ព័ត៌មានអំពីសារធាតុគីមី ត្រូវធ្វើការត្រួតពិនិត្យ វិភាគឡើងវិញ និងទទួលការឯកភាពពី ក្រសួងបរិស្ថាន មុននឹងដាក់ជូនទៅក្រសួង/ស្ថាប័នពាក់ព័ន្ធអនុម័ត ។ ក្រសួងបរិស្ថាន ដោយ មានកិច្ចសហការជាមួយស្ថាប័នពាក់ព័ន្ធ អាចនឹងធ្វើតេស្ត និងពិគ្រោះយោបល់បន្ថែម ដើម្បី ផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃព័ត៌មានដែលបានទទួល ។

## មាត្រា ១៨

ក្រសួង/ស្ថាប័នពាក់ព័ន្ធដែលមានតួនាទីពិនិត្យនិងអនុម័តការចុះបញ្ជី ត្រូវផ្តល់ព័ត៌មាន អំពីសារធាតុគីមី និងផលិតផលគីមី ជូនមកក្រសួងបរិស្ថាន ដើម្បីធ្វើការឃ្លាំមើលការចុះបញ្ជី សារពើភ័ណ្ឌ ការវាយតំលៃភាពងាយរងគ្រោះ និងការធ្វើអធិការកិច្ច ។

## មាត្រា ១៩

បន្ទាប់ពីបានចុះបញ្ជីជាផ្លូវការ នីតិបុគ្គល ឬរូបវន្តបុគ្គល ត្រូវរៀបចំផែនការសកម្មភាព សម្រាប់បញ្ចៀស និងទប់ទល់គ្រោះមហន្តរាយជាយថាហេតុ ការកាត់បន្ថយគ្រោះថ្នាក់ ការ ឃ្លាំមើល និងការគ្រប់គ្រងហានិភ័យផ្សេងៗ ដែលអាចកើតមានឡើងពីសារធាតុគីមី ។ នីតិបុគ្គល ឬរូបវន្តបុគ្គលត្រូវមានភាពស្មោះត្រង់ក្នុងការផ្តល់ព័ត៌មានឲ្យបានសុក្រិត្យអំពីសារធាតុគីមីទៅឲ្យក្រសួង/ស្ថាប័នទទួល ខុសត្រូវ។

## ជំពូក ៥

## ចំណាត់ថ្នាក់ និងការដាក់ស្លាកសញ្ញា

### មាត្រា ២០

ចំណាត់ថ្នាក់ និងការដាក់ស្លាកសញ្ញាលើសារធាតុគីមី ត្រូវអនុលោមតាមបទប្បញ្ញត្តិ ដែល កំណត់ដោយអនុក្រឹត្យលេខ១៨០ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៩ *ស្តីអំពីការគ្រប់គ្រងលើការ ចាត់ថ្នាក់ និងការដាក់ស្លាកសញ្ញាសារធាតុគីមី ។*

### មាត្រា ២១

សូចនាករប្រើប្រាស់ក្នុងការទប់ស្កាត់ ការបង្ការ និងការបញ្ចៀសគ្រោះថ្នាក់រូបវន្តគ្រោះ ថ្នាក់សុខភាព និងគ្រោះថ្នាក់បរិស្ថាន ត្រូវកំណត់ដោយក្រុមការងារអន្តរក្រសួងដែលមាន សមាជិកមកពីក្រសួង/ស្ថាប័នពាក់ព័ន្ធ សាកលវិទ្យាល័យ និងអង្គការក្រៅរដ្ឋាភិបាល ស្របតាម ប្រព័ន្ធចំណាត់ថ្នាក់ និងការដាក់ស្លាកសញ្ញាសកល (GHS) ។ តួនាទី និងភារកិច្ចរបស់ក្រុមការងារអន្តរក្រសួង ត្រូវកំណត់ដោយ អនុក្រឹត្យ ។

### មាត្រា ២២

នីតិបុគ្គល ឬរូបវន្តបុគ្គល ដែលធ្វើអាជីវកម្មពាក់ព័ន្ធនឹងផលិតកម្ម ការវេចខ្ចប់ ការចែកចាយ ការ ដឹកជញ្ជូន និងការលក់ដូរសារធាតុគីមី និងផលិតផលគីមី ត្រូវដាក់ស្លាកសញ្ញាឲ្យបានត្រឹមត្រូវ អនុលោមតាមអនុក្រឹត្យលេខ១៨០ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៩ មុននឹងចែកចាយ ដឹកជញ្ជូន ឬ លក់ដូរ។

### មាត្រា ២៣

នីតិបុគ្គល ឬរូបវន្តបុគ្គល ត្រូវបោះពុម្ពសៀវភៅខ្នាតតូច ឬសៀវភៅព័ត៌មាន ដើម្បី ផ្សព្វផ្សាយអំពីសុវត្ថិភាព ការបញ្ចៀសនិងការកាត់បន្ថយគ្រោះថ្នាក់ និងហានិភ័យដល់សុខភាព រាល់សារធាតុគីមី ដែលមានបំណងចែកចាយ និងលក់នៅព្រះរាជាណាចក្រកម្ពុជា ។

## ជំពូក ៦
## ការដឹកជញ្ជូន

### ជំពូក១ មាត្រា ២៤

នីតិបុគ្គល ឬរូបវន្តបុគ្គល ដែលដឹកជញ្ជូនសារធាតុគីមី ត្រូវគោរពតាមបទប្បញ្ញត្តិក្នុងការ ដឹកជញ្ជូនសារធាតុគីមី ដែលកំណត់ដោយច្បាប់នេះ និងច្បាប់ពាក់ព័ន្ធដទៃទៀត ។

អង្គភាពដឹកជញ្ជូន និងម្ចាស់ក្រុមហ៊ុនដឹកជញ្ជូនត្រូវមានការធានារ៉ាប់រងពេញលេញ រៀបចំផែនការសុវត្ថិភាព និងសុខភាពដល់បុគ្គលិក ហើយនិងផែនការទប់ទល់ចំពោះហេតុការណ៍គ្រោះថ្នាក់ជាយថាហេតុ កំណត់និងចាត់វិធានការចាំបាច់ ដើម្បីកាត់បន្ថយហេតុការណ៍គ្រោះថ្នាក់ និងស្តារឡើងវិញនូវផលវិបាក និងសងនូវការខូចខាតនានាចំពោះសុខភាពមនុស្ស បរិស្ថាននិងបង់ថ្លៃលើការសំអាត ក្នុងករណីហេតុការណ៍គ្រោះថ្នាក់កើតឡើង កំណត់ និងផ្តល់ដំណឹងបន្ទាន់ដល់អាជ្ញាធរមូលដ្ឋាន និងក្រសួងពាក់ព័ន្ធ ដែលមានទីតាំងនៅក្បែរ អំពីហេតុការណ៍ដែលបានកើតឡើងក្នុងអំឡុងពេលដឹកជញ្ជូន ទោះតាមផ្លូវគោក ផ្លូវទឹក ផ្លូវដែក ផ្លូវអាកាស ឬនាវាចរណ៍សមុទ្រ។

## មាត្រា ២៥

ក្រសួងបរិស្ថានត្រូវសម្របសម្រួលជាមួយក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួង/ ស្ថាប័នជំនាញ ដើម្បីរៀបចំបទប្បញ្ញត្តិបច្ចេកទេសបន្ថែម ស្តីពីការដឹកជញ្ជូនសារធាតុគីមី និង ផលិតផលគីមី ប្រកបដោយគ្រោះថ្នាក់។

# ជំពូក ៧
# ការប្រើប្រាស់ និងការបោះបង់ចោល

## មាត្រា ២៦

នីតិបុគ្គល ឬរូបវន្តបុគ្គល មានសិទ្ធិប្រើប្រាស់សារធាតុគីមី ឲ្យស្របតាមបទប្បញ្ញត្តិនៃ ច្បាប់នេះ ដោយត្រូវប្រកាន់ឲ្យបានខ្ជាប់ខ្ជួនរាល់គោលការណ៍ណែនាំបច្ចេកទេស ការពណ៌នា លើស្លាកសញ្ញា និងសុវត្ថិភាពសារធាតុគីមីទាំងនោះ ។

## មាត្រា ២៧

នីតិបុគ្គល ឬរូបវន្តបុគ្គល ដែលប្រើប្រាស់សារធាតុគិមី សម្រាប់ផលិតទំនិញ និងឧបករណ៍ប្រើប្រាស់សព្វសារពើ ត្រូវទទួលខុសត្រូវក្នុងការផាកពិន័យ ទូទាត់សំណង និងការជួសជុល ឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធសង្គម សុខភាពមនុស្ស សុខភាពសត្វ និងបរិស្ថាន ដែលរងការ ប៉ះពាល់ ឬការខូចខាត បង្កឡើងដោយឧប្បទ្ទវហេតុនៃសារធាតុគីមី ។

## មាត្រា ២៨

នីតិបុគ្គល ឬរូបវន្តបុគ្គល ពុំមានសិទ្ធិបោះបង់ចោលផ្នែកណាមួយ ឬទាំងស្រុងរាល់ សារធាតុគីមី ឬសំណល់គីមីទៅក្នុងបរិស្ថាន រួមមានទឹក ដី ខ្យល់ ដោយពុំមានការអនុញ្ញាត ពីក្រសួងបរិស្ថានឡើយ។

ការបោះបង់ចោលចំណែកណាមួយ ឬកញ្ចប់សារធាតុគីមី ត្រូវអនុវត្តតាមបទប្បញ្ញត្តិ ឬគោលការណ៍ណែនាំ ដែលកំណត់ដោយអនុក្រឹត្យលេខ៣៦ អនក្រ/បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការគ្រប់គ្រងសំណល់រឹង និងអនុក្រឹត្យលេខ២៧ អនក្រ/បក ចុះថ្ងៃទី០៦ ខែមេសាឆ្នាំ១៩៩៩ ស្តីពីការគ្រប់គ្រងសំណល់រាវ។

គោលការណ៍ណែនាំបន្ថែមអំពីការបោះចោលរាល់សំណល់គីមី និងសារធាតុគីមីត្រូវ កំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

## មាត្រា ២៩

នីតិបុគ្គល ឬរូបវន្តបុគ្គល ដែលប្រើប្រាស់សារធាតុគីមី សម្រាប់ការស្រាវជ្រាវវិទ្យាសាស្ត្រ ត្រូវមានភារកិច្ចដូចខាងក្រោម ៖

១. ការប្រើប្រាស់សារធាតុគីមី ត្រូវអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

២. មន្ទីរពិសោធន៍ត្រូវមានឧបករណ៍គ្រប់គ្រាន់ ដើម្បីរក្សាទុករាល់សារធាតុគីមី និងត្រូវប្រើប្រាស់សារធាតុគីមីទាំងនោះដោយសុវត្ថិភាព និងត្រូវមានសម្ភារៈការពារខ្លួន ។

៣. សារធាតុគីមី ត្រូវមានស្លាកសញ្ញាត្រឹមត្រូវស្របតាមបទប្បញ្ញតិនៃអនុក្រឹត្យ លេខ១៨០ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៩ *ស្តីអំពីការគ្រប់គ្រងលើការ ចាត់ថ្នាក់ និងការដាក់ស្លាកសញ្ញាសារធាតុគីមី* ។

៤. មន្ទីរពិសោធន៍ត្រូវមានប្រព័ន្ធរៀបចំទុកដាក់ឯកសារ អំពីសារធាតុគីមីដែលបាន ប្រើប្រាស់ ។

៥. ការបោះចោលរាល់សារធាតុគីមី ឬសំណល់គីមី ត្រូវគោរពតាមបទប្បញ្ញត្តិដែលមានចែងក្នុងមាត្រា២៨ នៃច្បាប់នេះ ។

៦. ពេលប្រើប្រាស់សារធាតុគីមីត្រូវរកឲ្យឃើញនូវទំហំនៃភាពគ្រោះថ្នាក់របស់វា និង ត្រូវកាត់បន្ថយទំហំនៃគ្រោះថ្នាក់ដែលអាចកើតឡើងដោយសារការប្រើប្រាស់ និង ការបោះចោលសារធាតុគីមីទាំងនោះ ។ ទន្ទឹមនោះ ត្រូវបង្កើតយន្តការប្រកបដោយ ប្រសិទ្ធភាពមួយ ដើម្បីធ្វើការកាត់បន្ថយហានិភ័យ ។

## មាត្រា ៣០

នីតិបុគ្គល ឬរូបវន្តបុគ្គល ពុំមានសិទ្ធិប្រើប្រាស់សារធាតុគីមី ក្នុងការផលិតចំណីអាហារ គ្រឿងសំអាងកាយ និងសម្ភារៈក្មេងលេងដែលអាច ឬបង្កគ្រោះថ្នាក់ដល់សុខភាព និងជីវិត មនុស្សនិងសត្វឡើយ ។

# ជំពូក ៨
# ឧស្សាហកម្មគីមី

## មាត្រា ៣១

នីតិបុគ្គល ឬរូបវន្តបុគ្គល ដែលផលិតផលសារធាតុគីមី ត្រូវមានសមត្ថភាពបច្ចេកទេសជំនាញក្នុងកិច្ចការពារសុវត្ថិភាពបរិស្ថាន និងសង្គម លើការងារជំនាញ ដូចមានរៀបរាប់ខាងក្រោម ៖

១. ត្រូវមានរោងជាង ឃ្លាំងស្តុក និង សម្ភារៈបច្ចេកទេសសមស្រប ។

២. ត្រូវមានឧបករណ៍ សម្ភារៈសុវត្ថិភាព ឧបករណ៍ការពារហានិភ័យ មានជាអាទិ ឧបករណ៍ពន្លត់ភ្លើង ឧបករណ៍ការពារការផ្ទុះ ឬរន្ទះ ការជ្រាប ឬការលេច សាយភាយចេញសារធាតុគីមី និងឧប្បត្តិហេតុផ្សេងៗ ។

៣. ត្រូវមានសម្ភារៈ និងឧបករណ៍ការពារសុវត្ថិភាពបុគ្គលិក។

៤. ត្រូវមានសម្ភារៈ និងឧបករណ៍ការពារបរិស្ថាន ។

៥. ត្រូវមានប្រព័ន្ធគ្រប់គ្រង និងការធ្វើប្រព្រឹត្តកម្មសំណល់សារធាតុគីមីត្រឹមត្រូវ ។

៦. ត្រូវមានផែនការបង្ការ និងទប់ទល់គ្រោះមហន្តរាយ និងការដាក់តាំងស្លាកសញ្ញាគ្រោះថ្នាក់ និងការពណ៌នាពីគ្រោះ ថ្នាក់។

**មាត្រា ៣២**

នីតិបុគ្គល ឬរូបវន្តបុគ្គល ដែលផលិតសារធាតុគីមី ត្រូវមានបុគ្គលិកជំនាញបច្ចេកទេសឆ្លើយ តបនឹងវិសាលភាពការងារ ប្រភេទ និងទំហំនៃសកម្មភាពផលិតកម្ម ហើយនិងចំណេះដឹងអំពីផែនការសុវត្ថិភាពការងារ និងវិធានការទប់ទល់នឹងហានិភ័យ។

**មាត្រា ៣៣**

នីតិបុគ្គល ឬរូបវន្តបុគ្គល ត្រូវបានលើកទឹកចិត្ត ក្នុងការធ្វើការពិនិត្យឡើងវិញក្នុងខ្សែ ចង្វាក់ផលិតកម្មសារធាតុគីមី ឬផលិតផលបៃតង ដែលបំភាយឧស្ម័នផ្ទះកញ្ចក់តិច ប្រើថាមពល តិច កម្រិតគ្រោះថ្នាក់និងបំពុលទាប ចំពោះបរិស្ថានធម្មជាតិ និងសុខភាពមនុស្ស ។

**មាត្រា ៣៤**

នីតិបុគ្គល ឬរូបវន្តបុគ្គលដែលផលិតសារធាតុគីមី ឬផលិតផលគីមីប្រកប ត្រូវធ្វើសំណើសុំចុះបញ្ជីសារធាតុគីមីឲ្យបានត្រឹមត្រូវ និងត្រូវមានអាជ្ញាប័ណ្ណធ្វើអាជីវកម្មចេញដោយក្រសួង ឬស្ថាប័នមានសមត្ថកិច្ច ដូចមានចែងក្នុងច្បាប់នេះ។

**មាត្រា ៣៥**

ក្នុងករណីផលិតកម្មសារធាតុគីមី និងផលិតផលគីមីប្រកបដោយគ្រោះថ្នាក់ នីតិបុគ្គល ឬរូបវន្តបុគ្គល ត្រូវផ្តល់របាយការណ៍ប្រចាំឆ្នាំពីកិច្ចដំណើរការផលិតកម្ម បរិមាណសមាសធាតុផ្សំ គោលបំណងប្រើប្រាស់ ការចរាចរណ៍ទំនិញ ការទុកដាក់និងប្រព័ន្ធប្រព្រឹត្តិកម្មសំណល់ ផែនការសុវត្ថិភាព និងវិធានការទប់ទល់ហានិភ័យ ជូនចំពោះក្រសួងជំនាញនិងក្រសួងបរិស្ថាន។ ទម្រង់នៃគំរូរបាយការណ៍ត្រូវរៀបចំដោយក្រសួង/ស្ថាប័នជំនាញ ក្រោមកិច្ចសហការជាមួយក្រសួងបរិស្ថាន ។

# ជំពូក ៩
# ការបង្ការ និងការទប់ទល់

## មាត្រា ៣៦

នីតិបុគ្គល ឬរូបវន្តបុគ្គល ត្រូវមានកាតព្វកិច្ចដូចតទៅ ៖

១. ត្រូវគោរពលក្ខខណ្ឌតឹងរឹងទៅលើបច្ចេកទេស គោលការណ៍ណែនាំអំពីស្លាកសញ្ញា និងសុវត្ថិភាព សារធាតុគីមីនីមួយៗ ដែលត្រូវបានកំណត់ដោយសារធាតុប្រកបដោយគ្រោះថ្នាក់និមួយៗ

២. ត្រូវមានវិធានការបង្ការ និងទប់ទល់គ្រោះមហន្តរាយ (ការសង្គ្រោះបឋម ផែនការជំលៀស ឧបករណ៍ពន្លត់ភ្លើង) រួមទាំងឧបករណ៍ការពារសុវត្ថិភាពបុគ្គលិកសំរាប់កម្មករនៅកន្លែងធ្វើការ ។

៣. ត្រូវរៀបចំបើកវគ្គបណ្តុះបណ្តាលជំនាញស្តីពីសុវត្ថិភាពនៃការប្រើប្រាស់សារធាតុប្រកបដោយគ្រោះថ្នាក់ រួមទាំងលំហាត់សមយុទ្ធដែលត្រូវអនុវត្ត ពេលមានគ្រោះថ្នាក់ជាយថាហេតុកើតឡើង ចំពោះមនុស្ស សត្វ និងបរិស្ថាន ។

៤. ត្រូវរៀបចំរាល់ផែនការទប់ទល់គ្រោះមហន្តរាយឲ្យបានហ្មត់ចត់ ។

## មាត្រា #

ក្នុងករណីមានគ្រោះថ្នាក់កើតឡើងដោយសារធាតុគីមីប្រកបដោយគ្រោះថ្នាក់ នីតិបុគ្គល ឬរូបវន្តបុគ្គល ត្រូវ បញ្ឈប់ជាបន្ទាន់រាល់សកម្មភាពផលិតកម្ម ឬអាជីវកម្ម ហើយត្រូវផ្តល់ដំណឹងជាបន្ទាន់ទៅអាជ្ញាធរពាក់ព័ន្ធ ស្ថាប័នមានសមត្ថកិច្ច និងក្រសួងបរិស្ថាន ។ សកម្មភាពចាំបាច់ត្រូវអនុវត្តជាបន្ទាន់ស្របតាមផែនការបង្ការ និងវិធានការទប់ទល់នានាដែលបានលើកឡើង ដើម្បីកាត់បន្ថយគ្រោះថ្នាក់ និងផលប៉ះពាល់ចំពោះសុខភាពមនុស្ស បរិស្ថាន និងទ្រព្យសម្បត្តិ សាធារណៈ។

## មាត្រា #

យន្តការធានារ៉ាប់រងគ្រោះមហន្តរាយ ដែលអាចកើតឡើងជាយថាហេតុបណ្តាលមកពីសារធាតុគីមី ត្រូវបង្កើតឡើងតាមរយៈការបង្កើតយន្តការហិរញ្ញវត្ថុ ដើម្បីបង្ការ ទប់ទល់ និង សងការខូចខាតនិងការសំអាតដែលបានកើតឡើងពីឧប្បត្តិហេតុ

ពាក់ព័ន្ធនឹងសារធាតុគីមីប្រកបដោយគ្រោះថ្នាក់ ។ បទប្បញ្ញត្តិនានា និងដំណើរការនៃការបង្កើតយន្តការធានារ៉ាប់រងនេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូក ១០
## ការផ្តល់ពត៌មាន

**មាត្រា #**

នីតិបុគ្គល ឬរូបវន្តបុគ្គលដែលទទួលបន្ទុក ការចែកចាយ ការលក់ និងការប្រើប្រាស់សារធាតុគីមី ត្រូវផ្តល់ព័ត៌មានផ្សេងៗ ដូចជា ឯកសារអំពីទិន្នន័យសុវត្ថិភាព វិធីផ្សព្វផ្សាយអំពីគ្រោះថ្នាក់ វិធានការបង្ការ និងការកាត់បន្ថយគ្រោះថ្នាក់ ជូនចំពោះក្រសួង/ស្ថាប័នទទួលខុសត្រូវ អ្នកប្រើប្រាស់ និងសាធារណជន ។

# គន្ថីទី ១៨ – ការគ្រប់គ្រងទឹក

- *គន្ថីនេះ នឹងចែងលម្អិតអំពីការគ្រប់គ្រងទឹក និងការរៀបចំផែនការទឹក ។ ផែនការសម្រាប់ការគ្រប់គ្រងទឹកគួរតែត្រូវបានរៀបចំឡើងនៅក្រោមបទប្បញ្ញត្តិនៃគន្ថីទី៥ ដែលចែងអំពីផែនការគ្រប់-គ្រងទឹក ថ្នាក់មូលដ្ឋាន ថ្នាក់តំបន់ និងថ្នាក់ជាតិ។*
- *ការនេះនឹងត្រូវពិចារណាអំពីការរៀបចំនូវការបែងចែកផលប្រយោជន៍ សម្រាប់ការប្រើប្រាស់ផ្លូវទឹកឆ្លងដែន ស្របតាមកាតព្វកិច្ចផ្លូវច្បាប់ជាអន្តរជាតិ ។*
- *សំណល់ទឹក និងការបំពុលទឹក នឹងមានចែងនៅក្នុងគន្ថីទី១៧ ស្តីពីការគ្រប់គ្រងសំណល់ និងការត្រួតពិនិត្យការបំពុល។*

## ជំពូកទី # – កិច្ចសហការអំពីតំបន់ដែលទឹកភ្លៀងហូរចូល រួមបញ្ចូល ទំនាក់ទំនងរវាងផ្នែកខាងលើ និងផ្នែកខាងក្រោមនៃបណ្តោយទន្លេ និងពាមទន្លេ និងរវាងអ្នកប្រើប្រាស់ផ្សេងៗគ្នា

### ជំពូកទី # – ការកំណត់អត្តសញ្ញាណ និងការកម្រិតចំនួន (តាមរយៈការអង្កេតតាមដាន និងការធ្វើផែនទី) ធនធានទឹកក្រោមដី និងលើដីទាំងអស់

### ជំពូកទី # – ប្រព័ន្ធធារាសាស្ត្រ និង ការផ្គត់ផ្គង់ទឹកសម្រាប់គោលបំណងកសិកម្ម

### ជំពូកទី # – ការត្រួតពិនិត្យការហូរច្រោះ(ការគ្រប់គ្រងសារពើរុក្ខជាតិដែលស្ថិតនៅតាមមាត់ទន្លេស្ទឹងបឹង)

### ជំពូកទី # – ផ្លូវទឹកដែលបង្កើតឡើងដោយមនុស្ស

### ជំពូកទី # – អាងស្តុកទឹកសម្រាប់ប្រើប្រាស់ជាសាធារណៈ (យោងទៅកាន់ការរៀបចំផែនការទីក្រុង ឬទីប្រជុំជន នៅក្នុងគន្ថីទី៦)

### ជំពូកទី # – ការបែងចែក និងពាណិជ្ជកម្មទាក់ទងទៅនឹងការទទួលបានសិទ្ធិក្នុងការប្រើប្រាស់ទឹក

### ជំពូកទី # – ការណែនាំអំពីប្រព័ន្ធធ្វើរបាយការណ៍ និងការអង្កេតតាមដាន (យោងទៅកាន់គន្ថីទី ២៩)

## គន្ថីទី ១៩ – ការការពារ និងការគ្រប់គ្រងបេតិកភណ្ឌធម្មជាតិ និងវប្បធម៌

- *គន្ថីនេះនឹងពិនិត្យពិច័យទៅលើ ការកំណត់អត្តសញ្ញាណ ការការពារ និងការគ្រប់គ្រងតំបន់បេតិកភណ្ឌធម្មជាតិ និងវប្បធម៌ ។ វានឹងពិចារណាលើសេចក្តីត្រូវការក្នុងការការពារទាំងបេតិកភណ្ឌវប្បធម៌រូបីយ និងអរូបីយ។*
- *គន្ថីនេះនឹងពិនិត្យទៅលើប្រតិបត្តិការរបស់អាជ្ញាធរអប្សរា និងច្បាប់ពាក់ព័ន្ធ ដើម្បីធានានូវដំណោះស្រាយស្របគ្នាចំពោះការការពារ និងការគ្រប់គ្រងបេតិកភណ្ឌសំណង់ វប្បធម៌ និងធម្មជាតិ រួមបញ្ចូលទាំងបេតិកភណ្ឌរូបីយ និងអរូបីយ។*
- *ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក៏ដូចជាអាជ្ញាធរដទៃៗទៀតដែលមានភារៈកិច្ចគ្រប់គ្រង និងការពារបេតិកភណ្ឌធម្មជាតិ និងវប្បធម៌*

Commented [SM37]: អនុសាសន៍ពីក្រុមការងារបច្ចេកទេសលេខ ៤

- *គន្លីនេះអាចនឹងពិនិត្យពិច័យទៅលើបេតិកភណ្ឌពិភពលោក និងតំបន់ដែលត្រូវបានចាត់ចូលក្នុងបញ្ជីតំបន់រ៉ាំសា និងតំបន់បេតិកភណ្ឌថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ។*

- *គន្លីនេះនឹងធ្វើនិយ័តកម្មទៅលើ សកម្មភាពសំខាន់ៗនៅក្នុងតំបន់បេតិកភណ្ឌ រួមបញ្ចូល តំបន់ទេសចរណ៍ តំបន់ស្រាវជ្រាវ ទីតាំងកំណាយបុរាណវិទ្យា និងសកម្មភាពអភិវឌ្ឍន៍ដទៃៗទៀត។ ក្រៅពីនោះ មានកំណត់សម្គាល់នៅក្នុងជំពូកថ្មីស្តីពីការសិក្សាស្រាវអំពីបូរាណវិទ្យាសង្គ្រោះ។*

- *យន្តការការពារផ្សេងៗទៀតនឹងរួមបញ្ចូលនូវបទប្បញ្ញត្តិស្តីពីការប្រឆាំងការជួញដូរ ការការពារប្រឆាំងទៅនឹងការធ្វើឱ្យខូចខាតដោយថាហេតុ ឬដោយចេតនា ឬការកម្ទេចចោលនូវបេតិកភណ្ឌវប្ប-ធម៌ ឬធម្មជាតិ ដែលបានដឹង ឬមិនបានដឹង និងការជួសជុលនូវបេតិកភណ្ឌដែលរងការខូចខាត និងការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុសម្រាប់ការការពារបេតិកភណ្ឌ។*

## ជំពូកទី # - បញ្ជីសារពើភ័ណ្ឌជាតិស្តីពីបេតកភណ្ឌធម្មជាតិ និងវប្បធម៌

មាត្រា# : ក្រសួងដែលទទួលបន្ទុកត្រូវបង្កើតបញ្ជីសារពើភ័ណ្ឌជាតិស្តីពីបេតកភណ្ឌធម្មជាតិ និងវប្បធម៌

មាត្រា# : បញ្ជីសារពើភ័ណ្ឌជាតិនេះត្រូវមានការធ្វើបច្ចុប្បន្នកម្មឲបានទៀតទាត់

មាត្រា# : ការបង្កើតតំបន់បេតកភ័ណ្ឌជាតិ និងថ្នាក់តំបន់

## ជំពូកទី # – ការកំណត់អត្តសញ្ញាណ និងការជ្រើសរើសតំបន់បេតិកភណ្ឌវប្បធម៌ និងធម្មជាតិ

## ជំពូកទី # – ការធ្វើចំណាត់ថ្នាក់ស្ថានភាពនៃការខូចខាត និងការអតិរេក្ស

## ជំពូកទី # – ការពិចារណាជាពិសេសទៅលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន សម្រាប់តំបន់បេតិកភណ្ឌវប្បធម៌ និងធម្មជាតិ

## ជំពូកទី # – ផែនការគ្រប់គ្រងសម្រាប់តំបន់បេតិកភណ្ឌធម្មជាតិ និងវប្បធម៌

មាត្រា# : រដ្ឋមន្ត្រីអាចនឹងតំរូវឲមានផែនការគ្រប់គ្រងបេតេកភណ្ឌមួយសំរាប់តំបន់បេតេកភណ្ឌធម្មជាតិ និងវប្បធម៌ដូចមាននៅក្នុងបញ្ជីសារពើភ័ណ្ឌជាតិ

មាត្រា# : ផែនការគ្រប់គ្រងបេតេកភណ្ឌ នឹងត្រូវបានបង្កើតឡើងក្រោមការពិគ្រោះយោបល់ជាមួយនឹងសហគមន៍មូលដ្ឋាន និងភាគីពាក់ព័ន្ធដែលបានផ្តល់ចំណាប់អារម្មណ៍

Commented [SM38]: ក្រុមលេខ ៤ សិក្ខាសាលាថ្ងៃទី៦ ខែមេសា

Commented [SM39]: ក្រុមលេខ ៤ សិក្ខាសាលាថ្ងៃទី៦ ខែមេសា

Commented [SM40]: អនុសាសន៍ពីក្រុមការងារបច្ចេកទេសលេខ ៤

មាត្រា# : ផែនការគ្រប់គ្រងបេតិកភណ្ឌ នឹងបង្កើតបាននូវតំបន់ការពារ និងតំបន់ស្នូលសំរាប់ការគ្រប់គ្រងបេតិកភណ្ឌនៃតំបន់

### ជំពូកទី # – លក្ខខណ្ឌតម្រូវសម្រាប់ការវាយតម្លៃផលប៉ះពាល់បេតិកភណ្ឌ

### ជំពូកទី # – បុរាណវិទ្យាសង្គ្រោះ នៅក្នុងតំបន់ដែលកំពុងរងគ្រោះថ្នាក់ រឺដែលកំពុងរងការគំរាមកំហែង

### ជំពូកទី # – បទបញ្ញាត្តិបញ្ឈប់រាល់ការសាងសង់ និងការកាប់បំផ្លាញនៅតាមតំបន់ដែលកំពុងរងគ្រោះថ្នាក់ រឺដែលកំពុងរងការគំរាមកំហែង

### ជំពូកទី # – ផលប៉ះពាល់នៅតាមតំបន់ការពារទៅលើសហគមន៍ផ្សេងៗ

Commented [SM41]: អនុសាសន៍ពីក្រុមការងារបច្ចេកទេសលេខ ៤

## គន្ថីទី ២០ – ឧស្សាហកម្មនិស្សារណកម្ម និងផលប្រយោជន៍សេដ្ឋកិច្ចប្រកបដោយចីរភាព

- *គន្ថីនេះនឹងពិនិត្យពិច័យទៅលើបណ្តាច្បាប់ដែលទាក់ទងទៅនឹងអាជីវកម្មរ៉ែ ក្នុងបទប្បញ្ញត្តិដែលចែងអំពីផលប្រយោជន៍សេដ្ឋកិច្ចប្រកបដោយចីរភាព សម្រាប់ព្រះរាជាណាចក្រកម្ពុជា។*
- *គន្ថីនេះត្រូវមានទំនាក់ទំនងជាមួយគន្ថីស្តីពី ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដើម្បីលើកកម្ពស់ការអភិវឌ្ឍន៍វិស័យឧស្សាហកម្មនិស្សរណកម្មប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល នៅក្នុងប្រទេសកម្ពុជា ។*

### ជំពូកទី # លក្ខខណ្ឌតម្រូវ និងស្តង់ដារនៃកម្មវិធីគំនិតផ្តួចផ្តើមប្រកបដោយតម្លាភាពនៃឧស្សាហកម្មនិស្សារណកម្ម

### ជំពូកទី # ការអនុម័តទទួលយកនូវការអនុវត្តល្អបំផុតនៅក្នុងវិស័យឧស្សាហកម្មនិស្សារណកម្ម

### ជំពូកទី # ការរៀបចំផ្នែកហិរញ្ញវត្ថុ និងសេដ្ឋកិច្ច ដើម្បីធានាឱ្យបាននូវការគ្រប់គ្រងទីតាំងបានត្រឹមត្រូវ

### ជំពូកទី # បទប្បញ្ញត្តិស្តីពីការបិទ ការជួសជុល និងការស្តារ តំបន់ឧស្សាហកម្ម និស្សារណកម្មឡើងវិញ

### ជំពូកទី # ប្រព័ន្ធផ្តល់អាជ្ញាបណ្ណ និងលិខិតអនុញ្ញាត បន្ទាប់ពីមានការឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន

### ជំពូកទី # អាជីវកម្មរ៉ែខ្សាច់

### ជំពូកទី # អាជីវកម្មរ៉ែថ្ម និង ថ្មបំបែក

### ជំពូកទី # រ៉ែខនិជ

### ជំពូកទី # រ៉ែប្រេង និងរ៉ែឧស្ម័ន

Commented [SM42]: បានពីលោក R. Deau

### ជំពូកទី # ផែនការស្តារឡើងវិញ និងផែនការបិទអាជីវកម្ម

### ជំពូកទី # ការផ្តល់ហិរញ្ញប្បទានដល់ការជួសជុល និងការស្តារឡើងវិញសម្រាប់ឧស្សាហកម្មនិស្សារណកម្ម

## គន្ថីទី ២១– ទេសចរណ៍ និងទេសចរណ៍ធម្មជាតិប្រកបដោយចីរភាព

- *គន្ថីនេះនឹងបង្កើតនូវក្របខណ្ឌសម្រាប់លើកទឹកចិត្ត ឱ្យមានសកម្មភាពទេសចរណ៍ធម្មជាតិសមរម្យ នៅក្នុងប្រទេសកម្ពុជា ។*
- *សកម្មភាពទេសចរណ៍ធម្មជាតិរួមមាន ឱកាសទេសចរណ៍ដែលយកសហគមន៍ជាមូលដ្ឋាន និងដែលមានទំហំទ្រង់ទ្រាយតូច ។*
- *គន្ថីនេះនឹងបង្កើតឱ្យមានក្របខណ្ឌ ក្នុងការលើកកម្ពស់ទេសចរណ៍ប្រកបដោយចីរភាពជាទូទៅ រួមមាន ទេសចរណ៍ទ្រង់ទ្រាយធំជាងទេសចរណ៍ធម្មជាតិ ដោយមានការកាត់បន្ថយនូវផលប៉ះពាល់ដល់បរិស្ថាន ។*

## ជំពូកទី # ការលើកកម្ពស់ទេសចរណ៍ធម្មជាតិ និងទេសចរណ៍ប្រកបដោយចីរភាព ក្នុងនាមជាអាទិភាពនៃការអភិវឌ្ឍ

## ជំពូកទី # ការកំណត់/ជ្រើសរើសតំបន់ទេសចរណ៍ធម្មជាតិពិសេស

## ជំពូកទី # ការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុសម្រាប់ប្រតិបត្តិការទេសចរណ៍ធម្មជាតិ

## ជំពូកទី # ស្តង់ដារប្រតិបត្តិការទេសចរណ៍ធម្មជាតិ ( គោលការណ៍ណែនាំសហគមន៍ ការគ្រប់គ្រងសហគមន៍ មូលនិធិសហគមន៍ ។ល។ )

## ជំពូកទី # ទង្វើទីផ្សា និងការលើកកម្ពស់ទេសចរណ៍ធម្មជាតិ

## ជំពូកទី # ទេសចរណ៍បៃតង: ស្តង់ដារ គោលការណ៍ណែនាំ និងការអនុវត្ត

## ជំពូកទី # ក្រមប្រតិបត្តិសម្រាប់ការអភិវឌ្ឍទេសចរណ៍ធម្មជាតិ

# គន្ថីទី ២២ – ថាមពលប្រកបដោយចីរភាព

Commented [SM43]: មានអនុសាសន៍ជាច្រើនលើកឡើងថា គន្ថីនេះគួរប្រែឈ្មោះថា ថាមពល វិញ រួចត្រូវបែងចែកជា ថាមពលដែលអាចប្រើឡើងវិញបាន និងថាមពលដែលមិនអាចប្រើឡើងវិញបាន។

- *គន្ថីនេះនឹងកំណត់អំពីគោលដៅ និងស្តង់ដារសម្រាប់ការអភិវឌ្ឍន៍ថាមពលប្រកបដោយចីរភាពសម្រាប់ប្រទេសកម្ពុជា ។*
- *ជាគន្ថីដែលចែងអំពីយន្តការដើម្បីសម្រេចបាននូវការអភិវឌ្ឍន៍ដ៏ឆាប់រហ័សនូវប្រភពថាមពលនៅក្នុងប្រទេសកម្ពុជា ដែលមានដូចជា៖ ថាមពលវារីអគ្គីសនី ថាមពលខ្យល់ ថាមពលពន្លឺព្រះអាទិត្យ ថាមពលជីវឧស្ម័ន ថាមពលកម្តៅផែនដី ថាមពលរលកទឹក និងថាមពលនុយក្លេអ៊ែរ ។*
- *ជាគន្ថីដែលពិនិត្យទៅលើការអភិវឌ្ឍន៍វិស័យប្រេង និងឧស្ម័ន ទៅតាមលក្ខណៈមួយដែលលើកកម្ពស់ដល់ការអភិវឌ្ឍន៍ប្រកបដោយចីរភាព និងតម្លាភាព។*

## ជំពូកទី # ផែនការថាមពលប្រកបដោយចីរភាព

## ជំពូកទី # ស្តង់ដារ និងបច្ចេកវិទ្យាសម្រាប់ថាមពលប្រកបដោយចីរភាព

## ជំពូកទី # បទប្បញ្ញត្តិស្តីពីថាមពលស្អាត សម្រាប់សហគមន៍ជនបទ

## ជំពូកទី # និយមន័យនៃប្រភពថាមពលប្រកបដោយចីរភាព

## ជំពូកទី # ការលើកកម្ពស់ថាមពលប្រកបដោយចីរភាព

## ជំពូកទី # ការអភិវឌ្ឍប្រព័ន្ធផ្គត់ផ្គង់អគ្គីសនីខ្នាតតូច

## គន្ថីទី ២៣ – ការប្រែប្រួលអាកាសធាតុ

Commented [SM44]: អាចនឹងយកទៅបញ្ចូលជាមួយគន្ថី ២៣ និង២៤

- *គន្ថីនេះនឹងត្រូវគូសបង្ហាញពីរបៀបបញ្ជ្រាបការវាយតម្លៃអំពីការប្រែប្រួលអាកាសធាតុ ទៅក្នុងការគ្រប់គ្រងធនធានធម្មជាតិនៅក្នុងប្រទេសកម្ពុជា។ ដោយការប្រើប្រាស់យុទ្ធសាស្រ្តដែលមានស្រាប់ដើម្បីបន្សាំ និងកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេសកម្ពុជា គន្ថីនេះនឹងថែងលម្អិតអំពីបញ្ហារបៀបដែលបញ្ហាទាំងនោះគួរត្រូវបានលើកយកមកពិចារណា នៅក្នុងអំឡុងពេលនៃដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងដំណើរការគ្រប់គ្រងធនធានធម្មជាតិ។*

- *ជាគន្ថីដែលនឹងដាក់បញ្ចូលនូវយន្តការនៃការប្រែប្រួលអាកាសធាតុអន្តរជាតិ មានដូចជា* REDD + *និងយន្តការដ៏ទៃៗទៀតស្តីពីការប្រែប្រួលអាកាសធាតុ ចូលទៅក្នុងច្បាប់នៃប្រទេសកម្ពុជា។*

- *វានឹងថែងអំពីបញ្ហាសំខាន់ៗមួយចំនួន ទាក់ទងទៅនឹងគន្ថីផ្សេងទៀត រួមមាន ការកសាងភាពធន់ស៊ាំនឹងការប្រែប្រួលអាកាសធាតុ តាមរយៈការរៀបចំផែនការ និងស្តង់ដារសំណង់ (យោងទៅកាន់គន្ថីទី៦ ការគ្រប់គ្រង និងការរៀបចំផែនការប្រើប្រាស់ដីទីក្រុង និងគន្ថីទី១១ ។*

## គន្ថីទី ២៤ – ការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ និងការលើកកម្ពស់ការអភិវឌ្ឍបៃតង

- *គន្លីនេះនឹងគូសបញ្ជាក់ពីរបៀបកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ដោយប្រទេសកម្ពុជា និងការលើកកម្ពស់ការអភិវឌ្ឍបៃតង ។*

- *មិនតែប៉ុណ្ណោះ វាជាគន្លីដែលផ្សាភ្ជាប់ទៅនឹងគន្លីទី២២ ថាមពលប្រកបដោយចីរភាព និងគន្លីទី២៦ ស្តីពី ថ្លៃសេវា បន្ទុកចំណាយផ្សេងៗ និងផលប្រយោជន៍ផ្នែកបរិស្ថាន ។*

### ជំពូកទី # ភាតព្វកិច្ចក្នុងការដោះស្រាយការប្រែប្រួលអាកាសធាតុ

### ជំពូកទី # ការដាក់បញ្ចូលការកាត់បន្ថយការប្រែប្រួលអាកាសធាតុ នៅក្នុងការសម្រេចចិត្តផ្នែកបរិស្ថាន និងធនធានធម្មជាតិ

### ជំពូកទី # ការដាក់បញ្ចូលការសម្របទៅនឹងការប្រែប្រួលអាកាសធាតុ នៅក្នុងការសម្រេចចិត្តផ្នែកបរិស្ថាន និងធនធានធម្មជាតិ

## គន្លីទី ២៥ – ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការគ្រប់គ្រងគ្រោះមហន្តរាយ

- *គន្លីនេះនឹងបែងអំពីលក្ខខណ្ឌតម្រូវផ្សេងៗក្នុងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ដោយការរៀបចំផែនការដែលត្រឹមត្រូវ និងការដាក់បញ្ចូលនូវយុទ្ធសាស្ត្រនៃការកាត់បន្ថយហានិភ័យចូលទៅក្នុងការសម្រេចចិត្តទាក់ទងនឹងការគ្រប់គ្រងធនធានធម្មជាតិ ។*

### ជំពូកទី # ការរៀបចំផែនការគ្រប់គ្រងគ្រោះមហន្តរាយ

### ជំពូកទី # ការដាក់បញ្ចូលផែនការកាត់បន្ថយគ្រោះមហន្តរាយ

### ជំពូកទី # ការអភិវឌ្ឍដែលត្រូវពិចារណាអំពីផែនការគ្រប់គ្រងគ្រោះមហន្ត-រាយ

### ជំពូកទី # ការរៀបចំផែនការសម្រាប់ឧប្បត្តិហេតុនៃការបំពុលចម្បងៗ

## ជំពូកទី # ការឆ្លើយតបចំពោះការខូចខាតបរិស្ថាន

## ជំពូកទី # ការគ្រប់គ្រងគ្រោះមហន្តរាយសម្រាប់តំបន់ការពារ និងតំបន់បេតិកភណ្ឌ

## ជំពូកទី # ការគ្រប់គ្រងគ្រោះមហន្តរាយនៅកន្លែងទុកដាក់សំណល់

## ជំពូកទី # ការគ្រប់គ្រងគ្រោះមហន្តរាយនៅកន្លែងផលិត និងស្តុកទុកថាមពល

## ជំពូកទី # ការគ្រប់គ្រងគ្រោះមហន្តរាយនៅកន្លែងទុកដាក់សារធាតុគីមី

## ជំពូកទី # ភាតព្វកិច្ចក្នុងការរាយការណ៍អំពីគ្រោះមហន្តរាយដែលអាចកើតឡើង

## គន្ថីទី ២៦ – ផលប្រយោជន៍ផ្នែកបរិស្ថាន ថ្លៃសេវា និងបន្ទុកចំណាយផ្សេងៗ

Commented [SM45]: ដោយលោក Teng Rithiny

- *ជាគន្ថីដែលនឹងកំណត់អំពីយន្តការ ដែលអនុញ្ញាតឲ្យសាមីក្រសួងមានសិទ្ធិយកកម្រៃសេវាផ្សេងៗ។*
- *គន្ថីនេះនឹងដាក់បញ្ចូលនូវបទប្បញ្ញត្តិច្បាស់លាស់ ដើម្បីធានាថា ថ្លៃសេវា និងបន្ទុកផ្សេងៗ ដែលបានប្រមូល និងបានទទួល និងឧបករណ៍សេដ្ឋកិច្ច ដែលត្រូវបានបង្កើតឡើង ដូចជា មូលនិធិបរិស្ថាន នឹងត្រូវបានគ្រប់គ្រង ស្របតាមស្តង់ដារអន្តរជាតិស្តីពីគណនេយ្យភាព និងតម្លាភាព ។*
- *មានសំណូមពរមួយបានលើកឡើងថា ប្រទេសកម្ពុជាពុំមានច្បាប់ស្តីពីមូលនិធិគាំទ្របរិស្ថាន ដើម្បីរួមចំណែកដល់ការបង្កើតកញ្ចប់ថវិការដើម្បីបង់ថ្លៃលើសេវាការពារតំបន់ការពារ និងព្រៃការពារ។ ការពិចារណាគួរមានឡើងដើម្បីបង្កើតបាននូវមូលនិធិបែបនេះ។*

## ជំពូកទី # ថ្លៃសេវាដែលត្រូវបង់សម្រាប់សេវាដែលផ្តល់ដោយក្រសួង

## ជំពូកទី # សវនកម្មនៃមូលនិធិ

## ជំពូកទី # ការយកពន្ធបរិស្ថាន

## ជំពូកទី # ផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុសម្រាប់ការវិនិយោគបៃតង

## ជំពូកទី # ផលប្រយោជន៍ពិសេសសម្រាប់ដគូរសាធារណៈ រឹឯកជន

## ជំពូកទី # ផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុ និងវិធានការយកពន្ធ ដើម្បីលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធទីក្រុងបៃតង

## ជំពូកទី # ផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុ និងវិធានការយកពន្ធ ដើម្បីលើកកម្ពស់វិស័យទេសចរណ៍ធម្មជាតិ និងទេសចរណ៍ប្រកបដោយចីរភាព

## ជំពូកទី # ផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុ និងវិធានការយកពន្ធ ដើម្បីលើកកម្ពស់ការអភិរក្ស និងជីវចម្រុះ

## ផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុ និងវិធានការយកពន្ធ ដើម្បីលើកកម្ពស់ការគ្រប់គ្រងធនធានសហគមន៍

## ជំពូកទី # ផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុ និងវិធានការយកពន្ធ ដើម្បីលើកកម្ពស់ផលិតកម្មថាមពលកាបោនកំរិតទាបប្រកបដោយចីរភាព

## ជំពូកទី # ការបង្កើតមូលនិធិអភិវឌ្ឍបរិស្ថាន ការអភិរក្ស និងសង្គម និងគោលដៅនៃមូលនិធិ

## ជំពូកទី # ប្រភពចំណូលសម្រាប់មូលនិធិអភិវឌ្ឍបរិស្ថាន ការអភិរក្ស និងសង្គម

### ជំពូកទី # តម្លាភាព និងនីតិវិធីនៃអភិបាលកិច្ចសម្រាប់មូលនិធិអភិវឌ្ឍបរិស្ថាន ភាពអតិរេក្ស និងសង្គម

### ជំពូកទី # លក្ខណៈវិនិច្ឆ័យសម្រាប់ការផ្តល់មូលនិធិ និងការចំណាយប្រាក់ចេញពីមូលនិធិអភិវឌ្ឍបរិស្ថាន ភាពអតិរេក្ស និងសង្គម

### ជំពូកទី # ហិរញ្ញប្បទានបៃតង

### ជំពូកទី # ហិរញ្ញប្បទានសម្រាប់ការដាក់ស្លាកសញ្ញាបរិស្ថាន

### ជំពូកទី # យន្តការទទួលខុសត្រូវបរិស្ថានសម្រាប់ការបង់ប្រាក់ដោយអ្នកបំពុល/ការខូចខាតបរិស្ថាន (ឧ. ប្រាក់តម្កល់ មូលនិធិបរិស្ថាន និងសង្គម)

### ជំពូកទី # មូលនិធិគាំពារសហគមន៍

## គន្ថីទី ២៧ – ការយល់ដឹងជាសាធារណៈអំពីបរិស្ថាន និងការអប់រំអំពីបរិស្ថាន

- *គន្ថីនេះនឹងចែងលម្អិតអំពីផែនការ សំរាប់ការលើកកម្ពស់ការយល់ដឹងជាសាធារណៈស្តីពីកិច្ចការពារបរិស្ថាន និងបញ្ហាបរិស្ថាន ដោយប្រើប្រាស់នូវវិធីសាស្ត្រប្រាស្រ័យទាក់ទងទ្រង់ទ្រាយធំៗ មានដូចជា មហោស្រព ប្រព័ន្ធអ៊ីនធឺណេត និងវិធីផ្សព្វផ្សាយផ្សេងៗ ។*
- *វានឹងបង្កើតបានជាកម្មវិធីគំនិតផ្តួចផ្តើមស្តីពីព័ត៌មានបរិស្ថាន ដើម្បីអប់រំដល់សាធារណៈជន នឹងវិស័យឯកជនស្តីពីកាតព្វកិច្ចផ្នែកបរិស្ថាន និងបញ្ហាបរិស្ថាន។*

### ជំពូកទី # ការលើកកម្ពស់ការយល់ដឹងអំពីបរិស្ថាននៅក្នុងសាលារៀន

### ជំពូកទី # ការលើកកម្ពស់ការយល់ដឹងអំពីបរិស្ថាននៅក្នុងមហាវិទ្យាល័យ

### ជំពូកទី # ការបង្កើតគណកម្មការអប់រំស្តីពីបរិស្ថាន

### ជំពូកទី # ការអភិវឌ្ឍការបណ្តុះបណ្តាល និងសម្ភារៈសម្រាប់ការអប់រំអំពីបរិស្ថាន (ដូចជា កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈតាមជំនាញ??)

Commented [SM46]: R. Deau

### ជំពូកទី # ការលើកកម្ពស់ការយល់ដឹងអំពីបរិស្ថានដល់សាធារណៈជន

### ជំពូកទី # លក្ខខណ្ឌតម្រូវក្នុងការលើកកម្ពស់ការយល់ដឹងអំពីបរិស្ថាន នៅតាមរោងកុន និងបណ្តាញសារពត៌មាន

### ជំពូកទី # ការគាំទ្រចំពោះយុទ្ធនាការយល់ដឹងអំពីបរិស្ថាន

### ជំពូកទី # ការលើកកម្ពស់ទិវាបរិស្ថានពិភពលោក

### ជំពូកទី # ការលើកកម្ពស់កម្មវិធីបរិស្ថានពិសេស

## គន្ថីទី ២៨ – ការសិក្សា និងការស្រាវជ្រាវស្តីពីធនធានធម្មជាតិ និងបរិស្ថាន

- *ជាគន្ថីដែលនឹងបែងលំអិតទៅលើការលើកកម្ពស់ការស្រាវជ្រាវផ្នែកបរិស្ថាន  និងបញ្ហាគ្រប់គ្រងធនធានធម្មជាតិ។*
- *វានឹងលើកកម្ពស់ដល់ការស្រាវជ្រាវ និងការអភិវឌ្ឍន៍ស្តីពីការអនុវត្តនូវគំហើញថ្មីៗ ដើម្បីការពារ និងគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ។*

### ជំពូកទី # ការបង្កើតនូវវិទ្យាស្ថានស្រាវជ្រាវបរិស្ថាន

### ជំពូកទី # ការផ្តល់អាហារូបករណ៍សម្រាប់ការសិក្សាអំពីបរិស្ថាន

### ជំពូកទី # ការលើកកម្ពស់នូវការស្រាវជ្រាវអំពីបរិស្ថាននៅមហាវិទ្យាល័យ

## ជំពូកទី # ការបង្កើតមជ្ឈមណ្ឌលនៃឧត្តមភាពនៅក្នុងការគ្រប់គ្រងធនធានធម្មជាតិ និងការអភិវឌ្ឍប្រកបដោយចីរភាព

## ជំពូកទី # ការផ្តល់មូលនិធិដល់ការស្រាវជ្រាវអំពីបរិស្ថាន

# គន្លឹះទី ២៩ – សវនកម្មបរិស្ថាន និងរបាយការណ៍គ្រប់គ្រងបរិស្ថាន

- *ជាគន្លឹះដែលនឹងគូសបង្ហាញអំពីគោលការណ៍ និងលក្ខខណ្ឌតម្រូវសម្រាប់សវនកម្មបរិស្ថាន និងលក្ខខណ្ឌតម្រូវនៃរបាយការណ៍ ស្របតាមបញ្ញត្តិដែលពាក់ព័ន្ធនៅក្នុងក្រមបរិស្ថាន។ សវនកិច្ចផ្នែកបរិស្ថាន គឺជាយន្តការសំខាន់មួយដើម្បីធានាថា ម្ចាស់អាជ្ញាប័ណ្ណ និងអស់អ្នកដែលអនុវត្តគម្រោងអភិវឌ្ឍន៍អនុលោមស្របតាមល័ក្ខខ័ណ្ឌនៃការអនុញ្ញាត។ ការនេះរួមមាន ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងកិច្ចសន្យាការពារបរិស្ថាន ក៏ដូចជាល័ក្ខខ័ណ្ឌមួយចំនួនដូចបានភ្ជាប់ទៅនឹងអាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតផ្សេងៗ ឬអាជ្ញាប័ណ្ណ ឬសម្បទានដីសេដ្ឋកិច្ច។*

- *ជាគន្លឹះដែលនឹងបង្កើតបានជាប្រព័ន្ធសមរម្យមួយរបស់ក្រុមហ៊ុន សម្រាប់ការរាយការណ៍ដោយខ្លួនឯងអំពីការបំពុល និងការចុះបញ្ជីកំណត់ពណ៌ (មូលវិចារណ៍) ស្តីពីការអនុលោមផ្នែកបរិស្ថាន។ ក្រុមហ៊ុនទាំងឡាយនឹងត្រូវបានដាក់កំណត់សម្គាល់ដោយ ពណ៌បៃតង និងខៀវ (គោរពច្បាប់បានល្អប្រសើរ) ពណ៌ខ្មៅ (គោរពច្បាប់បានល្អ) ហើយ ពណ៌លឿង និងពណ៌ក្រហម (គោរពច្បាប់មិនបានល្អ) ។*

- *គន្លឹះនេះមិនមានបំណងបង្កើនបន្ទុកផ្នែកច្បាប់ដល់អ្នកទទួលបានអាជ្ញាប័ណ្ណ ឬការឯកភាពនោះទេ ប៉ុន្តែគឺមានបំណងធានាឱ្យបានថា កាតព្វកិច្ចផ្នែកសង្គម និងបរិស្ថាន ត្រូវបានអនុវត្តស្របតាមលក្ខខណ្ឌនៃការឯកភាព។*

## ជំពូកទី # ការបង្កើតន្លូវការរាយការណ៍ដោយខ្លួនឯងសម្រាប់ការអនុលោមផ្នែកបរិស្ថាន

## ជំពូកទី # ភាតព្វកិច្ចក្នុងការរាយការណ៍អំពីការបំពានលើក្រមបរិស្ថាន

## ជំពូកទី # ការបង្កើតនូវប្រព័ន្ធនៃការអនុលោមផ្នែកបរិស្ថាន

## ជំពូកទី # បញ្ជីនៃលិខិតអនុញ្ញាត អាជ្ញាប័ណ្ណ ការឯកភាព និងរបាយការណ៍អធិការកិច្ច

## ជំពូកទី # បញ្ជីរួមដែលត្រូវដាក់បង្ហាញជាសាធារណៈ និងកន្លែងដែលងាយស្រួលស្វែងរក

## ជំពូកទី # សវនកម្មបរិស្ថាន

## ជំពូកទី # ការតែងតាំង និងលក្ខណៈសម្បត្តិនៃសវនករបរិស្ថាន

## ជំពូកទី # គម្រោង និងសកម្មភាពដែលតម្រូវឱ្យមានការចេញវិញ្ញាបនប័ត្របរិស្ថានតាមស្តង់ដារអន្តរជាតិ

## ជំពូកទី # របាយការណ៍អង្កេតតាមដាន ដែលតម្រូវឱ្យមាននៅក្រោមការឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន

## ជំពូកទី # របាយការណ៍អង្កេតតាមដានដែលត្រូវដាក់បង្ហាញជាសាធារណៈ

# គន្ថីទី ៣០ – ការស៊ើបអង្កេត ការអនុវត្ត និងសិទ្ធិទទួលបាននូវដំណោះស្រាយ

- *គន្លឹះនេះនឹងចែងអំពីអំណាចរបស់ក្រសួងពាក់ព័ន្ធ ក្នុងការស៊ើបអង្កេតទៅលើបទល្មើសផ្នែកបរិស្ថាន ដូចមានចែងនៅក្នុងគន្លឹះទី៣១ ។*

- *ជាគន្លឹះដែលចែងនូវបទប្បញ្ញត្តិ ដែលអនុញ្ញាតឲ្យប្រជាពលរដ្ឋ និងអង្គការនានា អនុវត្តតាមនីតិវិធីនៃការដោះស្រាយវិវាទ និងនាំបណ្តឹងទៅកាន់អង្គភាពទទួលបន្ទុកក្នុងការពិនិត្យ ។ បទប្បញ្ញត្តិទាំងនេះនឹងកំណត់ផងដែរ អំពីយន្តការក្នុងការដាក់បណ្តឹងទូទៅ និងការអនុវត្តតាមនីតិវិធីច្បាប់របស់ប្រជាពលរដ្ឋ និងអង្គការនានា ។*

- *គន្លឹះនេះនឹងត្រួតពិនិត្យអំពីការប្រើប្រាស់នីតិវិធីនៃការដោះស្រាយវិវាទដែលពាក់ព័ន្ធ និងយន្តការដោះស្រាយបណ្តឹង ដែលរួមមាន តុលាការ ឬអង្គជំនុំជម្រះ វិស័យបរិស្ថាន ដែលត្រូវធ្វើការពាក់ព័ន្ធទៅនឹងសេចក្តីសម្រេចនៃវិស័យអភិវឌ្ឍន៍ធនធានធម្មជាតិ និងបរិស្ថាន។ វានឹងកំណត់នូវជម្រើសសម្រាប់ក្រសួងបរិស្ថាន ក្នុងការបង្កើតអង្គជំនុំជម្រះវិស័យបរិស្ថាន ដើម្បីពិនិត្យឡើងវិញនូវសេចក្តីសម្រេចស្តីពីការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ដែលត្រូវបានធ្វើឡើងក្រោមក្រមបរិស្ថាននេះ។*

- *គន្លឹះនេះនឹងពិនិត្យផងដែរទៅលើ ជម្រើសផ្សេងទៀតដូចជា អង្គជំនុំជម្រះរដ្ឋបាល និង ស្នងការផ្នែកបរិស្ថាន ដើម្បីដើម្បីពិនិត្យបញ្ហា និងកង្វល់ទាំងឡាយ ដែលទាក់ទងទៅនឹងសេចក្តីសម្រេចចិត្តស្តីពីធនធានធម្មជាតិ និងបរិស្ថាន។ ភ្នាក់ងារទាំងនេះ ត្រូវបង្កើតឡើងដើម្បីឱ្យសហគមន៍មានភាពងាយស្រួលក្នុងការទាក់ទង ហើយនឹងជាស្ថាប័នដែលមានតម្លាភាព និងភាពបើកចំហ។*

- *ឧទាហរណ៍ ដូចជាការប្រើប្រាស់ ភ្នាក់ងាររៀបចំផែនការស្តីពីទីក្រុង ដើម្បីដោះស្រាយវិវាទរវាងសេចក្តីសម្រេចអំពីការរៀបចំផែនការ និងសេចក្តីសម្រេចអំពីការប្រើប្រាស់ដី នៅក្នុងបរិបទទីក្រុងជាដើម។*

# ជំពូកទី # បណ្តឹងបរិស្ថាន

## ផ្នែកទី១៖ ភាគីនៃបណ្តឹងបរិស្ថាន

**មាត្រា** # : ភាគីដែលទទួលរងផលប៉ះពាល់ផ្ទាល់

**មាត្រា** # : ការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ នៅក្នុងបណ្តឹងបរិស្ថាន

**មាត្រា** # : អាជ្ញាធររដ្ឋាភិបាលនៅក្នុងបណ្តឹងបរិស្ថាន

## ផ្នែកទី២៖ ប្រភេទនៃបណ្តឹងបរិស្ថាន

**មាត្រា** # : បណ្តឹងរដ្ឋប្បវេណី

**មាត្រា** # : បណ្តឹងព្រហ្មទណ្ឌ

**មាត្រា** # : បណ្តឹងប្រឆាំងនឹងសេចក្តីសម្រេចផ្នែករដ្ឋបាលរបស់រដ្ឋាភិបាល ឬអាជ្ញាធររដ្ឋាភិបាល

**មាត្រា** # : ទំនាក់ទំនងរវាងបណ្តឹងរដ្ឋប្បវេណី និងបណ្តឹងព្រហ្មទណ្ឌ

## ជំពូក # នីតិវិធីសម្រាប់ការដោះស្រាយបណ្តឹងបរិស្ថាន

## ផ្នែកទី ១ # : បទប្បញ្ញត្តិទូទៅ

**មាត្រា** # : គោលបំណង

**មាត្រា** # : វិសាលភាពនៃការអនុវត្ត

**មាត្រា** # : គោលការណ៍ទូទៅ

**មាត្រា** # : ប្រភេទនៃការដោះស្រាយវិវាទបរិស្ថាន

## ផ្នែកទី ២ : ការដោះស្រាយវិវាទបរិស្ថានក្រៅតុលាការ

**មាត្រា** # : គោលបំណង

**មាត្រា** # : ការតែងតាំងសន្ធានករ/មជ្ឈត្តករ

**មាត្រា** # : កាតព្វកិច្ចរបស់រដ្ឋាភិបាលក្នុងការបង្កើតវិទ្យាស្ថានមជ្ឈត្តការបរិស្ថាន

**មាត្រា** # : បណ្តឹងជំទាស់ទៅកាន់តុលាការ ប្រឆាំងនឹងសេចក្តីសម្រេចរបស់មជ្ឈត្តករ

## ផ្នែកទី ៣ : ការដោះស្រាយវិវាទបរិស្ថានតាមផ្លូវតុលាការ

**មាត្រា** # : សិទ្ធិរបស់ភាគីទទួលរងផលប៉ះពាល់

**មាត្រា** # : កាតព្វកិច្ចរបស់រដ្ឋាភិបាលក្នុងការបង្កើតតុលាការបរិស្ថាន អមជាមួយតុលាការជាន់ទាប និងតុលាការជាន់ខ្ពស់

**មាត្រា** # : សេចក្តីសម្រេចរបស់តុលាការ

**មាត្រា** # : បណ្តឹងឧបាស្រ័យប្រឆាំងនឹងសេចក្តីសម្រេចរបស់តុលាការជាន់ទាប ទៅកាន់តុលាការជាន់ខ្ពស់

## ផ្នែកទី ៤ : បណ្តឹងប្រឆាំងទៅនឹងសេចក្តីសម្រេចរដ្ឋបាលនៃអាជ្ញាធររដ្ឋាភិបាល

**មាត្រា** # : សិទ្ធិរបស់រូបវន្តបុគ្គល/នីតិបុគ្គល ដែលទទួលរងផលប៉ះពាល់

**មាត្រា** # : ការកំណត់រយៈពេលនៃការចេញសេចក្តីសម្រេចអំពីបណ្តឹង

**មាត្រា** # : ការប្តឹងជំទាស់ទៅនឹងសេចក្តីសម្រេចរដ្ឋបាលទៅស្ថាប័នរដ្ឋបាលជាន់ខ្ពស់

## ជំពូក # មន្ត្រីនគរបាលយុត្តិធម៌

**មាត្រា** # : សមាសភាពមន្ត្រីនគរបាលយុត្តិធម៌

**មាត្រា** # : បេសកកម្មមន្ត្រីនគរបាលយុត្តិធម៌

**មាត្រា** # : នីតិវិធីក្នុងការទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌

**មាត្រា** # : សមត្ថកិច្ចដែនដីរបស់មន្ត្រីនគរបាលយុត្តិធម៌

**មាត្រា** # : នីតិវិធីស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ចំពោះបទល្មើសបរិស្ថាន

**មាត្រា** # : កាតព្វកិច្ចរបស់អាជ្ញាធរពាក់ព័ន្ធក្នុងកិច្ចសហការចំពោះការស៊ើបអង្កេតបទល្មើសបរិស្ថាន

**មាត្រា** # : នីតិវិធីនៃការកសាងសំណុំរឿងបទល្មើសបរិស្ថាន

**មាត្រា** # : ការប្រើប្រាស់ឯកសណ្ឋានក្នុងការស៊ើបអង្កេតលើបណ្តឹងបរិស្ថាន

**មាត្រា** # : ការបង្កើតវិទ្យាស្ថានភូមិន្ទឯកទេសផ្នែកព្រៃ

Commented [SM47]: អនុសាសន៍ពីលោក មាស សុផល

## ជំពូក # ការបង្កើតតុលាការ ឬអង្គជំនុំជម្រះផ្នែកបរិស្ថាន និងធនធានធម្មជាតិ

## ជំពូក # ការបង្កើតស្ថាប័នផ្នែកបរិស្ថាន (អធិការកិច្ចបរិស្ថាន)

## ជំពូក # តួនាទីរបស់ស្ថាប័នផ្នែកបរិស្ថាន (អធិការកិច្ចបរិស្ថាន)

## ជំពូក # ការអង្កេតតាមដាន ការអនុលោម និងការពង្រឹងសិទ្ធិរបស់ពលរដ្ឋ

## ជំពូក # ពលរដ្ឋទាំងអស់អាចធ្វើបណ្តឹងទៅចំពោះមុខតុលាការ ឬអង្គជំនុំជម្រះផ្នែកបរិស្ថាន ចំពោះការរំលោភបំពានលើក្រមបរិស្ថាន

## ជំពូក # សិទ្ធិក្នុងការត្រួតពិនិត្យការសម្រេចចិត្តផ្នែកធនធានធម្មជាតិ និងបរិស្ថាន

## ជំពូក # អង្គការមិនមែនរដ្ឋាភិបាលអាចជួយប្រជាពលរដ្ឋ និងសហគមន៍ ក្នុងការនាំយកបញ្ហាមកកាន់តុលាការ ឬអង្គជំនុំជម្រះផ្នែកបរិស្ថាន

## ជំពូក # ភាគព្វកិច្ចរបស់តុលាការ ឬអង្គជំនុំជម្រះផ្នែកបរិស្ថាន ក្នុងការជំនុំជម្រះ និងកំណត់បញ្ហាដោយឆាប់រហ័ស និងយុត្តិធម៌

## គន្លឹះទី ៣១ – បទល្មើសបរិស្ថាន

- *គន្លឹះនេះនឹងគូសបញ្ជាក់ពីបទល្មើសបរិស្ថាន ដែលអាចជាកម្មវត្ថុនៃបណ្ដឹងណាមួយ នៃក្រមរដ្ឋប្បវេណី ឬក្រមព្រហ្មទណ្ឌ ។*
- *វានឹងផ្ដល់នូវមូលដ្ឋាន សម្រាប់ការកំណត់អំពីការបំពាននានានៃក្រមបរិស្ថាន ដែលអាចជាកម្មវត្ថុនៃបណ្ដឹងព្រហ្មទណ្ឌ ។*
- *គន្លឹះនេះនឹងកំណត់អំពី បទល្មើស និងការខកខានមិនបានគោរពទៅតាមបទប្បញ្ញត្តិពាក់ព័ន្ធនៃក្រមបរិស្ថាន ។*
- *គន្លឹះនេះនឹងផ្ដល់នូវព័ត៌មានពាក់ព័ន្ធមួយចំនួន អំពីបទបញ្ញាស្ដីពីសំណង និងការស្ដារឡើងវិញ ក្នុងករណីដែលការបំពាននៃក្រមបរិស្ថាននេះនាំឱ្យមានការខូចខាតបរិស្ថាន ឬគ្រោះថ្នាក់ដល់សុខភាពមនុស្ស ។*
- *វានឹងកំណត់អំពីជម្រើសនៃទណ្ឌកម្ម ដែលរាប់ពីការផាកពិន័យ ដល់ការជាប់ពន្ធនាគា និងការបញ្ជាឱ្យជួសជុលការខូចខាតឡើងវិញ ។ ការនេះនឹងផ្អែកទៅលើការងារដែលត្រូវបានធ្វើឡើងនៅក្នុងសេចក្ដីព្រៀងច្បាប់ស្ដីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។*

## ជំពូកទី # ការរំលោភបំពានលើបទប្បញ្ញត្តិនៃក្រមបរិស្ថាន

## ជំពូកទី # បទល្មើសស្ដីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

## ជំពូកទី # ទោសប្បញ្ញត្តិ

## ជំពូកទី # ការបញ្ជាឱ្យសងសំណងការខូចខាត

## ជំពូកទី # ការធ្វើបដិទាន និងការស្ដារឡើងវិញនូវការខូចខាតបរិស្ថាន

### ជំពូកទី # បទល្មើសទាក់ទងនឹងការបំពុលខ្យល់

### ជំពូកទី # បទល្មើសទាក់ទងនឹងការបំពុលទឹក

### ជំពូកទី # បទល្មើសទាក់ទងនឹងសំណល់

### ជំពូកទី # បទល្មើសទាក់ទងនឹងការធ្វើឱ្យកខ្វក់ ឬការបំពុល

### ជំពូកទី # ការអនុវត្តក្រមព្រហ្មទណ្ឌចំពោះបទល្មើសបរិស្ថាន

### ជំពូកទី # ការអនុវត្តទណ្ឌកម្មរដ្ឋប្បវេណីចំពោះបទល្មើសបរិស្ថាន

### ជំពូកទី # តារាងទណ្ឌកម្មសម្រាប់បទល្មើស

## គន្ថីទី ៣២ – ការឯកភាពរវាងច្បាប់នានា

- *គន្ថីនេះនឹងចែងលម្អិតអំពីច្បាប់  និងអនុក្រឹត្យទាំងឡាយ ដែលនឹងត្រូវនិរាករណ៍ ។*
- *គន្ថីនេះនឹងបញ្ជាក់ពីរបៀបដែលក្រមបរិស្ថាននឹងធ្វើវិសោធនកម្មទៅលើច្បាប់ស្តីពីធនធានធម្មជាតិដែលមានស្រាប់ និងច្បាប់ទាំងឡាយទាក់ទងទៅនឹងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។*

## គន្ថីទី ៣៣ – អន្តរបញ្ញត្តិ

- *គន្ថីនេះនឹងចែងលម្អិតអំពីមាត្រានៃអន្តរប្បញ្ញត្តិដែលចាំបាច់ ដើម្បីធ្វើឱ្យក្រមបរិស្ថានចូលជាធរមាននៅក្នុងរយៈពេលយ៉ាងខ្លីបំផុត ។*

- *វាជាគន្លឹះដែលចែងលម្អិតអំពី របៀបដែលតំបន់ការពារ និងតំបន់បម្រុងទុក ដែលមានស្រាប់នាពេលបច្ចុប្បន្ន ត្រូវបានថែរក្សា ស្របតាមគោលការណ៍នានានៃក្រមបរិស្ថាន រហូតដល់ពេលមួយដែលត្រូវធ្វើការពិនិត្យឡើងវិញ និងវាយតម្លៃស្របតាមបទប្បញ្ញត្តិនៃក្រមបរិស្ថាន ។*
- *ការបង្កើតក្រមបរិស្ថានមិនគួរត្រូវបានប្រើ ដើម្បីបន្តឲ្យមានការបំផ្លិចបំផ្លាញបរិស្ថាននោះទេ ក្នុងអំឡុងពេលដែលផែនការគ្រប់គ្រងបរិស្ថានថ្មីៗកំពុងត្រូវបានបង្កើតឡើង។*
- *គន្លឹះនេះនឹងចែងលម្អិតអំពីបណ្តាច្បាប់ និងអនុក្រឹត្យទាំងឡាយដែលត្រូវនិរាករណ៍។*

## គន្លឹះទី ៣៤ – អវសានបញ្ញត្តិ